01479082

E1/340.1

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

ឯកសារដើម

ORIGINAL/ORIGINAL

ថ្ងៃ ខែ ឆ្នាំ (Date): 16-May-2017, 15:58

CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៥**

**ម៉ោង ០៩:០៣នាទី**

**សវនាការលើកទី៣២១**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍

*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍

*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)

*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ម៉ាដាលេណា ហ្គេហ្ស៊ី

*(Ms. Maddalena Ghezzi)*

លោកស្រី សែ កុលវុឌ្ឍី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

កញ្ញា សុង ឆរ័ន្ត

លោក ត្រាវីស ហ្វារ *(Mr. Travis FARR)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍ *(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡោ ជុនធី

លោក ហុង គឹមសួន

លោក វ៉េន ពៅ

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

# បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក សេង ប៊ុនឃាង | ខ្មែរ |
| លោក ត្រាវីស ហ្វារ | អង់គ្លេស |
| លោក វិចទ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោក ឡោ ជុនធី | ខ្មែរ |
| លោក ស៊ីន សុវ៉ន | ខ្មែរ |
| លោក សម ស័ក្ក (2-TCCP-993) | ខ្មែរ |
| លោក មាន លឿយ (2-TCCP-994) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី៖ លោក សម សំអ្គ** (2-TCCP-993)


សួរដោយប្រធានអង្គជំនុំ ផ្តើមពី ....................ទំព័រ ២

សួរដោយលោក ឡោ ជុនធី ផ្តើមពី....................ទំព័រ ៤

សួរដោយលោក សេង ប៊ុនឃាង ផ្តើមពី....................ទំព័រ ១៨

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី....................ទំព័រ ២៤

សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្តើមពី....................ទំព័រ ៣៦


**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី៖ លោក មាន លឿយ** (2-TCCP-994)


សួរដោយប្រធានអង្គជំនុំ ផ្តើមពី ....................ទំព័រ ៤៦

សួរដោយលោកស្រី ស៊ីន សុវ៉ន ផ្តើមពី ....................ទំព័រ ៤៨

សួរដោយលោក ត្រាវីស ហ្វារ ផ្តើមពី ....................ទំព័រ ៦១

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី....................ទំព័រ ៦៦

សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្តើមពី....................ទំព័រ ៧០

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៣:២៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការស្ដាប់សេចក្ដីថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មដែលកើតមានចំពោះខ្លួននៅលើដើមបណ្ដឹងរដ្ឋប្បវេណីចំនួនពីររូប គឺមួយមានរហស្សនាម 2-TCCP-993 ហើយ និង 2-TCCP-994 ពាក់ព័ន្ធជាមួយនឹងអង្គហេតុការដ្ឋានការងារទំនប់ត្រពាំងថ្ម។

ក្រឡាបញ្ជីសវនាការ លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន! សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះ មានវត្តមាន។ ដោយឡែក លោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ហើយដើមបណ្ដឹងរដ្ឋប្បវេណីដែលត្រូវមកថ្លែងរៀបរាប់ទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្ម នៅថ្ងៃនេះ មានចំនួនពីររូប គឺដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-993 និង 2-TCCP-994។ ហើយនៅក្នុងអំឡុងពេលនៃការថ្លែងទុក្ខសោកនេះផងដែរ គឺមានបុគ្គលិកអង្គការ ធី.ភី.អូ លោក យួន សារ៉ាត់ នៅអង្គុយក្បែរដើមបណ្ដឹងរដ្ឋប្បវេណីទាំងពីររូបនេះ ហើយពួកគាត់មានវត្តមាននៅបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ សូមអរគុណលោកប្រធាន។

[០៩:០៥:១៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។

អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាពឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៥។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យ ព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៥ បានកំណត់សម្គាល់ពីស្ថានភាព សុខភាពរបស់លោក នួន ជា ថា លោក នួន ជា មានអាការៈឈឺចង្កេះខ្លាំង មិនអាចអង្គុយយូរបាន និងផ្តល់អនុសាសន៍ថា សូមអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះនិងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈសវនាការពេញមួយថ្ងៃនេះ។

[០៩:០៦:៣៤]

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ ក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

បាទ ជាបន្តទៅនេះ ឲ្យមន្ត្រីរដ្ឋបាលតុលាការអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-993 រួមទាំងបុគ្គលិកអង្គការធី.ភី.អូ មកកាន់កន្លែងផ្តល់នូវសេចក្តីថ្លែងទុក្ខសោកវេទនារបស់ខ្លួន នៅចំពោះមុខអង្គជំនុំជម្រះក្នុងបន្ទប់សវនាការ។

*(ដើមបណ្តឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកដើមបណ្តឹងរដ្ឋប្បវេណី តើលោកឈ្មោះអី?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោក សម ស័ក្ត៖**

**ឆ៖** បាទ ខ្ញុំឈ្មោះ សម ស័ក្ត។ ឆ្នាំកំណើត ថ្ងៃ០១ ខែ៨ ១៩៦៣។ ខ្ញុំបាទកើតនៅភូមិភ្នំពីរ ស្រុកស្វាយទង ខេត្តមាត់ជ្រូក ប្រទេសវៀតណាម។

**ស៖** ចុះទីលំនៅ លោករស់នៅទីកន្លែងណា? ហើយលោកប្រកបមុខរបររកស៊ីធ្វើអ្វី?

**ឆ៖** បាទ ខ្ញុំសព្វថ្ងៃរស់នៅក្នុងភូមិជាវប្តីខាងលិច ឃុំតាអូ ស្រុកគិរីវង់ ខេត្តតាកែវ។ មុខរបរធ្វើស្រែ។

**ស៖** ឪពុកបង្កើតរបស់លោកឈ្មោះអី? ហើយម្តាយបង្កើតរបស់លោកឈ្មោះអី?

**ឆ៖** ឪពុករបស់ខ្ញុំបាទ ឈ្មោះ សម សាន។ ម្តាយរបស់ខ្ញុំឈ្មោះ កឿង សុង។

**ស៖** ចុះប្រពន្ធរបស់លោកឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** បាទ ប្រពន្ធរបស់ខ្ញុំឈ្មោះ គង់ វណ្ណា។ ខ្ញុំមានកូនចំនួនពីរនាក់។

[០៩:១០:០០]

**ស៖** បាទ អរគុណ ហើយនៅក្នុងការថ្លែងទុក្ខសោកវេទនា និង ព្យសនកម្មដែលខ្លួនទទួលរងរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ អង្គជំនុំជម្រះបានសម្របសម្រួលផ្តល់នូវបុគ្គលិកអង្គការ ធី.ភី.អូ ឈ្មោះ យួន សារ៉ាត់ អង្គុយក្បែរដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីជួយពង្រឹងនូវសតិអារម្មណ៍របស់គាត់ ដើម្បីឲ្យគាត់មានអារម្មណ៍នឹងនរនៅក្នុងអំឡុងពេលនៃការផ្តល់នូវ ថ្លែងទុក្ខសោកវេទនា និង ព្យសនកម្មដែលគាត់ទទួលរង។

លោក សម ស័ក្ត នៅក្នុងនាមលោកជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសវនាការនេះ អង្គជំនុំជម្រះ ផ្តល់វេទិកាជូនទៅលោក ដើម្បីអាចថ្លែងរៀបរាប់ដល់អង្គសវនាការអំពីស្ថានភាពព្យសនកម្ម ទុក្ខសោកវេទនា និងស្ថានភាពព្យសកម្មដែលកើតមានចំពោះលោក ជាអាទិ៍ ការខូចខាតផ្លូវចិត្ត ផ្លូវកាយសម្ភារៈ ដែលជាព្យសនកម្មផ្ទាល់ខ្លួន ដែលជាបច្ច័យដោយផ្ទាល់អំពីបទឧក្រិដ្ឋ និងបានកើតមានពិតប្រាកដរហូតដល់សព្វថ្ងៃនេះ ដែលនាំឲ្យលោកតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងរឿងក្តីនេះ ពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់លើជនជាប់ចោទពីររូប នួន ជា និង ខៀវ សំផន។ ហើយនៅក្នុងពាក្យបណ្តឹងរបស់លោកអះអាងថា បានប៉ះពាល់ចំពោះលោកនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ៧៩ ហើយអង្គហេតុដែលពាក់ព័ន្ធនេះ គឺពាក់ព័ន្ធជាមួយនឹងការដ្ឋានទំនប់ត្រពាំងថ្ម។ ហើយតាមសំណើរបស់ក្រុមសហមេធាវីនាំមុខតំណាង

ដើមបណ្ដឹងរដ្ឋប្បវេណី តទៅនេះអង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្ប-វេណី ដើម្បីមានឱកាសសាកសួរអំពីស្ថានភាពទុក្ខសោកវេទនា និង ព្យសនកម្មទាំងឡាយដែលកើតមានចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម និង សាធារណជន ព្រមទាំងដើមបណ្ដឹងរដ្ឋប្បវេណី។ មេធាវីនាំមុខសុំអនុញ្ញាតផ្ទេរសិទ្ធិនៅក្នុងការសួរដើមបណ្ដឹងរដ្ឋប្ប-វេណី សម ស័ក្ដ ជូនលោកមេធាវី ឡោ ជុនធី ដែលជាមេធាវីផ្ទាល់របស់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

**លោក ឡោ ជុនធី៖**

បាទ សូមអរគុណលោកប្រធាន។ ដំបូងខ្ញុំបាទ សូមគោរពអង្គជំនុំជម្រះទាំងមូល។ ខ្ញុំបាទ ឡោ ជុនធី ដែលជាមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ហើយខ្ញុំបាទមកពីអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា។ នៅពេលនេះ ខ្ញុំបាទសូមសួរសំណួរទៅលើលោក សម ស័ក្ដ ដែលនឹងថ្លែងអំពីទុក្ខសោកក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលពិសេសផ្នែកពាក់ព័ន្ធទៅនឹងទំនប់ត្រពាំងថ្ម។

[០៩:០៩:២១]

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** ជាដំបូង ខ្ញុំសូមសួរបញ្ជាក់លោកបន្តិចពាក់ព័ន្ធនឹងលោកបានឆ្លើយអម្បាញ់មិញថា លោកបានកើតនៅភូមិភ្នំពីរ ស្វាយទង មាត់ជ្រូក ប៉ុន្ដែអ្វីដែលនៅក្នុងអត្តសញ្ញាណប័ណ្ណរបស់លោកបានដាក់ថា “ស្រុកកំណើត នៅជាវប្តីលិច ឃុំតាអូ ស្រុកគីរីវង់ ខេត្តតាកែវ វិញ” ចំណុចនេះ លោកអាចបញ្ជាក់ជូនអង្គជំនុំជម្រះបានទេ?

**លោក សម ស័ក្ដ៖**

**ឆ៖** បាទ អរគុណ។ ខ្ញុំពិតជាកំណើតកើតជានៅកម្ពុជាក្រោមពិតមែន ក៏ប៉ុន្ដែខ្ញុំមករស់នៅក្នុងទឹកដីស្រុកគីរីវង់នេះ តាំងពីយូរមក រៀននៅស្រុកគីរីវង់ ពេលនោះ ខ្ញុំបានចូលធ្វើជាកងទ័ព ខ្ញុំក៏កែប្រែ

ស្រុកកំណើតរបស់ខ្ញុំឲ្យនៅជាភូមិរបស់ប្រពន្ធខ្ញុំវិញ បាទ។

**ស៖** តើមានហេតុផលអីដែលអត់ទេ បានជាលោកសម្រេចដាក់ការកែប្រែនេះ?

**ឆ៖** បាទ កាលនោះ ខ្ញុំធ្វើជាកងទ័ពអ៊ីចឹង ខ្ញុំមិនចង់ឲ្យគេដឹងថាខ្ញុំជាខ្មែរក្រោម ក៏ខ្ញុំដាក់នៅជាខ្មែរលើវិញ។

**ស៖** បាទ អរគុណ។ បន្តទៅនេះខ្ញុំបាទសូមសួរថាតើនៅមុនថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ លោកបានរស់នៅណា? ហើយនិងក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ដែលខាងកម្ពុជាប្រជាធិបតេយ្យហ្នឹង បានចូលមកទីក្រុងភ្នំពេញ ក៏ដូចជាទូទាំងប្រទេសដែរ តើគេបានជម្លៀសលោក និងក្រុមគ្រួសារទៅខាងណាដែរបាទ?

**ឆ៖** បាទ សូមអរគុណ។ បាទ ថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ខ្ញុំបាទរស់នៅក្នុងទីក្រុងភ្នំពេញ គឺនៅម្តុំផ្សារអូឡាំពិក។ ថ្ងៃនោះពេលជាប្រហែលជាម៉ោងប្រាំល្ងាច ពួកខ្មែរក្រហមបានចូលមកដល់ក្រុងភ្នំពេញដេញគ្រួសារខ្ញុំឲ្យចុះចេញពីលំនៅដ្ឋាន។ គេបានប្រាប់ថា "សូមបងប្អូនចាក់ចេញពីទីក្រុងភ្នំពេញទៅនៅជាយក្រុងភ្នំពេញសិន តែរយៈពេលតែបីថ្ងៃទេ ចម្ងាយពីក្រុងបីគីឡូ ទម្រាំអង្គការគេបោសសម្អាតទីក្រុងស្អាត ហើយនិងនាំបងប្អូនឲ្យចូលមកនៅទីក្រុងភ្នំពេញវិញ"។ នេះជាសម្តីរបស់របបខ្មែរក្រហមដែលបានឲ្យយើងចាក់ចេញពីទីក្រុងភ្នំពេញ។ បន្ទាប់មកខ្ញុំក៏បានមកនៅអូរបែកក្អម អស់ពីទីក្រុងទៅអូរបែកក្អមប្រហែលជាបីគីឡូហ្នឹង ត្រូវរបស់គេហើយ។ ហ្នឹងគេឲ្យនៅអូរបែកក្អមសិន។ ពេលនោះខ្ញុំក៏នៅអូរបែកក្អមនៅជាមួយនឹងគេបានប្រហែលជាពីរទៅបីថ្ងៃទេ។

[០៩:១៧:៣២]

បន្ទាប់មកពួកខ្មែរក្រហមបានដេញបន្តទៀតៗ។ ពេលនោះក្រុមគ្រួសាររបស់ខ្ញុំក៏នឹកឃើញដល់ស្រុកទេស។ គាត់ថាគិតទៅកម្ពុជាក្រោមវិញ រស់នៅកម្ពុជាក្រោមវិញ ក៏បានធ្វើដំណើរឆ្លងកាត់ផ្លូវជាតិលេខ២ ទៅទើបដល់ថ្នល់ទទឹង ពួកខ្មែរក្រហមគេសួរថា "ទៅណា?" ហើយបងខ្ញុំគាត់ថា "ខ្ញុំទៅតាកែវស្រុកកំណើតនៅតាកែវ"។ នេះគឺជាល្បិចដោះសា កុហកគេមួយដំណាក់កាលៗ ក៏ប៉ុន្តែពួកខ្មែរក្រហមគេអត់ឲ្យទៅ ដល់ថ្នល់ទទឹង គេឃាត់ឲ្យឈប់ត្រឹមថ្នល់ទទឹងហ្នឹង ឲ្យខ្ញុំរស់នៅភូមិត្រយឹង។ បាទឲ្យរស់នៅក្នុងភូមិត្រយឹងហ្នឹង គឺឲ្យយើងឃ្វាលគោ ឲ្យខ្ញុំនៅតូចខ្ញុំឃ្វាលគោអ៊ីចឹងទៅ។ រើសអាចម៍គោឲ្យគេលើកភ្លឺស្រែឲ្យគេ ជំនាន់នុ៎ង។ បន្ទាប់មកគេជម្លៀសខ្ញុំ បញ្ជូនបន្តទៀតទៅខេត្តពោធិ៍សាត់។ ទៅខេត្តពោធិ៍សាត់មិនបានយូរទេកាលនុ៎ង ចូលរដូវភ្លៀងហើយ គឺភ្លៀងផងអីផងទៅ នៅនឹងផ្ទះគេហ្នឹង សុទ្ធតែ

ពួក១៧មេសា ឲ្យណែនហ្នង ណែនក្នុងផ្ទះហ្នឹង។ អាចម៍នោមអី ពេញកាំជណ្ដើរហ្នឹង គ្មាននរណាគេឃើញទេ វេទនាហួស។ បន្ទាប់មកទៀត បានរយៈពេលប្រហែលជា ពីរបីថ្ងៃ ខ្មែរក្រហមក៏បានយករថភ្លើងមកបញ្ជូនក្រុមគ្រួសារខ្ញុំ ក៏ដូចជាប្រជាជន១៧ មេសា ដទៃទៀត ឆ្ពោះទៅស្រុកស្វាយស៊ីសុផុន។ ទៅដល់ស្វាយស៊ីសុផុន គេដាក់យើងចុះក្នុងស្រុកស្វាយស៊ីសុផុន តែខ្ញុំមិនស្គាល់ថានៅម្ដុំណាៗទេ ដឹងថាជាប់រ៉ារទេះភ្លើង។ ដេកបាន ស្នាក់បានមួយយប់ ព្រឹកឡើងគេយកត្រាក់ទ័រ ត្រាក់ទ័រហ្នឹងមួយក្បាលគេមានរ៉ឺម៉កពីរ។ បាទ គេដឹកក្រុមគ្រួសារខ្ញុំហ្នឹង ក៏ដូចប្រជាជន ១៧មេសានៅទីក្រុងភ្នំពេញហ្នឹង ឡើងលើត្រាក់ទ័រហ្នឹង។ ត្រាក់ទ័រច្រើនណាស់ បើយើងឡើងទៅប៉ះត្រាក់ទ័រខាងព្រះនេត្រព្រះទៅ គឺទៅនៅព្រះនេត្រព្រះ។ បើយើងឡើងត្រាក់ទ័រប៉ះនៅភ្នំស្រុក យើងនៅភ្នំស្រុក។ បើយើងឡើងត្រាក់ទ័រពួកថ្មពួកយើងនៅថ្មពួក ក៏ប៉ុន្តែក្រុមគ្រួសារខ្ញុំឡើងទៅប៉ះត្រាក់ទ័រស្រុកភ្នំស្រុក បាទ។ អ៊ីចឹង ខ្ញុំឡើងទៅគេទម្លាក់ខ្ញុំនៅស្រុកភ្នំស្រុក ត្រាក់ទ័រហ្នឹង បាទ។

[០៩:២០:៤៨]

បន្ទាប់មកទៀត គេមានរទេះគោគេ រទេះគោពួកមូលដ្ឋាន គេមកដឹក បាទមកដឹកប្រជាជន ១៧មេសាហ្នឹង មានចិន មានខ្មែរ មានអីហ្នឹង ចិនកាត់ខ្មែរហ្នឹង ចម្រុះ។ ខ្ញុំជិះប៉ះរទេះគោ ចំរទេះគោឃុំណាំតៅ ភូមិសំរោង បាទ ចុងកាត់ចុងស្រុកហើយ សំរោងហ្នឹង។ ពេលនោះ ខ្ញុំនៅជាកងកុមារទេ គេឲ្យខ្ញុំធ្វើជាកងកុមារ។ ពេលនោះ ខ្ញុំហ្នឹងគេឲ្យ ខ្ញុំរើសអាចម៍គោ ដើររើសអាចម៍គោឲ្យគេបានមួយថ្ងៃ ៨០គីឡូ ទៅ ១០០គីឡូ។ គេថាំថ្លឹងនៅអន្លង់ហ្នឹងតែម្ដង ថាំថ្លឹង មានអន្លង់គេធំណាស់ អន្លង់ហ្នឹង គេថាំថ្លឹងឲ្យខ្ញុំរើសអាចម៍គោហើយបាន ១០០គីឡូ – ៨០គីឡូ ទៅ ១០០គីឡូ បាទ។ ហើយដណ្ដើមគ្នា ឃើញគោជុះអាចម៍មកធ្លាក់មិនទាន់ទេ យកបង្គីទៅត្រង បាទដើម្បីកំណត់គីឡូឲ្យគេ។

បន្ទាប់មកទៀត អ៊ីចឹង គេឲ្យយើងទៅនៅទួលមួយទៀត គេហៅថា "គុកតាសៀវ" គុកហ្នឹងហៅ គុកតាសៀវ។ ទួលហ្នឹងទួលអ្នកតា ទួលព្រៃខ្មោចអីហ្នឹង ឲ្យយើងទៅនៅហ្នឹង កងកុមារហ្នឹង។ កុមារហ្នឹងកុមារមិនតូចៗប៉ុន្មានទេធំៗដែរ ប្រហ៊ែខ្ញុំហ្នឹងធំៗដែរហ្នឹងមិនតូចទេ កុមារហ្នឹង សុទ្ធតែពួក ១៧មេសាទាំងអស់។ គេឲ្យខ្ញុំហ្នឹងលើងគល់ កាប់ព្រៃឫស្សី ឆ្ការព្រៃដើម្បីដាំដំឡូងមី ដាំដំឡូង ដាំបន្លែ នៅក្នុងគុកតាសៀវហ្នឹង។

ពេលឆ្នាំហ្នឹងគឺថា ចូលដល់ឆ្នាំគេធ្វើបាបពួកកុមារមាំណាស់។ ខ្ញុំមិនដែលស្គាល់កាប់ឫស្សីរបៀបម៉េចទេ។ ពេលជំនាន់ហ្នឹងគេឲ្យខ្ញុំកាប់ កាប់ឫស្សីព្រៃៗមិនត្រឹមតែកាប់ទេ ឲ្យលើងឫសទៀត ឲ្យ

លើងទាំងអស់ ឲ្យលើងទាំងឫស ដើម្បីទៅជាចម្ការ ចម្ការទៅជាភូមិ ដើម្បីដាក់ពួក១៧មេសា បាទ ចម្ការហ្នឹង។ ហើយធ្វើការគ្មានពេលកំណត់។ ប្រើយើងអត់ដឹងថាភ្លៀង មិនថាផ្គរ មិនថារន្ទះ មិនថាក្ដៅ មិនថាត្រជាក់។ ប្រើយើងឲ្យធ្វើហ្នឹង បាទ។

[០៩:២៣:៥២]

ហើយចំណែកការហូបចុករបស់គេវិញ គឺឲ្យយើងហូបមួយកំប៉ុងគ្នា ១០នាក់ របបគេឲ្យ។ មុនដំបូងគេឲ្យមួយកំប៉ុង ១០នាក់។ បបររាវ ឃើញអង្ករមួយៗទេ មួយកំប៉ុង១០នាក់។ បន្ទាប់មកទៀត មួយកំប៉ុង ២០នាក់។ បន្ទាប់មកទៀត មួយកំប៉ុង ៣០នាក់។ ប៉ុន្តែ មួយកំប៉ុង ៣០នាក់នោះ គេចាប់ផ្ដើមលាយត្រកួនហើយ ចាប់ផ្ដើមលាយត្រកួន។ គេចិញ្ច្រាំត្រកួនហ្នឹងដាក់ជាមួយបបរហ្នឹង។ គេចិញ្ច្រាំត្រកួនហ្នឹងដាក់ជាមួយអង្ករមួយកំប៉ុងទៅ ហើយមួយកងកុមារហ្នឹង ៣០នាក់ហ្នឹង ដាក់ឲ្យហូបទៅ ចាក់ចូលពាង ក្នុងពាង ហើយវែកគេដួសឲ្យ មួយវែកៗ វែកត្រឡោកគេហ្នឹង ត្រឡោកដូងហ្នឹង គេកាប់គេធ្វើជាវែកហ្នឹង ដួសឲ្យយើងមួយវែកៗម្នាក់ បាទ។ រហូតដល់ដាច់ យូរទៅដាក់របបអង្ករហ្នឹង មួយកំប៉ុង ៣០នាក់ហ្នឹង ដាច់ប៊ិតទៀត។ ហ្នឹងគេចាប់ផ្ដើមយកកន្ទក់ឲ្យយើងម្ដងហើយ យកកន្ទក់ឲ្យយើងហូបម្ដងហើយ កន្ទក់។ គេដឹកមកកន្ទក់ហ្នឹង កន្ទក់នោះខារ ធុំក្លិនខារ ដង្កូវព័ទ្ធដោយដង្កូវទៀត កន្ទក់ហ្នឹងគ្រាន់តែធុំក្លិនខ្ញុំចង់ក្អួត ប៉ុន្តែបំណាច់ឃ្លានគេបើកឲ្យហើយ បើយើងមិនហូបគឺស្លាប់។ គឺមុន នឹងហូបយកទៅលាងសិន លាងអីចឹងហើយបានយកមកខ្ចប់ស្លឹកចេក ខ្ចប់ស្លឹកចេកហើយបានយកមក អាំង ចម្អិនបានៗយកមកហូបទៅ ហូប។ ពេលនោះហើយដែលមានជំងឺកើតឡើងទៅជាជំងឺហើម គ្រុនចាញ់ បាទ ជំងឺហើម គ្រុនចាញ់ ចាប់ផ្ដើមស្លាប់បណ្ដើរៗបន្តបន្ទាប់ ស្លាប់ ចាប់ផ្ដើមស្លាប់ហើយ ពេលនោះ ហើម។ ហើយគ្មានថ្នាំទេ ព្យាបាល គ្មានហៅយើងទៅមន្ទីរពេទ្យ ថាទៅ "ឈឺហើយទៅមន្ទីរពេទ្យ" អត់មានទេៗ គឺថាយើងគ្រុនអីចឹងគេយកថ្នាំមកឲ្យយើងគឺអាចម៍ទន្សាយសុទ្ធ ចុកពោះក៏អាចម៍ទន្សាយ ឈឺក្បាលក៏អាចម៍ទន្សាយ គ្រុនញាក់គ្រុនញ័រក៏អាចម៍ទន្សាយថ្នាំគេគឺ ថ្នាំគេ បែបពូកែបែប បានគេឲ្យថ្នាំអីចឹងមកឲ្យយើងផឹក។

បាទ ខ្ញុំមានការឈឺចាប់ខ្លាំងណាស់ដល់ពេលធ្វើបានខ្លាំងៗពេក ធ្វើបាបខ្ញុំខ្លាំងពេក។ ហើយខ្ញុំរស់នៅតែម្នាក់ឯងគ្មានបងប្អូនណានៅជាមួយខ្ញុំទេ។ បងខ្ញុំគាត់នៅសហករណ៍ គាត់ខាងដកស្ទូង ខាងដកខាងស្ទូងទៅ បងស្រីហ្នឹង ហើយចំណែកខ្ញុំនៅផ្សេងទៅអត់បាននៅជាមួយគាត់ទេ គឺថារស់បែកគ្នា។

[០៩:២៧:៣៣]

ដោយមានការៗធ្វើបាបខ្លាំងពេក ខ្ញុំក៏សុខចិត្តៗ ដាច់ចិត្តទៅចូលធ្វើជាកងចល័ត ដើម្បីបាន -- ឃើញខាងចល័តគេបានបបរៗហូប ហើយខ្ញុំខាងកុមារនេះហូបកន្ទក់ ក៏សុខចិត្តទៅធ្វើជាកងចល័តៗ នៅអាងត្រពាំងថ្ម។ ខ្ញុំរស់នៅក្នុងអាងត្រពាំងថ្ម ក្នុងចំណោមចល័តមានតែខ្ញុំទេក្មេងតូចជាងគេ ហើយគេ បានសួរខ្ញុំថា "មិត្តឯងធ្វើកងចល័ត លោកឯង មិត្តឯង ធ្វើបានដែរឬអត់?" ខ្ញុំថា "ធ្វើបាន"។ បន្ទាប់មក គេឃើញនៅក្មេងអ៊ីចឹង គេឲ្យរទេះខ្ញុំមួយ គោខ្ញុំមួយនឹម សម្រាប់ដឹកអុសឲ្យចុងភៅដាំបាយ។ បាទ ខ្ញុំដឹង តែព្រឹកឡើងបររទេះគោ កាំបិតមួយទៅកាប់អុសឲ្យគេ ដាំបាយ ឲ្យកងចល័ត។ បន្ទាប់មកទៀតមានគេ ច្រណែននឹងខ្ញុំ កោសរូសនឹងខ្ញុំ ខ្ញុំក៏បានទៅរែកដីនឹងគេ ចាប់ផ្តើមរែកដីនឹងគេហើយនៅពេលនោះ តែខ្ញុំ ក្មេងខ្ញុំកាប់អត់កើតទេ កម្លាំងខ្សោយកាប់ដីរឹងអត់កើតទេ បានតែរែកទេ ខ្ញុំរែករហូត បាទ រែករហូត រែក គេកំណត់ឲ្យយើងរែក។ ពេលនោះហើយខ្ញុំទៅជាបាក់កម្លាំងរែកខ្លាំងពេកទៅជាបាក់កម្លាំង ខ្ញុំឈឺ គ្រុន ខ្ញុំគ្រុនៗហ្នឹងគ្រុនលស់ទៀត អាគ្រុនពេលហ្នឹង ចាប់ផ្តើមដល់ម៉ោងវាគ្រុនៗ តែអត់ហ៊ានឈប់ទេ ពេលគ្រុនហ្នឹងអត់ហ៊ានឈប់ទេ ដល់ស្វាងគ្រុនទៅធ្វើការវិញ ខ្លាចថ្នាក់លើគេចាប់កំហុស ខ្លាចគេថា យើងធ្វើពុត ព្រោះយើងគ្រុន យើងហូបបាយបាន ហូបបបរបាន គេមានទ្រឹស្តីគេមួយ ជំនាន់នោះគេមាន ទ្រឹស្តីគេថាអ៊ីចេះ ដល់យើងហូបបាយបាន គេមានទ្រឹស្តីគេថាអ៊ីចេះបានខ្ញុំខ្លាច គេថា "គ្រុនញាក់គ្រាន់ ញ័រ គ្រុនអាត្រាក់ទ័រ គ្រុនឡាន គ្រុនបាយបាន គ្រុនសតិអារម្មណ៍" ភាសានេះហើយដែលឲ្យខ្ញុំខ្លាច ខ្ញុំ ខ្លាចភាសាហ្នឹង។ តែយើងហូបបាយបាន គឺថាយើងគ្រុនសតិអារម្មណ៍។ បាទ ខ្ញុំអត់ភ្លេចទេភាសា សុភាសិតរបស់ជំនាន់នោះ សុភាសិតរបស់គេនោះ គេថាអ៊ីចឹង ខ្ញុំខ្លាច។ អ៊ីចឹងបានខ្ញុំខំប្រឹងៗធ្វើទាំងៗ ឈឺទាំងជាដើម្បីជីវិតៗ ប៉ុន្តែជំនាន់នោះខ្ញុំមិននឹងស្មានថាខ្ញុំបានរស់នៅ រស់រៀនដល់សព្វថ្ងៃទេ ខ្ញុំគ្មាន រំពឹងទេ ដឹងតែរស់ថ្ងៃនេះមួយថ្ងៃ ស្អែកមិនដឹងយ៉ាងម៉េច ខ្ញុំអត់ដឹងទេ អត់ដឹងថាខ្លួនឯងស្អែករស់ មិនរស់ អត់ដឹងៗទុកជាមុន អត់ដឹង។ មិនដឹងឈឺស្លាប់ ឬមួយមិនដឹងយើងនិយាយខុស គេយកទៅសម្លាប់ក៏ យើងមិនដឹង ប៉ុន្តែខ្ញុំខ្លាចណាស់ មិនហ៊ាននិយាយស្អីទាំងអស់ ចាត់ទុកដូចជាមនុស្សគអ៊ីចឹង អត់ហ៊ាន និយាយអីទាំងអស់។ បងខ្ញុំផ្តែផ្តាំថា អ្នែងកុំនិយាយអីឲ្យសោះណា ផ្តេសផ្តាសឲ្យសោះ ធ្វើដឹងតែធ្វើទៅ គេប្រើអីធ្វើហ្នឹងទៅ កុំចេះនិយាយពីសង្គមចាស់ យើងគ្រួសារយើងអ៊ីចេះម៉េច អ៊ីចុះម៉េច កុំចេះនិយាយ បាទអត់និយាយបានទេ។ ខ្ញុំអត់ហ៊ាននិយាយ។

[០៩:៣៣:១២]

ធ្វើការឲ្យគេជំនាន់នោះ គឺថាធ្វើៗខ្លាំងមាំណាស់ ធ្វើគឺអាងទំនប់ត្រពាំងថ្មអ៊ីចឹង ចាត់ទុកជា

សមរភូមិក្តៅមួយហើយជំនាន់នោះ សមរភូមិក្តៅ។ ធ្វើមិនដឹងថាភ្លៀង មិនដឹងថាក្តៅ វន្ទះផ្គរវន្ទះ អត់មានគិតអ៊ីចឹង គិតតែដល់ម៉ោងចេញធ្វើៗ។ ព្រឹកឡើងគឺម៉ោងបួនហ្នឹង ម៉ោងបួន ម៉ោងប្រាំហ្នឹង គឺចាប់ផ្តើមគោះហើយ ហៅហើយ ស្រែកហៅហើយ ហៅៗឡើងធ្វើការ។ ពេល*(ឮមិនច្បាស់)* កាប់គឹកគាក់ៗអ៊ីចឹងទៅ ឮតែស្នូរចប អត់ឃើញមនុស្សទេ ពេលដែលធ្វើហ្នឹង ពេលព្រឹកហ្នឹងអត់ឃើញមនុស្សទេ យើងមើលអត់ឃើញ ឮតែស្នូរចបទេ ឮតែស្នូរចប។ រហូតដល់ម៉ោងដប់មួយ បានគេឲ្យយើងសម្រាកៗ។ សម្រាកបាយបានមួយភ្លែត ប្រហែលជាម៉ោងមួយ គេឲ្យយើងចុះទៅធ្វើទៀត រហូតដល់ម៉ោងប្រាំល្ងាចៗ ប្រាំល្ងាចគេឲ្យឈប់សម្រាក។ អ៊ីចឹងទម្រាំយើងដើរដល់កន្លែងយើងសម្រាកហ្នឹងយូរដែរដើរមកដល់ ទម្រាំហូបបាយហើយក្រិសក្រុសៗ គឺដល់ម៉ោងគេទៀតហើយដល់ម៉ោងចុះទៀតហើយ ដល់ម៉ោងចុះអ៊ីចឹងទៅ ធ្វើទៀតទៅ ម៉ោងប្រាំឡើងទៅ។ ឡើងមកអ៊ីចឹងទៅ មកងូតទឹកងូតអី ហូបបាយ ហូបអីហើយអ៊ីចឹង ហូបបបរអ៊ីចឹងទៅ។ ម៉ោងប្រាំពីរ គេហៅចុះទៅធ្វើទៀតហើយ ទាំងយប់ហ្នឹង បាទ។ ធ្វើយប់ហ្នឹង ដល់ម៉ោងដប់បានគេឲ្យយើងមកសម្រាក គឺថាការងារជាទម្ងន់ ធ្វើបាប ចល័តត្រពាំងថ្ម ធ្វើបាបហួស គ្មានយកអ្វីប្រៀបធៀបមិនបាន។ ហើយរបបហូបចុករបស់គេ គេចែកបបរឈ្នាលហ្នឹងមួយចានចង្កឹះ គេវាល់ហើយ គេដាក់នឹងចានឲ្យយើង ដាក់ចានយើងហូប។

[០៩:៣៦:១២]

តែយើងខ្ញុំហូបអត់ឆ្អែតទេ អត់ឆ្អែតទេ ទុកបបរហ្នឹងសិន ដើររកបេះផ្ទី បន្លែបង្ការយកមកបន្ថែមដើម្បីឲ្យបានច្រើន។ ពេលនោះហើយ ខ្ញុំនឹកឃើញដល់ ស៊ិន ច័ន្ទឆាយា។ ស៊ិន ច័ន្ទឆាយា នេះ គឺរស់នៅកងចល័តជាមួយខ្ញុំផ្ទាល់ហើយ កូនលោក ស៊ិន ស៊ីសាមុត នេះ ស៊ិន ច័ន្ទឆាយា ហ្នឹង គាត់បាន -- ខ្ញុំអាល័យតែទៅបេះផ្ទីមកបង្គ្រប់ឲ្យបានឆ្អែត ឲ្យបានច្រើនហ្នឹង ស៊ិន ច័ន្ទឆាយា បានមកលួចរបបរបស់ខ្ញុំពាក់កណ្តាល បាទមកលួចរបបរបស់ខ្ញុំពាក់កណ្តាល ហើយខ្ញុំក៏យំ យំហើយ ខ្ញុំទៅប្រាប់មេកង ប្រាប់មេកង ប្រាប់ទៅ មេកងចាប់ ស៊ិន ច័ន្ទឆាយា វ៉ៃ។ បានខ្ញុំនឹកអនុស្សាវរីយ៍របស់ខ្ញុំ នឹកអាណិតគាត់ហួងមកដល់សព្វថ្ងៃនេះ។ ប៉ុន្តែរបបខ្មែរក្រហមជំនាន់នោះ គ្មានឲ្យយើងចេះស្រឡាញ់គ្នាទេ អត់មានចេះស្រឡាញ់គ្នាទេ អត់ចេះទេ។ ក្បាលអ្នកណា សក់អ្នកនោះ គ្មានចេះស្រឡាញ់គ្នា គ្មានចេះជួយគ្នាទេ គឺរែក៣ម៉ែត្រគូប ៣ម៉ែត្រដូចគ្នា ២ម៉ែត្រ ២ម៉ែត្រដូចគ្នា។ វាគ្មានឲ្យយើងចេះសាមគ្គីគ្នាទេ អត់ទេ។ បើអ្នកឯងធ្វើមិនហើយ គេកាត់របប។ ទី១ ហៅមកទិតៀន ស្វ័យទិតៀនគ្នា។ ពេលនោះ គេហៅថាទិតៀន និងស្វ័យទិតៀន ប្រជុំគ្នាទិតៀនគ្នាទៅ ឲ្យលោកឯងខំ ខំប្រឹង ជូនអង្គការៗ។

ពេលនោះ ខ្ញុំឈឺ ឈឺគ្រុន គ្រុនគ្មានអ្វីទេ គ្មានថ្នាំអ្វីទេ គ្នាថ្នាំសង្កូវអ្វីទេ គេឲ្យអាចម៍ទន្សាយ ក្បាលជង្គង់ខ្ញុំក្បាលឡើងត្រមោងៗ ក្បាលឡើងត្រមោងៗ សក់ឡើងកន្ទ្រើង សក់។ យើងមើលគេ យើងខ្លាចគេ គេមើលយើង គេខ្លាចយើង ព្រោះយើង គ្មានអ្នកណាមានសាច់ឈាមទេ ស្គេកស្គាំងៗ ហើយយើងឈឺគ្រុនញាក់ គ្រុនញ័រហ្នឹង គ្មានអ្នកមកជួយច្រូចបាច់អីណា មកជួយយើងទេ វាអស់ចិត្តវាបាត់ឯងវាអស់ឯង។ គេហៅថាគ្រុនដឹងពេលអាហ្នឹង ពេលហ្នឹង គ្រុនដឹងពេល។ ជំនាន់នោះខ្លួនខ្ញុំ សូម្បីតែអាវខ្ញុំខោខ្ញុំ ចៃឲ្យពេញខ្លួន ផ្អេះផ្អាប ដើរទៅជិតគេ ក៏គេថាដែរ ផ្អេះផ្អាប យើងទៅជិតគេ ក៏យើងថាគេដែរ ផ្អេះផ្អាប គឺចៃសាច់ចេញពេញខ្លួនហ្នង។ នៅតាមចង្កេះខោហ្នឹង កៅស៊ូខោហ្នឹងនៅជាប់នឹងចៃសៗស្កុះ គឺថាគ្មានទេ គ្មានពេលណាសម្អាត គ្មានសាប៊ូអីណា គ្មានអីណាដុស សូម្បីងូតទឹកសឹងតែរកពេលងូតទឹកមិនបានផង។

[០៩:៤០:០៣]

សូម្បីយើងដេកហ្នឹង យើងយកបង្គីធ្វើខ្នើយ បង្គីដែលយើងរែកដី យើងធ្វើជាខ្នើយ។ ចបដែលយើងកាប់ហ្នឹង ធ្វើជាខ្នើយឱប កល់ជើង កល់ដៃ។ ដេកនឹងដី ដេកផ្ទាល់ដី។ ការឈឺចាប់របស់ខ្ញុំ ខ្ញុំខឹងជំនាន់នោះ គឺថាគេធ្វើបាបសម្បើមណាស់ ពួក១៧មេសានេះ។ គេស្អប់ពួក១៧មេសាតែម្តង។ គេថាពួកសក្តិភូមិ ពួកនាយទុន។ មកតែមួយចង្កេះទេមក អត់យកអីមកតាមទេ។ គេថាយើងអ៊ីចឹង។ ចុះអ្នកណាយកអីទៅតាម បើអស់លោកឃោសនាថាតែបីថ្ងៃ។ តែ៣គីឡូម៉ែត្រចេញពីទីក្រុងភ្នំពេញ។ មានអ្នកណានឹកថាយកអីទៅតាម។ តែមួយចង្កេះផ្អេះនឹងខ្លួន ច្រើនមានតែពីរកំប្លេតែប៉ុណ្ណោះ។ ធ្វើការ គ្មានពេលសម្រាក ភួយក៏គ្មានដណ្តប់។ ខែកត្តិកដឹងតែបំពក់ភ្នក់អាំង ជួនណាឆេះអស់បាវពោះខៀវហ្នឹង យកមកក្រាលដេក។ ជួនណា ភ្លើងមក អាកម្មេចភ្លើងហ្នឹងមកទៅ ឆេះទៅ។ រងា។ គ្រុនក៏អាំងភ្លើង អ្នកខ្លះគ្រុនអាំងភ្លើងទៅ ស្លាប់នឹងភ្នក់ភ្លើងក៏មានដែរ។ អាហ្នឹង គ្រុនអាំងភ្លើង។ គ្មានយកចិត្តទុកដាក់ថ្នាំពេទ្យឲ្យយើងទេ គឺថាមានតែថ្នាំអាចម៍ទន្សាយតែប៉ុណ្ណោះ។ ឈឺអីក៏អាចម៍ទន្សាយៗ។ គ្មានថាថ្នាំអាចម៍ទន្សាយដាក់ស្លាកនេះ ស្លាកនោះ អត់មានទេ។

[០៩:៤២:៣៣]

**សះ** បាទ ខ្ញុំសូមបន្តសំណួរបន្តិច ថាតើលោកបានលើកឡើងថា លោកនៅជាកងកុមារទេ ហេតុអីបានជាគេបញ្ជូនទៅកងចល័តនៅត្រពាំងថ្មកើត ព្រោះយើងនៅជាកុមារ?

**ឆះ** បាទ អរគុណលោកមេធាវី។ ខ្ញុំនៅជាកងកុមារ ដូចខ្ញុំប្រាប់ខាងដើមហើយ ថាខ្ញុំទ្រាំហួប

កន្ទក់អត់បាន។ បបរមួយកំប៉ុង៣០នាក់ លាយតែត្រកួន រហូតដល់ដាច់ ឲ្យកន្ទក់ខ្ញុំហូប ខ្ញុំហូបអត់បាន។ ម៉្លោះហើយ ក៏ខ្ញុំដាច់ចិត្តទៅធ្វើការឲ្យស្មើនឹងគេមនុស្សធំ ដើម្បីបានបបរឈ្មោលហូបតែប៉ុណ្ណោះទេ លោកមេធាវី។

**ស៖** បាទ។ ចុះនៅពេលដែលលោកទៅដល់ការដ្ឋានដំបូង តើគេបែងចែកឲ្យលោកហ្នឹងធ្វើការស្មើគេដែរ ឬមួយយ៉ាងណា?

**ឆ៖** បាទ អរគុណ។ ការងារកងចល័ត គឺថាយើងគ្មានថាតូច គ្មានថាធំទេ។ ការងារបែងចែកស្មើគ្នា។ បែងចែកស្មើគ្នា។ បើយើងធ្វើឲ្យគេមិនគ្រប់ទេ គេនឹងកាត់របបយើង។ ក្នុងក្រុមនោះគេកាត់របបយើង។ ទោះបីមួយចុងស្លាបព្រាក៏ដោយ មួយស្លាបព្រាក៏ដោយ គេកាត់ពីយើងទៅឲ្យអ្នកធ្វើការហើយនោះ គេទៅឲ្យអ្នកដែលធ្វើការជាមួយយើងនោះ ដាក់បន្តិចៗទៅ ឲ្យម៉េចឲ្យដាច់ពាក់កណ្តាលរបបយើង។ ហើយពេលនោះខ្ញុំមកហើយ អង្គុយយំ។ ចុះខ្ញុំនៅតូចជាងគេ ខ្ញុំអង្គុយយំៗ។ តូចចិត្តខ្លួនឯងធ្វើអត់ហើយ។ ក៏ប៉ុន្តែយូរៗទៅ ខ្ញុំធ្វើដូចគេដូចឯងអីចឹង ដូចគេដូចឯង។ អ្នកឯងធ្វើបានប៉ុន្មាន ខ្ញុំធ្វើបានប៉ុណ្ណឹង ដូចគ្នា ធ្វើបានដូចគ្នា។ ខ្ញុំសូមនិយាយសាក្រោយបន្តិចចុះ ខ្ញុំភ្លេចនិយាយកាលខ្ញុំនៅកុមារ។ ខ្ញុំឃ្លានខ្លាំងណាស់ៗ អត់អីស៊ី។ ពេលដែលថាមួយកំប៉ុង៣០នាក់នោះ ខ្ញុំដាច់ចិត្ត ដើររើសឆ្អឹងត្រីរបស់មូលដ្ឋាន។ រើសឆ្អឹងត្រីខ្ញុំណា និយាយឥតខ្មាស់ ខ្ញុំដើររើសឆ្អឹងត្រីរបស់មូលដ្ឋាន គេស៊ីហើយ សាច់ហើយគេបោះឆ្អឹងចោល ខ្ញុំរើសមកស៊ី។ កង្កែបគេកាត់ក្បាល គេលាត់ចោលស្បែក ខ្ញុំរើសមកស៊ីទៀត។ យកមកស្ងោរស៊ី គឺថាទុក្ខសោករបស់ខ្ញុំយកអ្វីមកប្រៀបធៀបអត់បានទេជំនាន់នោះ។ ហើយខ្ញុំជាអ្នក១៧មេសា ខ្ញុំមិនដែលទៅហូបអីរបស់អីចឹងៗ។ ដើររើសឆ្អឹងត្រីរបស់មូលដ្ឋាន គេហូបហើយ គេបោះចោល។ ទឹកបាយគេជាត់ហើយយកចានទៅត្រង យកឆ្នាំងដាក់ត្រង គេជាត់ចោលសោះ របស់គេចោលសោះ រហូតគេស្តីឲ្យយើងទៀត។ គេថា យើងស៊ីអាក្រក់មាំម៉្លេះរបស់គេចោលហ្នឹង។ គេថាឲ្យយើងអីចឹងទៀត។ បានខ្ញុំដាច់ចិត្តទៅធ្វើជាកងចល័តបាទ។

[០៩:៤៦:២៥]

**ស៖** ចុះនៅពេលដែលលោកមកកងចល័តហ្នឹងហើយ មានការទំនាក់ទំនងអ្វីទៅក្រុមគ្រួសារបានទេ?

**ឆ៖** បាទ ពេលខ្ញុំមកនៅជាកងចល័តនេះ អត់មានពេលទៅជួបបងបានទេ។ មានទៅជួបបានម្តង ខ្ញុំសុំគេទៅៗ ទៅពេលល្ងាច ព្រឹកឡើងខ្ញុំមកវិញ ទៅជួបបង។ ហើយបងណែនាំខ្ញុំថា កុំនិយាយអី

ផ្តេសផ្តាស ចេះតែធ្វើទៅ គេប្រើអីធ្វើហ្នឹងទៅ កុំនិយាយអីផ្តេសផ្តាស គាត់គ្រាន់តែផ្តែផ្តាំខ្ញុំប៉ុណ្ណឹង។ គ្មានបានជួបជុំគ្នាទេ គ្រាន់តែជួបគាត់មួយភ្លែត គាត់ក៏ទៅធ្វើការទៅ ខ្ញុំមកវិញមក អត់ប៉ានទៅយូរទេ បាទ។

**ស៖** ចុះចំពោះពេលដែលលោកនៅកងចល័តហ្នឹងហើយ បានជួបប្រទះនូវព្រឹត្តិការណ៍ណាផ្សេងៗទៀតដែលធ្វើឱ្យលោកទទួលការឈឺចាប់ខ្លាំង?

**ឆ៖** បាទ ខ្ញុំនៅកងចល័តៗ ពេលដែលព្រឹត្តិការណ៍កើតឡើង គឺមានច្រើនដែរ ច្រើន ដូចជា គេយកមនុស្សទៅសម្លាប់ យកទៅសម្លាប់។ តែពេលនោះ ខ្ញុំអត់ដឹងថាគេខុសអីទេ ខ្ញុំអត់ដឹងដែរ។ គ្រាន់ថាគេយកទៅសម្លាប់ ហើយពេលយើងទៅធ្វើការយប់ម៉ោងប្រាំពីរយើងចេញទៅអស់ហើយ ស្ងាត់អស់រោង។ មានអ្នកគេដើរមកមើលក្នុងរោង តាមរោងទៀត តើមានអ្នកណានៅក្នុងរោងខ្លះបាទ។ គេដើរមើលតាមរោងហ្នឹងអ៊ីចឹង។ អ៊ីចឹងមានអ្នកគ្រុន មានអ្នកឈឺ មានអ្នកខ្ជាក់មាន់ ពេលនោះ ខ្ញុំតែអ្នកខ្ជាក់មាន់ទេ ខ្ញុំដឹង។ អ្នកខ្ជាក់មាន់អ៊ីចឹង គេយក -- គេដឹកដៃៗឱ្យចូលទៅបង្គន់អាចម៍ គេពិសោធយើងយកទៅពិសោធ។ គេដឹកដៃអ៊ីចឹង គេមានលុងសាំងគេហ្នឹង គេកាត់ជាលុងសាំង គេដាក់ឈើឱ្យយើងហើយ គេយកបារហ្នឹងវ័ណ្ឌអ៊ីចឹង ឱ្យយើងបត់ដៃបត់ជើងក្នុងបង្គន់ហ្នឹង។ អ៊ីចឹងការដកពិសោធរបស់គេ គេយកពួកខ្ជាក់មាន់ហ្នឹង ដឹកដៃគ្នាអ៊ីចឹងឱ្យដើរឆ្លងកាត់បង្គន់។ អ៊ីចឹងអ្នកដែលមិនខ្ជាក់មាន់ធ្វើជាខ្ជាក់មាន់ដល់មាត់បង្គន់នោះគឺហាក់ខ្លោ ហាក់ហួសបង្គន់ហ្នឹង ក៏ប៉ុន្តែអ្នកដែលខ្ជាក់ពិតប្រាកដធ្លាក់ភ្លូកត្រឹមភ្លៅ។ បាទធ្លាក់ចូលក្នុងបង្គន់ត្រឹមភ្លៅអ៊ីចឹងទៅ។ បាទ ធ្លាក់អ៊ីចឹង រួចខ្លួន ហ្នឹងហើយរួចខ្លួន។ អត់អីទេអាហ្នឹងពិតប្រាកដ ក៏ប៉ុន្តែអ្នកដែលមានពុតត្បុតនឹងអង្គការ គឺបាត់ខ្លួននៅពេលហ្នឹង បាត់ខ្លួន។ ប៉ុន្តែគ្រាន់តែដឹងថាបាត់ខ្លួន នៅពេលណាទេខ្ញុំអត់ដឹងទេ ខ្ញុំអត់បានតាមដានទេ គេយកទៅម្តងមួយៗ។ គឺបាត់ខ្លួន បាត់អត់ដឹងថាគេយកពីថ្ងៃរម៉ាន ថ្ងៃណាអីហ្នឹង អត់ដឹង។ គឺថាធ្វើការជាមួយ ដឹងបាត់ៗអ្នកហ្នឹងមួយហ្នង បាទ។

**ស៖** ចុះតើចំពោះអ្វីដែលបានជួបប្រទះហ្នឹងធ្វើឱ្យអារម្មណ៍លោកយ៉ាងដូចម្តេចដែរនៅពេលហ្នឹង?

**ឆ៖** បាទ អរគុណ។ ជំនាន់នោះអារម្មណ៍របស់ខ្ញុំគឺថាមានការរន្ធត់ៗណាស់ មានការរន្ធត់។ ឃើញគេយកទៅបាត់ៗៗអ៊ីចឹងទៅ ដូចមានការភ័យៗយកតែមែនទែន ភ័យខ្លាចថាខ្លួនឯង ភ័យដល់ខ្លួនឯង។ ប៉ុន្តែខ្ញុំវាមានភ័ព្វសំណាងខ្ញុំ ដល់ខ្ញុំជំនាន់នោះ ខ្ញុំអត់មានខ្ជាក់មាន់នឹងគេ អត់បានខ្ជាក់មាន់នឹងគេ។

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

បានតែជំងឺគ្រុនចាញ់ មានតែជំងឺគ្រុនចាញ់តែមួយមុខ និងហើម។ ខ្ញុំហើម ខ្ញុំកើតជំងឺហើម និងគ្រុនចាញ់ នៅខ្មែរក្រហម។ បាទ កើតជំងឺហើមៗជើងដ៏ស្ពឹង។ ដើរទៅអន្ទិលៗៗ ដូចយើងពាក់ស្បែកជើង អាស្បែកជើងច្រកទឹកចូលអ៊ីចឹង ដើរទៅអន្ទិលៗៗអ៊ីចឹង។ ចុច យកដៃចុចអ៊ីចឹងទៅ ចុចប៉ុន្មានទ្រុឌប៉ុណ្ណឹងដៃយើងចុចៗៗអ៊ីចឹង ទ្រុឌប៉ុណ្ណឹង ចុចទៅ ហ្នឹងហៅជំងឺហើមហ្នឹង។ មុខយើងហើមស្ពឹង យកដៃចុចអ៊ីចេះទេ ទ្រុឌអ៊ីចឹងទៅ បាទ។ អាហ្នឹងជំងឺហ្នឹង មានតែពីរមុខហ្នឹង ខ្ញុំកើតជំងឺជំនាន់ខ្មែរក្រហម។

[០៩:៥២:២៧]

**ស៖** តើគេបានមានគ្រូពេទ្យអីទៅព្យាបាលយើងទេ?

**ឆ៖** បាទ ជំនាន់នោះ គ្មានគ្រូពេទ្យ អត់មានគ្រូពេទ្យទេៗៗទៅថែមើលយើងទេ។ បើយើងសុំថ្នាំគេបាន សុំថ្នាំគេៗឲ្យតាមរយៈមេក្រុមអីទៅ គេឲ្យយើង យកមកឲ្យយើងទៅ។ គឺគ្មានថ្នាំពេទ្យទេ គឺថ្នាំអាចម៍ទន្សាយហ្នឹង ដូចខ្ញុំថាអ៊ីចឹង។ ហើមក៏អាចម៍ទន្សាយ គ្រុនក៏អាចម៍ទន្សាយ គឺថាចម្រុះថ្នាំគេពូកែណាស់។ ពូកែមែនថ្នាំនោះ បាទ។

**ស៖** ខ្ញុំសូមត្រឡប់ទៅក្រោយបន្តិច តាមបទពិសោធន៍របស់លោក កាលពីលោកនៅកុមារហ្នឹង ក្នុងកងចល័តកុមារ ឬមួយ -- តើមានការបណ្ដុះបណ្ដាលរៀនសូត្រអីទេ?

**ឆ៖** បាទ អរគុណលោកមេធាវី។ ជំនាន់នោះខ្ញុំមិនដែលមានការបណ្ដុះបណ្ដាលកុមារទេ ខ្ញុំមិនដែលឃើញទេ ខ្ញុំមិនដែលឃើញឲ្យកុមាររៀនសូត្រទេ។ មានតែឲ្យកុមារសូត្រខាងកាប់ទន្ទ្រានខែត្ររើសអាចម៍គោ មាន។ បើថាឲ្យចូលសាលារៀន គឺគ្មានៗ។

**ស៖** បាទ ហើយខ្ញុំសូមត្រឡប់ទៅក្រោយបន្តិចមួយទៀត។ លោកថាមានពេលដែលជួបបងស្រីនៅភូមិនោះ គាត់ថា “កុំនិយាយឲ្យសោះ កុំនិយាយពីរឿងប្រវត្តិខ្លួនឯង ខ្លាច”។ តើគាត់ផ្ដាំផ្ញើហ្នឹង មានមូលហេតុអីដែរឬទេ?

[០៩:៥៥:០០]

**ឆ៖** បាទ អរគុណ។ ព្រោះគាត់ជាអ្នកចេះដឹងមួយដែរ គាត់មានប្ដីគាត់ធ្វើជាទាហានដែរ ថ្នាក់ដឹកនាំមួយដែរជំនាន់លន់ នល់នោះ ប៉ុន្តែគាត់ឃើញគេយកអ្នកមានតួនាទីជំនាន់លន់ នល់នោះគេយកទៅសម្លាប់។ អ៊ីចឹង គាត់មិនឲ្យខ្ញុំនេះ ផ្ដែផ្ដាំខ្ញុំនេះ មិនឲ្យនិយាយផ្ដេសផ្ដាសពីរឿងពីសង្គម បងប្អូនធ្វើនេះៗ កុំនិយាយឲ្យសោះ ខ្លាចគេយកទៅសម្លាប់ទាំងគ្រួសារ ព្រោះមានគេយកទៅសម្លាប់ហើយ បានគាត់ផ្ដែផ្ដាំខ្ញុំ ហើយគាត់ហ្នឹងក៏រួចខ្លួនពីការស្លាប់ដែរ ព្រោះគាត់ហ្នឹង ប្ដីគាត់ហ្នឹងបែកបាក់គ្នា។ គាត់ធ្វើទាហាន

នៅអ្នកលឿង។ អ៊ីចឹងគាត់ក៏ផ្ដែផ្ដាំអ៊ីចឹងថា កុំឲ្យនិយាយការងារសង្គម បងប្អូនធ្វើអីៗ អ៊ំនេះធ្វើអីៗ កុំនិយាយឲ្យសោះ ខ្លាចគេយកយើងទៅសម្លាប់ បិទមាត់ទៅ កុំនិយាយ ការអីងារអីពីសង្គម កុំនិយាយឲ្យសោះ បាទ។

**ស៖** សំណួរខ្ញុំមួយទៀតថា តើពាក់ព័ន្ធនឹងសាច់ញាតិរបស់លោកក្នុងជំនាន់នោះ តើមានការបាត់បង់សាច់ញាតិណាម្នាក់ដែលជាទីស្រឡាញ់របស់លោកនៅសម័យនោះដែរឬទេ?

**ឆ៖** បាទ អរគុណលោកមេធាវី។ រឿងការស្លាប់របស់សាច់ញាតិក្នុងរបបខ្មែរក្រហមគឺថា អ៊ំខ្ញុំស្លាប់ផុតពូជ ទាំងគាត់ទាំងអ៊ំខ្ញុំ ទាំងប្រពន្ធគាត់ទាំងកូនគាត់ ស្លាប់ដាច់ពូជ មួយពូជតែម្ដង។ ចំណែកប្អូនម្ដាយខ្ញុំម្នាក់ទៀតគឺគាត់ធ្វើទាហានជំនាន់នោះគឺពាក់ស័ក្តិ៥ គឺយកគាត់ទៅសម្លាប់ទាំងពូជ គឺសល់តែម្នាក់ទេ សព្វថ្ងៃហ្នឹងសល់តែមួយទេមួយពូជហ្នឹង មួយពូជប្អូនម្ដាយរបស់ខ្ញុំគឺសល់កូនមួយ។ មួយពូជបងម្ដាយខ្ញុំនេះ គឺដាច់ពូជអស់ហើយ គ្មានទេ ស្លាប់អស់ បាទ។

[០៩:៥៨:២៥]

**ស៖** តើលោកមាននៅចាំទេថា មនុស្សសំខាន់ចំពោះលោកដែលបានចិញ្ចឹមបីបាច់លោកហ្នឹងត្រូវបានបាត់ខ្លួននៅក្នុងសម័យហ្នឹងដែរ តើជាអ្នកណាទៅដែលលោកបានលើកឡើងអម្បាញ់មិញ?

**ឆ៖** បាទ អរគុណលោកមេធាវី។ អ្នកចិញ្ចឹមបីបាច់ខ្ញុំតាំងពីតូចមកគឺម្ដាយរបស់ខ្ញុំ ក៏ប៉ុន្តែក្នុងឆ្នាំ១៩៦៩ អ៊ំខ្ញុំយកខ្ញុំមកចិញ្ចឹមនៅទីក្រុងភ្នំពេញនេះ ទាំងបងខ្ញុំ បងស្រីខ្ញុំ បងប្រុសខ្ញុំគឺគាត់ចិញ្ចឹមទាំងអស់ គាត់ចិញ្ចឹមឲ្យរៀនសូត្រនៅទីក្រុងភ្នំពេញទាំងអស់ គឺអ៊ំខ្ញុំអតីតគឺជារដ្ឋមន្ត្រី គឺ ថៅ សៅ ក្នុងរបបលន់នល់ គាត់ហ្នឹងហើយគឺជាបង្គោលដ៏ធំមួយចិញ្ចឹមបងប្រុសខ្ញុំ បងស្រីខ្ញុំ ឲ្យមានការរៀនសូត្រខ្ពង់ខ្ពស់ គឺអ៊ំនេះហើយ គឺខ្មែរក្រហមយកទៅសម្លាប់នោះហើយ។ ខ្ញុំមានការឈឺចាប់ខ្លាំងណាស់ដោយគាត់ស្លាប់ដោយគ្មានកំហុស បាត់ដល់សព្វថ្ងៃនេះ បងប្រុសខ្ញុំពីរនាក់ក៏បាត់ខ្លួនទៅជាមួយគាត់ បាត់រហូតដល់សព្វថ្ងៃ។

**ស៖** តើមកដល់បច្ចុប្បន្ននេះ ពេលដែលលោករំឭកទៅដល់រឿងរ៉ាវដែលបានឆ្លងកាត់នេះ តើក្នុងចិត្តរបស់លោក អារម្មណ៍របស់លោកទទួលនូវអារម្មណ៍យ៉ាងដូចម្ដេចដែរ?

**ឆ៖** បាទ អរគុណ។ ខ្ញុំសព្វថ្ងៃបាត់អ៊ំ បាត់ពូ បាត់បងជាទីពឹងរបស់ខ្ញុំ គឺថាខ្ញុំមានចិត្ត គឺមានចិត្តក្ដុកក្ដួលជាខ្លាំង ដោយបាត់គាត់ជាទីបង្គោលរបស់ខ្ញុំ បង្គោលរបស់ម្ដាយខ្ញុំ។ គាត់នេះហើយជាអ្នកបីបាច់ថែរក្សាក្រុមគ្រួសាររបស់ខ្ញុំ ចិញ្ចឹមបងខ្ញុំឲ្យមានការចេះដឹង ទីបំផុតរបបខ្មែរក្រហមបានយកគាត់

ទៅសម្លាប់រហូតដល់សព្វថ្ងៃ គឺថាខ្ញុំឈឺចាប់គ្មានយកវត្ថុអ្វីមកប្រៀបធៀបមិនបានទេ មិនបាន។ កុំតែរបបនោះហើយ បំផ្លាញអនាគតរបស់ក្រុមគ្រួសាររបស់ខ្ញុំ ខ្វះការអប់រំ បាទ ខ្វះការអប់រំ ការរៀនសូត្រ ធ្វើឲ្យខ្ញុំនេះមានការឈឺចាប់ខ្លាំងណាស់បាទ។

**ស៖** លោកអាចបញ្ជាក់ពីការឈឺចាប់មួយទៀត ថាតើនៅពេលដែលលោកបានធ្វើការនៅការដ្ឋានត្រពាំងថ្មនោះ មានការហត់នឿយខ្លាំងហើយ ៗថែមទាំងអត់អាហារគ្រប់គ្រាន់ទៀត តើនៅពេលនោះលោកបានគិតថាយ៉ាងដូចម្ដេចនៅពេលនោះ?

**ឆ៖** បាទ អរគុណលោកមេធាវី។ ខ្ញុំនៅកងចល័ត ធ្វើការធ្ងន់ ហូបមិនគ្រប់គ្រាន់ ដេកមិនពេញភ្នែក គឺថាខ្ញុំ ក្នុងចិត្តខ្ញុំនេះរកអ្វីមកប្រៀបធៀបមិនបាន គឺថាឃ្លានខ្លាំងពេក និយាយជំនុំគ្នាថា "ខ្ញុំឲ្យតែបាយខ្ញុំហូបឲ្យឆ្អែត មាន់ស្ងោរខ្ញុំមួយចាន ដូចពីសង្គមហ្នឹង យកខ្ញុំទៅសម្លាប់ចុះ ខ្ញុំមិនស្ដាយជីវិតខ្ញុំទេ ឲ្យតែបានឆ្អែតមួយពេលបានហើយ" ជំនុំគ្នាអ៊ីចឹង។ អ្ហ៎! អ្នកខ្លះទៅគេថា "អញបានគុយទាវមួយចានទឹកកកមួយកែវ គេយកទៅសម្លាប់ ក៏គេមិនស្ដាយដូចគ្នា"។ គិតទៅនិយាយតែពីរឿងស៊ី បំណាច់យើងឃ្លានពេកៗ បាទ ហ៊ានយកជីវិតទៅប្ដូរការស្លាប់ជំនាន់នោះ ឲ្យតែបានឆ្អែតៗ មួយពេលគេយកទៅសម្លាប់ចោលទៅ អត់មានស្ដាយទេ អត់ស្ដាយទេ បាទ។

[១០:០៥:០០]

**ស៖** ថាតើនៅពេលដែលលោកទៅធ្វើការនៅការដ្ឋានទំនប់ត្រពាំងថ្មហ្នឹង តើលោកដឹងថាអាចនឹងការចំណាយកម្លាំង ការខិតខំរបស់លោកហ្នឹង អាចនឹងទទួលបានផលប្រយោជន៍អ្វីទេ?

**ឆ៖** បាទ អរគុណលោកមេធាវី។ ខ្ញុំបើនិយាយពីរឿងផលប្រយោជន៍និងកម្លាំង ជំនាន់នោះខ្ញុំដូចជាសត្វមួយក្បាលទៅចុះ ចាត់ទុកជាសត្វមួយក្បាលទៅចុះ គេប្រើអីធ្វើហ្នឹងៗ។ ចំពោះផលប្រយោជន៍ ដែលថាទំនប់នោះ សម្រេចដោយលទ្ធផល ឬយ៉ាងណានោះ ខ្ញុំអត់ដឹង ផែនការរបស់អង្គការ ខ្ញុំអត់ដឹង ខ្ញុំអត់បានដឹង ប៉ុន្តែខ្ញុំនេះដូចជាសត្វមួយក្បាលដែលគេសម្រាប់ប្រើ មិនដឹងជាថ្ងៃណាស្លាប់ មិនដឹងជាថ្ងៃណារស់ ព្រោះជំនាន់នោះអត់ដឹងទេ អត់ដឹងខ្លួនឯងថ្ងៃស្លាប់ថ្ងៃណា ដឹងៗអានេះរស់ ស្អែកមិនដឹងយ៉ាងម៉េចទេ អត់ដឹង យើងអត់ដឹងមុន ជំនាន់នោះយើងអត់ដឹងមុនទេ អាការស្លាប់នោះអត់ដឹងមុនទេ។ ដឹងថ្ងៃហ្នឹងរស់ ឬមួយល្ងាចស្លាប់ ក៏យើងមើលមិនដឹង អត់ដឹងថាគេតម្រូវការយើងធ្វើរម៉ាន យើងក៏មិនដឹង។ ប៉ុន្តែទំនប់អាងត្រពាំងថ្ម ខ្ញុំក៏មិនដឹងថាគោលបំណងគេធ្វើហ្នឹងដើម្បីអី ក៏ខ្ញុំមិនដឹង ព្រោះខ្ញុំនៅក្មេង ហើយយើងមិនចាប់អារម្មណ៍ថាគេធ្វើដើម្បីធ្វើអី យើងគេធ្វើនេះដើម្បីធ្វើអី យើងក៏មិនដឹងដែរ អត់

ដឹងៗ ដឹងត្រឹមតែថាធ្វើស្រែប្រាំងទៅ ដឹងតែប៉ុណ្ណឹង រឿងស្រែប្រាំងដឹង អារឿងហ្នឹង។ អារឿងផលប្រយោជន៍ទៅមុខទៀត ខ្ញុំអត់ដឹង។

**ស៖** បាទ សំណួរចុងក្រោយមួយ គឺថា តើនៅពេលដែលលោកធ្វើការនៅទីនោះ មានការហៅថា លោកបានលើកឡើងអម្បាញ់មិញ មានន័យថាស្លាប់ព្រឹកក៏មិនដឹង ស្លាប់ល្ងាចក៏មិនដឹង។ ថាតើនៅស្ថានភាពនៅពេលនោះអ្នកទាំងអស់គ្នា ទាំងក្រុមលោកទាំងទូទៅហ្នឹង សុទ្ធតែអារម្មណ៍ ពិសេសគឺអារម្មណ៍របស់លោកតែម្តងឈឺចាប់យ៉ាងម៉េច? បានន័យថាហួសមួយថ្ងៃ ឬមួយថ្ងៃ ភ័យខ្លាចរហូត ឬមួយយ៉ាងម៉េច?

**ឆ៖** បាទ អរគុណ។ នេះគំនិតអត់ខុសគ្នាទេ គំនិតគឺប្រហែលប្រហាក់ប្រហែលគ្នា ជំនាន់នោះប្រហាក់ប្រហែលគ្នា ព្រោះសុទ្ធតែពួកចេញពីទីក្រុងដូចគ្នា ធ្វើកងចល័តសុទ្ធតែ១៧មេសាដូចគ្នា។ មានដែរ មានមូលដ្ឋានគេមានដែរ មិនអត់ទេមាន តែមូលដ្ឋានហ្នឹងគេយកតែថ្នាក់ គេហៅថាមើលយើង មើលការខុសត្រូវយើង ខុសត្រូវអីគេមើលលើយើង និយាយខុសនិយាយត្រូវអីគេមើលលើយើង ប៉ុណ្ណឹង។ បើយើងពួក១៧មេសានេះ ដូចតែគ្នាទាំងអស់ ចិត្តមិនខុសពីគ្នាទេ បាទ។

[១០:០៨:៤៧]

**ស៖** ជាចុងក្រោយ តើលោកមានសំណួរអ្វីតាមរយៈលោកប្រធានអង្គជំនុំជម្រះ ទៅជនជាប់ចោទដែរឬទេ?

**ឆ៖** បាទ សូមអរគុណលោកមេធាវី។

**លោក សម ស័ក្ត៖**

សូមគោរពលោកប្រធាន សូមសួរ សូមសំណួរ សូមសួរសំណួរតាមរយៈលោកប្រធាន ទៅដល់ជនជាប់ចោទថា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គេចាត់ទុកកុមារ ជាសសរទ្រូងរបស់បដិវត្ត។ ហេតុអ្វីក៏មិនឲ្យកុមារមានការរៀនសូត្រ? ផ្ទុយទៅវិញ បែរយកកុមារទៅធ្វើបាប រើសអាចម៍គោ កាប់ទន្រ្ទានខែត្រ បង្អត់អាហាររហូតដល់មួយកំប៉ុង៣០នាក់ ខ្ញុំចង់សួរមួយសំណួរ។

សំណួរទី២ៗ ខ្ញុំសុំសួរថា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ អង្គការលើកឡើងថា បង្កបង្កើនផលឲ្យបានក្នុងមួយហិកតា បីទៅបួនតោន តើស្រូវអង្ករទាំងនោះយកទៅណា? ហេតុអ្វីមិនចែកប្រជាជនហូបគ្រប់គ្រាន់?

ទី៣ ខ្ញុំសុំសួរថា កម្ពុជាប្រជាធិបតេយ្យ មហាលោតផ្លោះ មហាអស្ចារ្យ ហេតុអ្វីទំនប់ត្រពាំងថ្ម

មិនយកគ្រឿងចក្រទៅប្រើប្រាស់ បែរទៅកេណ្ឌកម្លាំងប្រជាជនទៅធ្វើទៅវិញ ហើយថែមទាំងបង្អត់អាហារទៀត? បាទ សូមអរគុណលោកប្រធាន។

[១០:១០:៥៥]

**ប្រធានអង្គជំនុំ៖**

បាទ ហើយអង្គជំនុំជម្រះសូមជម្រាបទៅលោក សម ស័ក្ត ថានៅក្នុងសវនាការកាលថ្ងៃពី០៨ ខែមករា ២០១៥ បន្ទាប់ពីអង្គជំនុំជម្រះបានសួរបញ្ជាក់ជនជាប់ចោទទាំងពីររូបឲ្យឆ្លើយបញ្ជាក់ពីជំហររបស់ពួកគាត់រក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបនឹងសំណួរ ហើយនាពេលនោះ នាពេលសវនាការនោះ អង្គជំនុំជម្រះបានកត់សម្គាល់ថា ជនជាប់ចោទទាំងពីរនាក់នៅតែរក្សាជំហររបស់ខ្លួនបន្តអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបដដែល លើកលែង និងរហូតដល់ពេលណាដែលអង្គជំនុំជម្រះសាលាដំបូងទទួលបានព័ត៌មានជាក់ច្បាស់ផ្សេងពីជនជាប់ចោទ ឬពីសហមេធាវីការពារក្តីជនជាប់ចោទ។ ហើយនៅក្នុងសវ-នាការនោះ អង្គជំនុំជម្រះក៏បានកំណត់ឲ្យជនជាប់ចោទ និង/ឬ មេធាវីការពារក្តីជនជាប់ចោទ ត្រូវមានកាតព្វកិច្ចទទួលខុសត្រូវក្នុងការជូនដំណឹងដល់អង្គជំនុំជម្រះឲ្យទាន់ពេលវេលា និងមានប្រសិទ្ធភាពបើសិនជាជនជាប់ចោទសម្រេចលះបង់សិទ្ធិនៅស្ងៀមមិនឆ្លយតប ហើយយល់ព្រមឆ្លើយតបនឹងសំណួរដោយអង្គជំនុំជម្រះ ឬក៏ភាគីនៅដំណាក់កាលមួយនៃកិច្ចដំណើរការនីតិវិធីសវនាការ។

ហើយរហូតមកដល់ពេលនេះ អង្គជំនុំជម្រះនៅមិនទាន់បានទទួលដំណឹងពីផ្លាស់ប្តូរជំហររបស់ជនជាប់ចោទទាំងពីរនាក់នៅឡើយទេ ពីការសម្រេចលះបង់សិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយតប មកជាការឆ្លើយតបនឹងសំណួរនោះ។ ដូច្នេះ គឺយើងមិនអាចបង្ខំឲ្យជនជាប់ចោទដែលបានលះបង់សិទ្ធិឆ្លើយតប ហើយនៅស្ងៀមមិនឆ្លើយតប ទៅជាឆ្លើយតបនឹងសំណួររបស់លោកបានទេ។

បាទ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះទៅ រហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់រួមទាំងបុគ្គលិកអង្គការធី.ភី.អូ មកកាន់កន្លែងដែលគាត់អង្គុយថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងព្យសនកម្មនៅក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងដប់កន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៣ នាទី ដល់ម៉ោង ១០:៣១ នាទី)*

[១០:៣១:២០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយតទៅនេះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសតាំងសំណួរចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ប្រសិនបើមាន។ សូមអញ្ជើញ!

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន ហើយជាបឋមសូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល ហើយក៏សូមជម្រាបសួរលោក សម ស័ក្ត ផងដែរ។

ខ្ញុំឈ្មោះ សេង ប៊ុនឃាង ជាសហព្រះរាជអាជ្ញារងជាតិនៃការិយាល័យសហព្រះរាជអាជ្ញា ហើយខ្ញុំមានសំណួរមួយចំនួនដើម្បីឲ្យលោកជួយបញ្ជាក់ជូនអង្គសវនាការ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** សំណួរដំបូងរបស់ខ្ញុំ គឺចង់ដឹងថាតើអ្នកដែលធ្វើការនៅទំនប់ត្រពាំងថ្មហ្នឹង មានជាមនុស្សប្រភេទណាខ្លះ ឧទាហរណ៍ដូចជា មនុស្សចាស់ ក្មេង ឬក៏ប្រជាជនមូលដ្ឋាន ឬក៏ប្រជាជនថ្មីអីបាទ?

**លោក សម ស័ក្ត៖**

**ឆ៖** បាទ សូមអរគុណ។ នៅក្នុងការដ្ឋានត្រពាំងថ្ម គឺថាមានអាយុ គឺថាកម្លាំងពេញវ័យ។ ពេញវ័យគឺថា ចាប់ពី១៦ ទៅដល់ប្រហែលជាអាយុ៤០ ៤០ជាងតិចតួច។ បាទ ខ្ញុំចាំមិនភ្លេច ប្រហែល ៤០ជាងបាទ ហើយចល័តនោះ គឺថាភាគច្រើនជាពួក ១៧មេសា ៗ បាទ។

[១០:៣៣:៣៨]

**ស៖** ចុះលោកអាចប៉ាន់ប្រមាណអំពីចំនួនអ្នកដែលធ្វើការនៅទំនប់ត្រពាំងថ្មហ្នឹងបានទេថា ប្រហែល ចំនួនប្រហាក់ប្រហែល តើប្រហែលប៉ុន្មាននាក់ដែរ?

**ឆ៖** បាទ សូមអរគុណ។ កងចល័តនៅទំនប់ត្រពាំងថ្មនោះ គឺគ្មានអ្នកណាមួយថា ប៉ាន់ស្មានត្រូវបានទេ។ គ្មានអ្នកណាអាចប៉ាន់ស្មានបាន គឺមនុស្សច្រើនណាស់ គ្រប់ស្រុកៗ មកធ្វើអាងត្រពាំងថ្មនោះ គ្រប់ស្រុក។ មិនអាចអ្នកណាមួយថា ចំនួនពាន់ ចំនួនលាននាក់បានទេ អត់បានទេ។ ខ្ញុំអត់ជឿ។ បាទ សូមអរគុណ។

**ស៖** អ៊ីចេះ ខ្ញុំចង់ឲ្យលោក បើសិនជាអាច តើលោកអាចប៉ាន់ប្រមាណថា ចំនួនរយ ចំនួនពាន់ឬចំនួនម៉ឺននាក់ តើលោកលោកអាចប៉ាន់ប្រមាណចំនួនប៉ុណ្ណឹងបានទេ?

**ឆ៖** បាទ អរគុណ។ សូមទោស ខ្ញុំអត់អាចប៉ាន់ទេ ព្រោះមនុស្សមើលទៅដាច់កន្ទុយភ្នែកបាទ។

**ស៖** បាទ អរគុណ។ មុននេះបន្តិចលោកបានជម្រាបជូនអង្គសវនាការថា លោកធ្លាប់ធ្វើការរែកដីនៅទំនប់ត្រពាំងថ្មនេះដែរ។ អ៊ីចឹងខ្ញុំចង់ដឹងថា តើក្នុងមួយថ្ងៃគេតម្រូវឲ្យលោករែកដីប៉ុន្មានម៉ែត្រគូប?

**ឆ៖** បាទ អរគុណ។ ក្នុងកងចល័តត្រពាំងថ្មហ្នឹង គឺថាគេកំណត់ឲ្យយើងប្រហែលជា ២ម៉ែត្រ ២ម៉ែត្រទៅ៣ម៉ែត្រ ព្រោះថាវាមាន២ម៉ែត្រហ្នឹងកាលយើងធ្វើមុនដំបូងវា ជិតៗ ដល់ពេលក្រោយមកយើងរែកឆ្ងាយទៅៗអ៊ីចឹងឲ្យយើង ២ម៉ែត្រ បន្ទាប់មក មុន៣ម៉ែត្រៗគូបក្នុងមួយថ្ងៃ បាទ។

[១០:៣៦:០២]

**ស៖** តើលោកអាចជម្រាបបានទេថា តាមរយៈការដឹងរបស់លោក ឬក៏តាមការសង្កេតរបស់លោកផ្ទាល់ហ្នឹង តើអ្នកដែលមិនអាចធ្វើការតាមផែនការកំណត់ដូចដែលលោកបានជម្រាបជូនអង្គសវនាការអម្បាញ់មិញនេះ តើមានអ្វីកើតឡើងចំពោះពួកគេដែរទេ?

**ឆ៖** បាទ សូមអរគុណ។ ការកំណត់ផែនការរបស់អង្គការហ្នឹង គឺឲ្យយើងធ្វើតាមគោលការណ៍របស់គេគឺថា ២ម៉ែត្រគឺ ត្រឹម២ម៉ែត្រ។ កំណត់២ម៉ែត្រគឺហើយហ្នឹង។ ៣ម៉ែត្រ គឺហើយ៣ម៉ែត្រហ្នឹង។ ប៉ុន្តែភាគច្រើនដែលថាមិនហើយ ភាគច្រើនណាស់គឺហើយតែម្តង។ បាទ ភាគច្រើនមិនហើយគ្មានទេតិចណាស់ បាទ។

**ស៖** បាទ អរគុណ។ ចុះតាមរយៈដែលលោកដឹងផ្ទាល់ ឬក៏តាមរយៈការសង្កេតរបស់លោក ឬក៏តាមរយៈដឹងតាមប្រភពណាក៏ដោយ នៅពេលនោះ អ្នកដែលធ្វើមិនហើយតាមផែនការនោះ តើគេធ្វើអ្វីខ្លះចំពោះអ្នកដែលធ្វើមិនហើយហ្នឹង? តើលោកអាចជម្រាបជូនអង្គសវនាការបានទេ?

**ឆ៖** បាទ អរគុណ។ ការងាររែកដីជាកងចល័ត គេកំណត់ឲ្យយើងធ្វើ។ ហើយ មិនហើយគឺថាពេលយើងធ្វើមិនហើយអ៊ីចឹង ឧបមាថា យើងមិនហើយអ៊ីចឹងចុះ គេហៅយើងទៅទិតៀន គេហៅធ្វើ

ទិតៀន និងស្វ័យទិតៀន។ បាទ គេធ្វើការប្រជុំឲ្យយើងប្រឹងឲ្យហើយជូនអង្គការ។ គេទិតៀនយើង ស្វ័យទិតៀនយើង។ បាទ មានតែប៉ុណ្ណឹង។

[១០:៣៨:១៥]

**ស៖** ចុះដែរមានទេ ក្នុងករណីដែលគេហៅទៅស្វ័យទិតៀន ឬទិតៀនហើយ ប៉ុន្តែអ្នកនោះនៅតែមិនអាចធ្វើបាន? តើមានករណីហ្នឹងមានកើតឡើងដែរទេ? ហើយបើសិនជាមាន តើអ្នកដែលធ្វើមិនបានហ្នឹងទទួលផលយ៉ាងម៉េចខ្លះបន្ទាប់ពីធ្វើមិនបានហ្នឹង?

**ឆ៖** បាទ អរគុណ។ កងចល័តត្រពាំងថ្ម គឺថាគេមើលដែរ។ គឺពីមុនយើងទៅធ្វើការ គេមើលយើងដែរ សមត្ថភាពយើងដែរ តើយើងអាចធ្វើកើតដែរអត់ គេមើលដែរ គេមើល។ បាទ គេមើល។ តែរឿងថា ធ្វើមិនហើយហ្នឹងគេធ្វើយ៉ាងម៉េច គឺថាខ្ញុំអត់ដឹងដែរហ្នឹង ពេលហ្នឹងអត់ដឹងៗ។ អត់បានដឹងទេ។ បាទ សូមអរគុណ។

**ស៖** ទាក់ទងនឹងលោកបានជម្រាបទាក់ទងនឹងការស្វ័យទិតៀនហ្នឹង តើនៅកន្លែងលោកៗ ធ្លាប់ត្រូវបានគេហៅធ្វើការប្រជុំស្វ័យទិតៀនដែរទេ? ហើយប្រសិនជាមាន តើគេធ្វើប៉ុន្មានថ្ងៃម្តង?

**ឆ៖** បាទ សូមអរគុណ។ ស្វ័យទិតៀនហ្នឹង ខ្ញុំធ្លាប់ប្រជុំស្វ័យទិតៀនក្នុងកង ក្នុងពួក ក្នុងពួកវាមិនដឹងទេ បាទ មានបីនាក់ ប្រាំមួយនាក់មិនដឹងទេ ខ្ញុំភ្លេចទៅ ខ្ញុំភ្លេច តែខ្ញុំគេមានគេហៅខ្ញុំទិតៀនខ្ញុំ បានខ្ញុំដឹង។ ឧបមាថា ខ្ញុំធ្វើការ ខ្ញុំធ្វើអត់ហើយទេ ខ្ញុំរែកអត់ហើយ អ៊ីចឹងខ្ញុំសល់។ អ៊ីចឹងគេធ្វើការទិតៀនខ្ញុំថា គេប្រជុំអ៊ីចឹង គេថា សូម “ខ្ញុំសូមទិតៀនមិត្តស័ក្តិ” បាទ គេថាអ៊ីចឹង។ សូមទិតៀនមិត្តស័ក្តិ។ “មិត្តឯងធ្វើឲ្យដូចគេដូចឯង ឲ្យតាមផែនការរបស់អង្គការ”។ បាទ ដល់ពេលគេទិតៀនយើងអ៊ីចឹង ដល់ពេលនេះ គេឲ្យទទួលកំហុស ដល់ពេលខ្ញុំថាខ្ញុំទទួលកំហុសហើយ ខ្ញុំអត់ហ៊ានតវ៉ានឹងគេទេ ព្រោះយើងធ្វើអត់ហើយមែន។ បាទ ខ្ញុំថា “អ៊ីចឹងខ្ញុំសូមទទួលកំហុសដ៏រីករាយ ខ្ញុំទទួលស្គាល់ការងារ ខ្ញុំធ្វើមិនហើយ ថ្ងៃមុខ ថ្ងៃក្រោយ ខ្ញុំធ្វើឲ្យហើយ”។ ខ្ញុំមាននិយាយតែប៉ុណ្ណឹង បាទ នេះយើងសារភាពទទួលកំហុស។ អរគុណ។

**ស៖** បាទ អរគុណ។ ចុះការធ្វើស្វ័យទិតៀន ឬក៏ប្រជុំទិតៀនអីហ្នឹង ជាទូទៅ តើអ្នកណាជាអ្នកដឹកនាំការប្រជុំហ្នឹង?

**ឆ៖** បាទ សូមអរគុណ។ រឿងថា ហៅមកលើកទិតៀន ស្វ័យទិតៀនហ្នឹង គឺថាបញ្ជាពីលើមកឲ្យយើងមានពួក មានក្រុមគេ តែខ្ញុំមិនដឹងពួក កាលហ្នឹងមិនដឹងថាពួក ខាងក្រុមអីទេ ខ្ញុំអត់ដឹង ខ្ញុំអត់

ចាប់អារម្មណ៍ទេ។ ខ្ញុំដឹងថា ខ្ញុំមានតែប្រាំមួយនាក់ទេ តែប្រាំមួយនាក់ មួយពួកខ្ញុំមានតែប្រាំមួយនាក់ទេ។ អីចឹងពេលនេះហើយ គេហៅយើងមក ប្រាំមួយនាក់ហ្នឹង មកអង្គុយមូរគ្នាដូច គម្របឆ្នាំងអីចឹង។ បាទ អីចឹងឧបមាថាខ្ញុំខុសអីចឹង គេចង្អុលឈ្មោះថា មិត្តស័ក្តិ អីចឹង ខុសអីចឹងទៅ គេទិតៀនខ្ញុំទៅ ខ្ញុំឡើងទទួលកំហុសអីចឹងទៅ គឺចប់។ អីចឹងគេទិតៀនមិត្ត "ខ" អីចឹង, មិត្ត "ខ" ហ្នឹងអីចេះមួយ អីចេះពីរទៅ គេទិតៀនហើយអីចឹង អ្នកនុ៎ងគេទទួលកំហុសទៅ គឺចប់ បាទ មានតែប៉ុណ្ណឹង។ ទិតៀន ស្វ័យទិតៀនហ្នឹង។ បើថាមេក្រុមធ្វើខុសពីយើង យើងទិតៀនមេក្រុមវិញទៅ ទៅវិញទៅមក។ អាហ្នឹងគេថាកញ្ចក់ឆ្លុះខ្លួនឯង បាទ ឆ្លុះខ្លួនឯងអាហ្នឹង។ ឆ្លុះគ្នាទៅវិញទៅមក។ បាទ សូមអរគុណ។

**ស៖** បាទ អរគុណ។ ឥឡូវទាក់ទង ខ្ញុំចូលមកកន្លែងទំនប់ត្រពាំងថ្មនៃការ ការធ្វើការនៅទំនប់ម្តងឡើងវិញ។ តើលោកដឹងទេថា អ្នកដែលធ្វើការនៅទំនប់ត្រពាំងថ្មនោះ មានអ្នកដែលរបួស ឬក៏មានអ្នកស្លាប់អីទេ នៅពេលនុ៎ង?

[១០:៤២:៥១]

**ឆ៖** បាទ សូមអរគុណ។ តែខាងខ្ញុំ ដូចអត់បានឃើញរបួស បានឃើញអីទេ ព្រោះវាមិនប៉ះខាងរបួសហ្នឹង បើខាងគេ ប៉ែកខាងគេរបួស ខ្ញុំក៏មិនបានដឹងដែរ។ បាទ អាហ្នឹងវាចែកជាក្រុម ជាពួកអីចឹង ខាងក្រុមយើងអត់មានទទួលការរបួស ខ្ញុំអត់ដឹងដែរ។ បាទ អរគុណ។

**ស៖** បាទ អរគុណ។ ចុះតាមការសង្កេតរបស់លោក តើលោកឃើញស្ថានភាពសុខភាពរបស់អ្នកដែលធ្វើការនៅទីនោះ មានស្ថានភាពយ៉ាងម៉េចដែរ ឧទាហរណ៍ដូចជាស្គមស្គាំង ស្លេកស្លាំងអី។ តើលោកសង្កេតយ៉ាងម៉េច ចំពោះអ្នកធ្វើការនៅទីនោះ?

**ឆ៖** បាទ សូមអរគុណ។ ក្នុងកងចល័តត្រពាំងថ្មនោះ មានអ្នកឈឺ មិនអត់ទេ។ អ្នកឈឺវាមានហើយ មិនមែនអត់ទេ ទាំងគេ ទាំងខ្ញុំ ព្រោះការហូបវាមិនគ្រប់គ្រាន់។ ដេកក៏មិនបានពេញភ្នែក។ អីចឹងមនុស្ស វាមានជំងឺទ្រុឌទ្រោមហើយ។ ដូចខ្ញុំនិយាយពីខាងដើមថា ក្បាលខ្ញុំដូចបាតលោកអីចឹង ត្រមោងៗ ក្បាលជង្គង់ឡើង ត្រមោងៗ បាទ ទៅជាញាក់ ទៅជាគ្រុនៗហ្នឹង គ្រុនៗចាញ់ផង ក៏មានគ្រុនលស់ ក៏មាន អាគ្រុនលស់ វាគ្រុនដឹងពេល។ ឧបមាថា យើងគ្រុនម៉ោងមួយ ចាប់ផ្តើមម៉ោងមួយ ដឹងតែប្រេឲ្យហើយទៅ អាហ្នឹងញាក់មកហ្មង ចេញពីក្នុងឆ្អឹងមកហ្មង។ ហ្នឹងហើយ គេហៅគ្រុនលស់។ បាទ បើគ្រុនចាញ់នេះ គឺមុខស្លេកស្លាំងអីចឹងទៅ ខ្លួនឡើងហើមទៅ ក្បាលពោះកំពីងៗទៅ ក្បាលជង្គង់ត្រមោងៗទៅ បាទ មានៗ ហើយឈឺស្លាប់ មានឈឺស្លាប់ មាន។ ដូចគ្រុនចាញ់អីចឹង បាទ។

**ស៖** បាទ អរគុណ។ លោកបានជម្រាបជូនអង្គសវនាការអម្បាញ់មិញថា មានការសម្រាក ឬក៏ដេកមិនគ្រប់គ្រាន់។ អ៊ីចឹងខ្ញុំចង់ដឹងអំពីពេលវេលានៃការធ្វើការ តើនៅកន្លែងធ្វើការនៅការដ្ឋានទំនប់ត្រពាំងថ្មហ្នឹង គេតម្រូវឱ្យយើងធ្វើការពីពេលណា? ពេលវេលានៃការធ្វើការ? ពេលណាដល់ពេលណា? សម្រាកពេលណា ហើយតពេលណាទៀត?

[១០:៤៥:៣៨]

**ឆ៖** បាទ សូមអរគុណ។ ក្នុងទំនប់ត្រពាំងថ្មគឺថា ធ្វើមួយថ្ងៃបីពេល។ ម៉ោងបួន បួនជាង, ម៉ោងប្រហែលម៉ោងប្រាំ ពួកខ្ញុំចេញទៅមើលគ្នាអត់ស្គាល់ទេ បាទ អត់ស្គាល់ទេ។ គឺថាសំអាងលើមាន់រងាវ មាន់រងាវជិតភ្លឺហ្នឹងគឺយើងចេញហើយ ហើយយើងក៏សន្មតថាប្រហែលជាម៉ោងប្រាំ ឬមួយម៉ោងជិតប្រាំចុះ ប៉ុន្តែមើលគ្នាអត់ស្គាល់ទេ មើលគ្នាអត់ឃើញទេចេញទៅហ្នឹង កាប់ហ្នឹងដូចខ្ញុំថាអ៊ីចឹង ឮសូរតែស្នូរចប តែមនុស្សអត់ឃើញទេ ឮគឹកគាក់ៗអ៊ីចឹងទៅ។ អារឿងមនុស្សមើលអត់ឃើញទេវានៅងងឹតនៅឡើយ។ អ៊ីចឹងបានថា ខ្ញុំសន្មតថាជាម៉ោងប្រាំចុះបាទ នៅងងឹតហ្នឹង រហូតដល់ម៉ោងដប់មួយ ហ្នឹងពេលព្រឹក។ ចុះមក ឡើងមកអ៊ីចឹង កំណត់ម៉ោងអ៊ីចឹង ប្រហែលជាម៉ោងដប់មួយថ្ងៃត្រង់ហ្នឹង មើលថ្ងៃទៅ គ្មានអ្នកណាមាននាឡិកាពាក់មើលថ្ងៃទេ គេឱ្យមើលថ្ងៃ ល្មមឡើងគេឱ្យឡើង បាទ ម៉ោងដប់មួយឡើងមក បាយទឹកហើយអីហើយអ៊ីចឹង ងូតទឹកងូតអីហ្នឹង សម្រាកបានមួយភ្លែត ម៉ោងមួយយើងចុះទៅទៀតហើយ ទៅដល់ម៉ោងប្រាំល្ងាច។ បាទ ម៉ោងប្រាំល្ងាចៗអ៊ីចឹង យើងមក ឡើងមកអ៊ីចឹង យើងងូតទឹកហូបបាយទៅ ហូបបបរទៅ ដាក់ចែក ដាក់ចានមួយជួរតុអ៊ីចឹង ដាក់ពីរជួរអ៊ីចឹងទៅ គេវាល់អាចូងគេដាក់ចូងគេវាល់ហើយអ៊ីចឹង អាចានចៀមអ៊ីចេះ គេដាក់ផ្កាប់អ៊ីចេះ ឱ្យស្មើគ្នាតែម្តង ថាមួយចានៗគឺស្មើគ្នាតែម្តង គេដាក់ពីរជួរអ៊ីចឹង យើង*(ឮមិនច្បាស់)* ហូបទៅ បាទ ហើយយើងងូតទឹក ងូតទឹកទៅបាទ ម៉ោងប្រាំមួយចាប់ផ្តើមប្រមូលគ្នាហើយ ចាប់ផ្តើមកកម្លាំងគ្នា ទៅដល់ការដ្ឋានធ្វើម៉ោងប្រហែលម៉ោងប្រាំពីរ ដើរទៅជាមួយគេជាមួយឯង ទៅដល់ហ្នឹងម៉ោងប្រាំពីរ ចាប់ផ្តើមធ្វើគឹកគាក់ៗហ្នឹងទៅ បាទ។ ហើយម៉ោងដប់ បានគេឱ្យមកសម្រាក ដប់យប់បាទ ដប់យប់។ បាទ សូមអរគុណ។

[១០:៤៧:៥៧]

**ស៖** បាទ អរគុណ។ ខ្ញុំនៅសល់សំណួរពីរបីសំណួរទៀតដើម្បីសួរលោក។ ទាក់ទងទៅនឹងនៅកន្លែងធ្វើការនោះដែរ នៅពេលដែលអ្នកធ្វើការ ឬក៏លោកស្រេកទឹក តើមានទឹកស្អាតសម្រាប់ទទួលទានដែរទេនៅពេលហ្នឹង?

**ឆ៖** បាទ សូមអរគុណ។ ជំនាន់នោះ គ្មានគេយកទឹកស្អាតឲ្យយើងទេ។ ទឹកនោះល្អក់ គេហៅទឹកល្អក់ គ្មានអនាម័យទេទឹក គ្មានអនាម័យទេ ទឹក។ ពេលយើងកុនណាស់ ពេលណាយើងផឹកទឹកទាល់តែយកអាវមកដាក់មាត់អ៊ីចេះ ដាក់មាត់ហើយយើងបឺត យើងខ្លាចៗមានសត្វល្អិតចូលក្នុងពោះយើង បាទលាអាវអ៊ីចេះមក មានអាវអ៊ីចឹងដាក់អ៊ីចេះ ហើយយើងដាក់ផឹកទៅ ហ្នឹងរបៀបវិធីផឹកទឹក បាទ ទឹកវាអត់ស្អាត ទឹកវាមានកូនសត្វល្អិត បាទ អរគុណ។

**ស៖** បាទ អរគុណ។ ចុះលោកអាចជម្រាបជូនអង្គសវនាការបានទេថា នៅការដ្ឋានទំនប់ត្រពាំងថ្មហ្នឹង តើមានអ្នកណាជាអ្នកគ្រប់គ្រងនៅការដ្ឋានហ្នឹងដែរទេ លោកដឹងទេ?

**ឆ៖** បាទ សូមអរគុណ។ ខ្ញុំៗជំនាន់នោះ ខ្ញុំអត់បានស្គាល់ថា អ្នកណាជាអ្នកគ្រប់គ្រងកងរបស់ខ្ញុំទេ ខ្ញុំអត់ដឹងទេ ក៏ប៉ុន្តែ ខ្ញុំថាដឹងថាខ្ញុំហ្នឹង ធ្វើការក្នុងកងចល័តនេះគឺថា របស់តាវ៉ាល់ ប៉ុន្តែត្រង់ថា ខ្ញុំមេកងមេអីខ្ញុំហ្នឹង ខ្ញុំអត់ដឹងឈ្មោះវាទេ ខ្ញុំអត់ដឹងទេ ព្រោះខ្ញុំជាឋានៈ អត់មានឋានៈអីត្រូវថាដឹងការងារអីចឹងៗទេ បាទ អត់មានត្រូវៗដឹងអារឿងការងារហ្នឹង ដឹងតែពីធ្វើឲ្យគេទៅ ដើម្បីបាន កុំឲ្យវាមានកំហុសដែលប៉ុណ្ណឹងទេ អត់មានចង់ដឹងថាអ្នកណាធ្វើមេកង មេក្រុម មេអី ខ្ញុំអត់ចង់ដឹងទេ។ តែខ្ញុំដឹងថាតាវ៉ាល់ ជាអ្នកគ្រប់គ្រង លើចល័តត្រពាំងថ្ម ខ្ញុំដឹងតែប៉ុណ្ណឹង។

[១០:៥០:៣៤]

**ស៖** បាទ អរគុណ។ សំណួរចុងក្រោយរបស់ខ្ញុំ ចង់ឲ្យលោកជួយបញ្ជាក់ដែរ តាមរយៈការឃើញរបស់លោកផ្ទាល់ ឬក៏តាមរយៈការឮគេនិយាយប្រាប់លោក ថាតើធ្លាប់មានថ្នាក់ដឹកនាំពីលើៗ ចុះទៅពិនិត្យនៅការដ្ឋានត្រពាំងថ្មនោះដែរអត់?

**ឆ៖** បាទ សូមអរគុណ។ ខ្ញុំបានឃើញៗ ថ្នាក់ដឹកនាំគេមក តែខ្ញុំអត់បាននៅជិតគេទេ ខ្ញុំនៅក្រោមទំនប់ កំពុងរែកដីនៅក្រោមទំនប់ទេ បាទ ឃើញថ្នាក់ដឹកនាំគេនៅលើខ្នងទំនប់ទេ។ ខ្ញុំមើលពីចម្ងាយ ឃើញតែប៉ុណ្ណឹង បាទ សូមអរគុណ។

**ស៖** បាទ អរគុណ។ តាមរយៈដែលលោកឃើញពីចម្ងាយហ្នឹង តើលោកស្គាល់ទេ ថ្នាក់ដឹកនាំហ្នឹង អ្នកណាខ្លះ? ឬក៏មានអ្នកណាខ្លះប្រាប់លោកថា នោះថ្នាក់ដឹកនាំដែលមកហ្នឹងឈ្មោះនេះៗ តើលោកស្គាល់អត់ លោកដឹងចំណុចហ្នឹងអត់?

**ឆ៖** បាទ សូមអរគុណ។ ក្នុងធ្វើការក្នុងទំនប់នោះ ត្រពាំងថ្មនោះ គឺមានថ្នាក់ដឹកនាំគេមកមើល ក៏ប៉ុន្តែគ្រាន់តែដឹងថាៗចិនៗគេមកចិនៗគេមកមើលអ៊ីចឹង ចិនគេពាក់ខោខ្មៅ អាវខ្មៅទៅ បាទ គេមក

ហើយស ស្បែកស។ យើងមិនទៅជិតគេទេ គ្រាន់ថា និយាយពីតគ្នាពីមួយទៅមួយៗ។ អាអ្នកគេនៅកិត ទៅគេដឹង អ្នកយើងនៅឆ្ងាយ គឺថាគេនិយាយតៗៗគ្នាហ្នឹងថា "ចិនគេមកមើលទំនប់ហ្នឹងហើយ ចិន គណៈប្រតិភូចិន"។ បាទ ដឹងតែប៉ុណ្ណឹង។

[១០:៥២:៤២]

**ស៖** ចុះ លោកបានបញ្ជាក់ប្រតិភូចិន។ ចុះប្រតិភូនៅក្នុងស្រុក នៅក្នុងប្រទេសកម្ពុជានេះ កម្ពុជាប្រជាធិបតេយ្យ តើលោកដឹងទេថាអ្នកដឹកនាំនៃកម្ពុជាប្រជាធិបតេយ្យ តើអ្នកណាបានចូលរួម ជាមួយប្រតិភូចិននោះ? តើលោកមានបានដឹងទេ?

**ឆ៖** បាទ សូមអរគុណ។ ខ្ញុំគ្រាន់តែដឹងថា គណៈប្រតិភូគេមកទេ អត់បានទៅដឹងថា ថ្នាក់ដឹក នាំប្រទេស អ្នកណា គណៈស្រុក គណៈតំបន់ ឬមួយថ្នាក់ដឹកនាំប្រទេសមកទេ ខ្ញុំអត់បានដឹងទេ អត់បាន ដឹងៗ គឺមិនបានដឹង។ បាទ សូមអរគុណ។

**ស៖** បាទ អរគុណ។

**លោក សេង ប៊ុនឃាង៖**

លោកប្រធាន ខាងការិយាល័យសហព្រះរាជអាជ្ញាអស់សំណួរហើយ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះ ផ្តល់វេទិកាទៅក្រុមសហមេធាវីការពារក្តី ដំបូងនេះ ក្រុមមេធាវី ការពារក្តីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ប្រសិនបើ មាន។ សូមអញ្ជើញបាទ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ជម្រាបសួរលោកដើមបណ្តឹងរដ្ឋប្បវេណី! ខ្ញុំមានសំណួរមួយចំនួន សួរលោក<បន្ត>។ ព្រឹកមិញនេះលោកបានឆ្លើយថា នៅពេលដែលលោកធ្វើជាទាហាន លោកបានផ្លាស់ប្តូរទឹកខ្លែងកំណើត ទៅជា ទៅយកទឹកន្លែងកំណើតរបស់ប្រពន្ធរបស់លោកមកប្រើប្រាស់ ដោយសារតែលោកមិនចង់ឱ្យគេ ដឹងថា លោកគឺជាអ្នកដែលមានប្រភពដើមពីខ្មែរក្រោមទេ គឺថាលោកៗផ្លាស់ប្តូរបែបនេះ គឺដើម្បីឱ្យគេ

ដឹងតែថាលោកនេះ គឺមកពីខ្មែរលើ។ តើអាចពន្យល់អង្គជំនុំជម្រះបានទេហេតុអ្វីបានជាលោកមិនចង់ឲ្យគេដឹងអំពីទីកន្លែងកំណើតរបស់លោក?

**លោក សម ស័ក្ត៖**

**ឆ៖** បាទ សូមអរគុណ។ ខ្ញុំផ្លាស់ប្ដូរប្រវត្តិរូបខ្ញុំ គ្រាន់ថាឈ្មោះខ្ញុំនៅដដែល គ្រាន់តែថាខ្ញុំផ្លាស់ប្ដូរលំនៅដ្ឋាន ភូមិកំណើត ពីកម្ពុជាក្រោម មកជាកម្ពុជាលើវិញ។ គឺថាខ្ញុំមិនចង់ឲ្យគេដឹងថាខ្ញុំនៅកម្ពុជាក្រោមទេ ខ្ញុំចង់ឲ្យដឹងថាខ្ញុំនៅកម្ពុជាលើវិញ។ គំនិតរបស់ខ្ញុំមានតែប៉ុណ្ណឹង តែយើងមិនដែលមានកំហុសខុសឆ្គងអី លាក់ប្រវត្តិរបស់យើង អត់ទេ អត់មានគំនិតថាចង់លាក់ប្រវត្តិទេថា គ្រាន់តែថាចង់ដាក់នៅកម្ពុជាលើវិញ មិនចង់ថានៅកម្ពុជាក្រោម។ មានតែប៉ុណ្ណឹងទេបាទ។

**ស៖** ខ្ញុំស្ដាប់ឮហើយគឺអ្វីដែលលោក -- ហ្នឹងហើយអ្វីដែលលោកបានឆ្លើយកាលពីព្រឹកមិញ។ ប៉ុន្តែសំណួរខ្ញុំសួរថា ហេតុអ្វីបានជាលោកលាក់អត្តសញ្ញាណរបស់លោកនៅពេលនោះ? <ហើយខ្ញុំគិតថាអាចនៅក្នុងទសវត្សរ៍៨០ ក៏ថាបាន?>

**ឆ៖** បាទ សូមអរគុណ។ ខ្ញុំឆ្លើយយ៉ាងម៉េចទេ បើខ្ញុំថាខ្ញុំលាក់អត្តសញ្ញាណកម្ពុជាក្រោមព្រោះខ្ញុំធ្វើចូលធ្វើជាទាហាន ខ្ញុំដាក់នៅភូមិជាវប្ដីម្ដងទៅ ស្រណុកថា យើងមានរឿងមានរ៉ាវអី របួសស្នាមអីប្រពន្ធកូននៅជិតនេះដឹង ខ្ញុំមានម៉ែមានឪឯណាទៀត បើម៉ែឪស្លាប់អស់ហើយៗ។ អ៊ីចឹងមានតែប្រពន្ធខ្ញុំហ្នឹងហើយ ដាក់នៅហ្នឹងហ្នងទៅ ម្ដាយក្មេកឪពុកក្មេក យ៉ាងហោចណាស់ក៏គេដឹងរឿងរបស់ខ្ញុំដែរ មានផែនការអី មានរបួសមានស្នាមអីក៏គេដឹងៗដែរ។ បាទ សូមអរគុណ។

[១០:៥៧:១៧]

**ស៖** បាទ ខ្ញុំនឹងបន្តទៅទៀត <លោកដើមបណ្ដឹង>។ បើខ្ញុំយល់មិនច្រឡំទេ គឺលោកធ្លាប់បានរស់នៅក្បែរផ្សារអូរឡាំពិកនៅក្នុងទីក្រុងភ្នំពេញ នៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ខ្ញុំរស់នៅក្រោយផ្សារអូរឡាំពិក បាទ។

**ស៖** តើលោកអាចប្រាប់ផងបានទេ តើគ្រួសាររបស់លោកពេលហ្នឹងចិញ្ចឹមគោ ក្របីហ្នឹងចិញ្ចឹមនៅឯណា ទុកដាក់វានៅឯណា?

**ឆ៖** បាទ លោកសួរម្ដងទៀត នៅក្នុងក្រុងភ្នំពេញនរណាចិញ្ចឹមគោ ចិញ្ចឹមក្របីទេ បាទ សូមទោស សូមសួរខ្ញុំម្ដងទៀត។

**ស៖** ខ្ញុំយល់ស្របហើយ ប៉ុន្តែក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោក ៗបាន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ស្នើសុំឱ្យសងសំណងចំពោះការបាត់បង់គោ ក្របី <និងផ្ទះសម្បែង>របស់លោក<។> អ៊ីចឹង<ហើយទើបខ្ញុំឆ្ងល់ថា លោកទុកដាក់គោក្របីរបស់លោកនៅកន្លែងណា>?

**ឆ៖** បាទ សូមទោស ខ្ញុំអត់មានសរសេរដាក់សូមសងគោ ក្របី ខ្ញុំអត់មានចិញ្ចឹមទេ ព្រោះខ្ញុំនៅអាយុនៅមិនទាន់ នៅស្រាតខោនៅឡើយហ្នឹង ជំនាន់នោះនៅស្រាតខោនៅឡើយតើ ខ្ញុំមានចិញ្ចឹមគោចិញ្ចឹមក្របីឯណាខ្ញុំ បាទ។

**ប្រធានអង្គជំនុំ៖**

យ៉ាងម៉េចទៅមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី?

**លោក ពេជ អង្គ៖**

បាទ ខ្ញុំចង់សូមឱ្យលោក វ៉ិចទ័រ កូប៉េ ជួយបញ្ជាក់កន្លែងណាដែលគាត់បាននិយាយថា គាត់បានបាត់បង់គោ ក្របីរបស់គាត់នៅក្នុងពាក្យសុំរបស់គាត់។ តាមដែល មើលតាមពាក្យសុំរបស់គាត់ចំណុចទី៧ គឺគាត់សុំគោ ក្របី ក៏ប៉ុន្តែគាត់មិនបានបញ្ជាក់ថាគាត់បានបាត់បង់គោ ក្របីទេ។ អ៊ីចឹងសូមឱ្យលោកមេធាវី ជួយបញ្ជាក់ថាតើកន្លែងណាដែលគាត់និយាយថាគាត់បានបង់គោ ក្របី។ សូមអរគុណ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំយោងទៅលើឯកសារលេខ D22/3209/1, អង់គ្លេស ERN 00562491។ <ការបកប្រែជាភាសាអង់គ្លេសដាក់ថា៖ “អ្នកដាក់ពាក្យបណ្តឹង>ស្នើសុំឱ្យសងការបាត់បង់គោ <> ក្របី <និងផ្ទះ>របស់<គាត់>”។ តែយ៉ាងណាក៏ដោយ មិនសំខាន់អ្វីទេចំណុចនេះ ដោយសារថាដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយទៅហើយ។ អ៊ីចឹងខ្ញុំបន្តទៅមុខទៀតទៅចុះ។

[១១:០១:២១]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំសូមសួរអំពីកំណត់ហេតុស្តាប់ចម្លើយសាក្សីរបស់លោកជាពិសេស អំពីអ្វីដែលលោកបានឆ្លើយនៅក្នុងឯកសារ E319/19.3.10។ សំណួរ និងចម្លើយ១៤៦ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយនេះ គេសួរលោកថា “តើលោកអាចប៉ាន់ប្រមាណបានទេ មានមនុស្សប៉ុន្មាននាក់ស្លាប់ដោយសារអត់បាយ និងស្លាប់ដោយសារជំងឺ <ឬសម្លាប់>? លោកឆ្លើយថា ខ្ញុំមិនដឹងថាមានចំនួនប៉ុន្មានទេ ប៉ុន្តែមានច្រើនណាស់។ បើសិនជាចិនវិញ គឺគេស្លាប់រហូតដល់ស្វាត់ភូមិតែម្តង” តើលោកចង់មានន័យថាម៉េចដែរ នៅពេលដែលលោកឆ្លើយនូវចម្លើយនេះជូនទៅអ្នកស៊ើបអង្កេត?

**លោក សម ស័ក្ត៖**

**ឆ៖** បាទ សូមអរគុណ។ ខ្ញុំឆ្លើយអ៊ីចឹងមែន ព្រោះខ្ញុំបានទៅដល់ភូមិសំរោងហ្នឹង គឺថាគេឲ្យទៅនៅកាប់ផ្ការព្រៃហ្នឹង ភូមិមួយគេហៅ ភូមិច្រអួល។ ភូមិច្រអួល គេដាក់ចិន, ភូមិថ្មីគេដាក់ខ្មែរ។ អ៊ីចឹងភូមិច្រអួលហ្នឹង គេហៅថា ច្រអួលៗហ្នឹង គឺថាគេដាក់ចិនហ្នឹង ងាប់ៗ មួយផ្ទះៗហ្នឹងងាប់ ម៉ាផ្ទះខ្លះអស់រលីង អស់រលីងហ្មង ខ្ញុំឃើញនឹងផ្ទាល់ភ្នែករបស់ខ្ញុំ។ ខ្មែរ ១៧មេសា ក៏ស្លាប់ដោយជំងឺ ស្លាប់ដោយជំងឺទៅ ស្លាប់ដោយលួចពោតលួចអីគេ គេចាប់យកទៅសម្លាប់ក៏មាន ស្លាប់ដោយជំងឺក៏មានអត់អាហារក៏មាន បើចិន ភាគច្រើនចិន គឺថាអត់អាហារ ហើយនិងឈឺ គឺស្លាប់ហ្មង ចិនហ្នឹងបាទ ប៉ុណ្ណឹង។

[១១:០៣:៥២]

**ស៖** ដូច្នេះ បើខ្ញុំយល់មិនច្រឡំទេ គឺថាមិនមែនស្លាប់ដោយសារតែពួកគាត់ជាជនជាតិ<ចិន> នោះទេគឺស្លាប់ដោយសារតែខ្វះចំណីអាហារនេះឯង អ៊ីចឹងមែនទេ?

**ឆ៖** បាទ ចិនមែនជាចិននៅប្រទេសចិនទេ ចិននោះ គឺខ្មែរកាត់ចិន ដែលថាចិនហ្នឹងដូចចិនផ្សារអូរឫស្សីអ៊ីចឹងទៅ ចិនផ្សារថ្មីអ៊ីចឹងទៅ អ្នក១៧មេសាហ្នឹង។ អាហ្នឹងគឺចិនហ្នឹងទេ មិនមែនចិនមកពីប្រទេសក្រៅទេ ចិនកាត់ខ្មែរហ្នឹង ចិនរស់នៅស្រុកខ្មែរ ១៧មេសាហ្នឹង ចេញទៅដូចគ្នាហ្នឹង រួចហើយគេទុកចិត្តហ្នឹងម៉ុ។ ចិនហ្នឹងដូចតែខ្មែរយើងទេ គ្រាន់តែវាស ចិនលក់មាស បាទ មិនមែនចិនមកពីប្រទេសចិនទេ អត់ទេ បាទ ហើយស្លាប់នោះ គឺស្លាប់ដោយសារឈឺទេ គឺស្លាប់ឈឺ។ ចិនហ្នឹងគ្មានអ្នកណាវៃវាទេ ចិនហ្នឹង ជំនាន់ហ្នឹង។ វាអត់អាហារ អត់ថ្នាំសង្កូវហ្នឹង វាឈឺស្លាប់ទេ។ បាទ សូមអរគុណ។

**ស៖** ប៉ុន្តែប្រជាជនដែលមានដើមកំណើតជាចិនហ្នឹង តើគេមានគេ ត្រូវបានគេធ្វើបាបដោយសារហេតុផលណាមួយទេ?

**ឆ៖** បាទ សូមអរគុណ។ ធ្វើដូចតែគ្នា ១៧មេសា អ៊ីចឹង ប៉ុន្តែគ្នានោះវាដូចថា បើនិយាយពីជំនាន់របបខ្មែរក្រហម គឺថានាយទុនណា។ របបនាយទុន គេថា ចិននាយទុន។ បាទ នាយទុន គឺថារកស៊ី គេហៅថារកស៊ីកេងប្រវ័ញ្ច។ ជំនាន់នោះគេហៅថា រកស៊ីកេងប្រវ័ញ្ច។ អាពួកហ្នឹងបានគេយកទៅដាក់ម៉ុ។ បាទ ពួកចិនលក់មាស ចិនអ្នកមានហ្នឹងណា។ បាទ ស្លាប់ដោយសារគ្រុនចាញ់ ហើម។ បាទ ចំពោះការធ្វើការដូចតែគ្នាទេ ធ្វើការដូចតែគេអ៊ីចឹង។ បាទ សូមអរគុណ។

[១១:០៦:១៣]

**ស៖** ខ្ញុំសួរសំណួរ<បន្តមួយ> ដើម្បីឲ្យយល់ចំណុចនេះ ឲ្យកាន់តែច្បាស់។<>នៅក្នុងកំណត់

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ហេតុស្តាប់ចម្លើយរបស់លោក ដែលខ្ញុំទើបតែសំណួរអម្បាញ់មិញនេះ លោកត្រូវបានសួរសំណួរ៣៦ និង៣៧ ដំបូងគេសួរលោកអំពីចាម <ហើយលោកនិយាយ>ថា "នៅកន្លែងខ្ញុំ គឺថាមិនមានចាមរស់នៅទីនោះទេ ប៉ុន្តែមានចិន<មួយចំនួន>"។ <សំណួរ>៖ "តើគេមានៗចាប់ចងចិន<ទាំងអស់នោះ>ទេ?" លោកឆ្លើយថា៖ "គេមិនបានសម្លាប់ចិននោះ<ទេ> ប៉ុន្តែគេបានធ្វើបាបចិនទាំងនោះ"។ អ៊ីចឹងចម្លើយរបស់លោកហ្នឹង<ទំនងដូចចង់ប្រាប់ថា>គេធ្វើបាបចិនដោយសារតែអ្នកនោះ មានឈាមជ័រជាចិន ឬក៏<លោកមិនមែនមានន័យអ៊ីចឹងទេ> ?

**ឆ៖** បាទ អរគុណ។ គេមិនធ្វើបាបអីដូចតែយើង ពួក១៧អ៊ីចឹង ចេញពីទីក្រុងភ្នំពេញដូចតែខ្មែរយើងអ៊ីចឹងចិនហ្នឹង តែគ្រាន់តែថា គេយកទៅដាក់ភូមិនោះ គេហៅថា ភូមិច្រអួល។ ភូមិកប់ខ្មោចភូមិហ្នឹង សុទ្ធតែព្រៃគ្រាច ព្រៃត្បែង ព្រៃឫស្សី ហើយទៅកាប់ឆ្ការហ្នឹង ដើម្បីដាក់ពួកចិនហ្នឹង។ បាទ ចិននៅម្តុំទៅគ្នាវាហ្នឹង ចិនហ្នឹង។ បាទ ហើយចំណែកកម្លាំងពលកម្មចេញមកធ្វើដូចតែគ្នាហ្នឹង ដូចតែយើងអ៊ីចឹងដែរ ដូចតែពួក១៧មេសាហ្នឹង ដូចតែគ្នាហ្នឹង។ បាទ សូមអរគុណ។

**ស៖** ហើយព្រឹកមិញនេះ លោកក៏បានឆ្លើយថា ប្រជាជន១៧មេសា សូមដកស្រង់៖ "គឺថាត្រូវបានគេធ្វើបាបយ៉ាងខ្លាំង"។ តើ<ឥឡូវនេះ លោកចង់និយាយថា>គេធ្វើបាបទៅលើជនជាតិចិន<អ៊ីចឹង>ដែរ<ទេ>?

**ឆ៖** បាទ សូមអរគុណ។ អត់បាន -- វាធ្វើបាប គឺដូចតែគ្នាទេ។ ចិនហ្នឹងក៏ធ្វើកងចល័តដែរ ក៏ទៅធ្វើដូចតែគ្នាហ្នឹង។ កម្លាំងពលកម្ម គឺស្មើគ្នា គ្មានអ្នកណាខ្មែរ -- ពួក១៧គេឲ្យ៣ម៉ែត្រគូប គេឲ្យចិន៤ម៉ែត្រគូបទេ មិនមែនទេ។ ឲ្យដូចតែគ្នា ស្មើភាពគ្នាទេ ព្រោះ១៧មេសា ដូចគ្នា។ គ្រាន់តែថា ពួកចិនស្បែកស គេដាក់ម្តុំប៉ុណ្ណឹងទេ។ បាទ សូមអរគុណ។

[១១:០៨:៤៣]

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី ឥឡូវខ្ញុំសូមចូលទៅប្រធានបទមួយថ្មីទៀត និយាយអំពីមន្ទីរពេទ្យ ហើយនិងថ្នាំពេទ្យ។ នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក <>ERN ជាភាសាអង់គ្លេស 00919930, បារាំង 00922767, ខ្មែរ 00562499<>ឯកសារ E3/5033 លោកបានឆ្លើយថា "នៅក្នុងភូមិនោះ គឺថាប្រជាជនថ្មីហ្នឹង គឺកើតជំងឺគ្រុនចាញ់ <អត់ថ្នាំសង្កូវ មិនមានការព្យាបាល> មិនមានមន្ទីរពេទ្យទៅសម្រាកទេ ហើយនិងដោយសារតែភាពអត់ឃ្លានផង"។ តើ<>លោកសំដៅទៅលើតែឆ្នាំ៧៥ <ឬក៏មិនមានមន្ទីរពេទ្យ នៅក្នុងឆ្នាំ>៧៧ នៅពេលលោកធ្វើការនៅទំនប់ ឬ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

យ៉ាងណា?

**ឆ៖** បាទ សូមអរគុណ។ បញ្ហាថ្នាំសង្កូវ មន្ទីរពេទ្យគេមាន១ ប៉ុន្តែគ្រាន់ថាមន្ទីរពេទ្យនុ៎ងវាគ្មានមនុស្សដេកទេ អត់មានមនុស្សទៅដេកទេ។ ហើយខ្ញុំក៏ធ្លាប់ទៅសុំថ្នាំគេដែរនៅមន្ទីរពេទ្យគេហ្នឹង មន្ទីរពេទ្យនៅភូមិសំរោងហ្នឹង មន្ទីរពេទ្យភូមិសំរោងមាន ប៉ុន្តែគេឲ្យថ្នាំអាចម៍ទន្សាយតែខ្ញុំ ឲ្យថ្នាំអាចម៍ទន្សាយ។ ខ្ញុំគ្រុនគេឲ្យអាចម៍ទន្សាយ ខ្ញុំហើមក៏គេឲ្យអាចម៍ទន្សាយ។ បាទ វាមានតែប៉ុណ្ណឹង បាទ។

**ស៖** <ខ្ញុំរៀបសំណួរខ្ញុំឡើងវិញ> អ្នកធ្វើការនៅការដ្ឋានទំនប់ត្រពាំងថ្ម ពេលដែលឈឺហ្នឹង <តើ>ក្រោយមកត្រូវគេបញ្ជូនមកឲ្យសម្រាកនៅមន្ទីរពេទ្យដើម្បីឲ្យជាសះស្បើយដែរទេ?

**ឆ៖** បាទ សូមអរគុណ។ ខ្ញុំមិនសូវដឹងទេ រឿងថាអ្នកឈឺហ្នឹងបញ្ជូនមកមន្ទីរពេទ្យ ខ្ញុំអត់ដឹងមន្ទីរពេទ្យនៅអាងត្រពាំងថ្ម នៅត្រង់ណាខ្ញុំអត់ដឹងដែរ អត់បានដឹង។ បាទ សូមទោសខ្ញុំអត់បានដឹងទេ រឿងមន្ទីពេទ្យគេហ្នឹង ខ្ញុំអត់ដែលបានដឹង។ ខ្ញុំរស់នៅ១ទំនប់ត្រពាំងថ្មហ្នឹង តែខ្ញុំមិនដែលទៅពេទ្យ១ ចល័តខ្ញុំមិនដែលទៅពេទ្យផង។ ដឹងតែគេឲ្យថ្នាំមក គេឲ្យខ្ញុំផឹកអ៊ីចឹងទៅ ថ្នាំអាចម៍ទន្សាយគេឲ្យ។ ប្រាប់គេ១ឲ្យមកវិញ តែបើរឿងចំពោះខ្ញុំ ថាឲ្យទៅពេទ្យ ខ្ញុំអត់ដែលទៅសោះ។ បាទ អរគុណ។

[១១:១១:៥៨]

**ស៖** ប៉ុន្តែត្រឹមត្រូវថា មានមន្ទីរពេទ្យមួយ<>នៅស្រុកភ្នំស្រុក? ត្រឹមត្រូវទេ?

**ឆ៖** បាទ សូមទោស បាទ ខ្ញុំអត់បានដឹងទេ។ កាលខ្ញុំនៅក្នុងស្រុកភ្នំស្រុក ខ្ញុំអត់បានទៅដល់ស្រុកភ្នំស្រុកផង ខ្ញុំនៅតែត្រពាំងថ្មអីទៅ ហើយអ៊ីចឹងទេនៅសំរោងអីទៅ ខ្ញុំមិនដែលបានទៅពេទ្យស្រុកទេ អត់ដែលស្គាល់ពេទ្យស្រុកផង។ បាទ សូមអរគុណ។

**ស៖** ឥឡូវនេះ ខ្ញុំសូមអានសំណួរចម្លើយ២៩ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សីរបស់លោក។ សំណួរលេខ២៩ និង៣០៖ “តើមានថ្នាំពេទ្យ និងពេទ្យនៅសាលាស្រុកភ្នំស្រុកទេ?” លោកឆ្លើយថា៖ “បាទ <>មាន<មន្ទីរពេទ្យមួយ និង>ថ្នាំអាចម៍ទន្សាយ”។ តើចំណុចនេះជួយរំឭកដល់ការចងចាំរបស់លោកទេ?

**ឆ៖** បាទ ខ្ញុំចងចាំ ក៏ប៉ុន្តែខ្ញុំមិនដែលថា ខ្ញុំទៅសុំថ្នាំគេនៅសាលាស្រុកភ្នំស្រុកទេ។ ខ្ញុំមិនដែលនិយាយពាក្យហ្នឹងទេ បាទ។ ខ្ញុំចាំ។ បាទ អរគុណ។

**ស៖** ចុះលោកដឹងរបបអាហារសម្រាប់កង<ចល័ត>ពិសេសទេ<>នៅការដ្ឋានទំនប់ត្រពាំងថ្ម?

**ឆ៖** បាទៗ សុំទោស បាទ សូមសួរម្តងទៀត។

**ស៖** សំណួររបស់ខ្ញុំ ថាតើលោកមានបានដឹងអំពីរបបអាហារសម្រាប់កងចល័តពិសេស<នៅ> ការដ្ឋានទំនប់ត្រពាំងថ្មនោះដែរទេ?

**ឆ៖** បាទ សូមអរគុណ។ អាហារកងចល័តនោះ ដូចខ្ញុំបានប្រាប់ថា គេចែករបបជាបបរឈ្នោល ប៉ុន្តែបាយ បានបាយខែប្រាំងៗ បាន។ ដល់ពេលហួសពីខែច្រូតមក គឺធ្លាក់ដល់បបរៗឈ្នោល។ បាទ ប៉ុន្តែរឿងអាហារ ម្យ៉ាងទៀតខ្ញុំអត់ដឹងអាហារហ្នឹង។ ខ្ញុំមិនដែលឮឈ្មោះផង អាហ្នឹង។ ខ្ញុំមិនដែលឮឈ្មោះ បាទ។ សូមអរគុណ។

**ស៖** ខ្ញុំមើលទៅកំណត់ហេតុស្តាប់ចម្លើយសាក្សីរបស់លោកនៅត្រង់សំណួរ៥៥ សួរថា៖“<តើកងចល័តពិសេសនោះមានលក្ខណៈ>ដូចម្តេច?” <ចម្លើយ>៖ “នៅខាងកង<ចល័តពិសេស>ហ្នឹង គឺគេឲ្យយើងហូបបាយរឹង។ ឯ<នៅក្នុងកង>កុមារ<>គេឲ្យហូបបបរ<រាវ>។ បើសិនយើង<ធ្វើការគ្រប់ផែនការនោះ យើងនឹងទទួលបានរបបអាហារពេញ តែបើមិនធ្វើការគ្រប់ផែនការនោះ> គឺត្រូវបានគេដករបបអាហារហ្នឹងពាក់កណ្តាលចេញវិញ។” តើលោកនឹកឃើញចំណុចនេះទេ?

**ឆ៖** បាទៗ ត្រូវហើយ។ អាហារ គេឲ្យយើងហូបបាយៗមែន។ ដូចខ្ញុំថា ខែប្រមូលផល បាយគេដាក់ឲ្យយើងហូបមែន គេដាក់ៗនៅចង្អេរ គេចាក់ក្នុងចង្អេរ ហើយយកស្លឹកចេកគ្រប។ ហើយរុយរោមឡើងខ្មៅ រុយរោម ខ្មៅអស់ហើយ។ មែននិយាយមែន។ ដល់ពេលបានតែប៉ុន្មាន ប្រហែលជាមួយខែទេ បាយហ្នឹង បានធ្លាក់មកដល់បបរវិញ។ ហ្នឹងចំពោះកងចល័ត បាទ។ អរគុណ។

[១១:១៦:០៩]

**ស៖** ឥឡូវនេះ ខ្ញុំសូមសួរអំពីពេលម៉ោងការងាររបស់លោក នៅការដ្ឋានលើកទំនប់នោះ។ លោកបានឆ្លើយថា លោកនឹកឃើញអំពីដំណើរទស្សនកិច្ចរបស់ប្រតិភូចិន ហើយក៏លោកក៏នឹកឃើញថា តាវ៉ាល់ គឺជាអ្នកទទួលខុសត្រូវការដ្ឋានលើកទំនប់នោះទាំងមូល។ លោកនៅនឹកឃើញខែ ឬក៏ឆ្នាំដែលលោកបានធ្វើការនៅឯការដ្ឋានលើកទំនប់នោះដែរឬទេ? តើលោកបានធ្វើការនៅទីនោះរយៈពេលប៉ុន្មានខែដែរ?

**ឆ៖** បាទ សូមអរគុណ។ ខ្ញុំៗនៅកងចល័តត្រពាំងថ្មប្រហែលជាឆ្នាំ៧៧ៗ។ ៧៧ហ្នឹងគឺថា ខ្ញុំនៅរហូតៗដល់បែកៗរបបខ្មែរក្រហម គឺថាខ្ញុំរត់ ខ្ញុំចាំខ្ញុំរត់ពីទំនប់ត្រពាំងថ្មមក រកបងខ្ញុំនៅសំរោង។ ខ្ញុំចាំអ៊ីចឹង ខ្ញុំរត់ពីត្រពាំងថ្មមក មករកបងនៅសំរោង បាទ។

**ស៖** មានភស្តុតាងបញ្ជាក់ថា នៅការដ្ឋាន ការធ្វើការងារ -- ការដ្ឋានលើកទំនប់នោះ គឺថាត្រូវបានបញ្ចប់<ក្រោយពីរ ឬបីខែ>នៅក្នុងខែមេសា ឬក៏ខែឧសភា ១៩៧៧។ ហើយទំនប់នេះ ចាប់ផ្ដើមនៅពាក់កណ្ដាល<ខែកុម្ភៈឆ្នាំ១៩៧៧>។ ចុះពេលទំនប់នោះ ត្រូវបានគេលើករួចរាល់ហើយទៅ តើលោកទៅធ្វើអ្វីទៀត?

**លោក ត្រាវីស ហ្វារ៖**

<លោកប្រធាន ខ្ញុំ>សូមជំទាស់ គឺថាមានភស្តុតាងអំពីអង្គហេតុនេះ ក៏មានឯកសារពីជំនាន់នោះមកផងដែរថា យ៉ាងហោចណាស់ទំនប់នោះ បន្តរហូតទៅដល់រដូវប្រាំង ឆ្នាំ១៩៧៨។ <ដូច្នេះ បើសួរគាត់ថាតើលោកធ្វើអីក្រោយខែឧសភា ឆ្នាំ១៩៧៧, ខ្ញុំ>មិនជំទាស់ទេ។ <ប៉ុន្តែ មិនគួរណាសួរសំណួរសាក្សីថាភស្តុតាងនោះបង្ហាញថា ការសាងសង់ធ្វើនៅតែក្នុងឆ្នាំ> ៧៧<នោះទេ>។

[១១:១៨:៤៨]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមរៀបសំណួរឡើងវិញ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** តើត្រឹមត្រូវទេថា លោកបានធ្វើការនៅការដ្ឋានទំនប់ត្រពាំងថ្មនោះ តែពីរបីខែទេ មិនមែនដល់ទៅពីរបីឆ្នាំ ឬក៏មិនមែនដល់មួយឆ្នាំកន្លះនោះទេ? អ៊ីចឹងមែនឬក៏អត់ទេ?

**លោក សម ស័ក្ដ៖**

**ឆ៖** សូមអរគុណ។ អត់មានពីរបីខែ ខ្ញុំនៅហ្នឹង ខ្ញុំនៅធ្វើហ្នឹងរហូត ធ្វើរហូត ព្រោះខ្ញុំនៅបីដំណាក់កាល។ មុនដំបូង ខ្ញុំនៅក្រោមទំនប់ ស្នាក់នៅក្រោមទំនប់។ រហូតមក ខ្ញុំមកនៅស្នាក់នៅក្បែរស្ពានទី១។ ដំណាក់កាលទី៣ ខ្ញុំមកស្នាក់នៅកន្លែងចុងស្ពាន មុខទ្វារទឹកហ្នឹង កន្លែងប្រឡាយតូចហ្នឹងបុកប្រឡាយតូចហ្នឹង មុខស្ពានហ្នឹង ខ្ញុំមកស្នាក់នៅទីហ្នឹងបីដំណាក់កាល។ អាហ្នឹងហើយ ដែលខ្ញុំបែករបបខ្មែរក្រហមនោះ ខ្ញុំរត់ពីហ្នឹងទៅ ខ្ញុំចាំ បាទ។ ត្រង់ឆ្នាំណាៗ ខ្ញុំអត់បានដឹងឆ្នាំទេ ជំនាន់នោះ ខ្ញុំអត់បានដឹងឆ្នាំទេ។ អត់មានដឹងខែ ដឹងថ្ងៃទេ ជំនាន់នោះ យើងអត់ដឹងទេ។ បាទ សូមទោស សូមអរគុណ។

**ស៖** ប៉ុន្តែការរែកដី សែងដី គឺថាគេនៅបន្តរែកដីលើកទំនប់ហ្នឹងទៀតក្រោយពីចប់ដំណាក់កាលទី១ហើយហ្នឹងដែរឬទេ?

**ឆ៖** បាទ អរគុណ។ ខ្ញុំនិយាយៗទៅ ហើយការដ្ឋានត្រពាំងថ្មនោះ កាលខ្ញុំនៅហ្នឹង ស្ពានហ្នឹង

មិនទាន់ស្មើទេ ស្ពានហ្នឹងនៅគ្រហុកនៅឡើយទេ អត់ទាន់បានចាក់ដីស្មើទេ នៅវាងចុះមុខស្ពាននៅឡើយ –នៅវាងចុះមុខស្ពាននៅឡើយ។ ប៉ុន្តែខ្ញុំនៅការដ្ឋានត្រពាំងថ្មនោះ ខ្ញុំបានគេឲ្យទៅធ្វើស្រែប្រាំងទៀត បាទ ចប់ពីហ្នឹង ទៅធ្វើស្រែប្រាំងទៀត ប៉ុន្តែចំពោះទំនប់នោះមិនទាន់ហើយជាស្ថាពរទេ។ ខ្ញុំទទួលស្គាល់ថា មិនទាន់ហើយទេ ព្រោះស្ពានហ្នឹងមិនទាន់ចាក់ដីស្មើ ស្ពានទី១ហ្នឹង នៅកម្ពស់ខ្ពស់ នៅស៊ីម៉ង់ត៍ហ្នឹងនៅខ្ពស់ មិនទាន់បានធ្វើហើយទេ។ បាទ សូមអរគុណ។

**ស៖** ប៉ុន្តែ នៅពេលលោកធ្វើការនៅដំណាក់កាលទី២ នៅ<>ស្ពានហ្នឹង តើលោករែកដីដែរទេ នៅដំណាក់កាលទី២ហ្នឹង?

**ឆ៖** បាទ សូមអរគុណ។ ដំណាក់ទី២ ខ្ញុំនៅរែកដីនៅឡើយ បាទ ខ្ញុំនៅរែកដីនៅឡើយ ប៉ុន្តែរែកដីហ្នឹង រែកដីនៅឡើយ ប៉ុន្តែគេដកខ្ញុំទៅការដ្ឋានស្ពានស្រែងទៀត។ គេយកឡានៗមានទ្រុងហ្នឹងដឹកខ្ញុំទៅទាំងយប់ ហើយខ្ញុំមិនដឹងថាថ្ងៃណាឆ្នាំណាទេ ខ្ញុំភ្លេចហើយ យូរហើយ តែខ្ញុំចាំតែពីរឡានដឹកទៅការដ្ឋានស្ពានស្រែងហ្នឹង ទប់ស្ទឹងហ្នឹង បាទ ខ្ញុំចាំតែប៉ុណ្ណឹង។ រហូតដល់បែក៧៩ ហ្នឹង បាទ ខ្ញុំមីតទៅរកបងខ្ញុំ។ ខ្ញុំចាំប៉ុណ្ណឹង។ អរគុណ។

[១១:២២:២៥]

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំ។ សហព្រះរាជអាជ្ញាសួរថាតើមានមនុស្សស្លាប់ទេនៅឯការដ្ឋាននោះ? លោកបានឆ្លើយថា លោកមិនបានឃើញមានអ្នកណាស្លាប់ដោយសារតែគ្រោះថ្នាក់ការងារទេ ប៉ុន្តែលោកបានឃើញមនុស្សស្លាប់ដោយសារតែខ្វះចំណីអាហារ និងការងារធ្ងន់ធ្ងរពេក។ លោកចាំថា លោកមានឆ្លើយចំណុចនេះទេ?

**ឆ៖** បាទ ខ្ញុំឆ្លើយ។ ខ្ញុំឆ្លើយថា ខ្ញុំអត់បានឃើញទេ អ្នករែកដីរបួសហ្នឹង ខ្ញុំមិនបានឃើញទេ ប៉ុន្តែការស្លាប់បាត់មនុស្សនេះ ខ្ញុំដឹងថាមាន មានគេយកសម្លាប់ ខ្ញុំដឹង ប៉ុន្តែការខ្ញុំឃើញ ខ្ញុំមិនបាន អត់បានឃើញទេ។ បាទ សូមអរគុណ។

**ស៖** សំណួរខ្ញុំសួរអំពីការងារលើសលប់ ហើយនិងការអត់ឃ្លាន។ <លោកបាននិយាយនៅក្នុងពាក្យសុំតាំងខ្លួនដើមបណ្តឹងរដ្ឋប្បវេណីថា មានមនុស្សច្រើនណាស់ ខ្ញុំ>សូមដកស្រង់<>៖ "<មាន> ប្រជាជនជាច្រើនត្រូវស្លាប់ដោយសារការងារហួសកម្លាំង ហើយនិងភាពអត់ឃ្លាន" បញ្ចប់ការដកស្រង់។ ប៉ុន្តែត្រឹមត្រូវទេដែលថា លោកមិនបានឃើញប្រជាជននេះ ស្លាប់ដោយអត់ឃ្លាន ឬក៏ដោយការងារលើសកម្លាំងហ្នឹងដោយផ្ទាល់ភ្នែកទេ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ហ្នឹងហើយដែលវាខ្វះអាហារហ្នឹងហើយ ធ្វើឱ្យគេឈឺបាក់ទ្រុឌទ្រោមកម្លាំងហ្នឹង។ ក្បាលត្រមោងៗ ក្បាលជង្គង់ត្រមោងៗ ឈឺហើមរហូតដល់គ្នាស្លាប់ហ្នឹង ហ្នឹងហើយ វាជាការខ្វះអាហារ។ បាទ សូមអរគុណ។

**ស៖** បាទ ប៉ុន្តែ អ្នកឈឺទាំងអស់ហ្នឹងគេបញ្ជូនទៅមន្ទីរពេទ្យ ហើយលោកមិនបានឃើញគេស្លាប់នៅឯមន្ទីរពេទ្យហ្នឹងទេ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ខ្ញុំអត់បានឃើញស្លាប់ក្នុងមន្ទីរពេទ្យ ខ្ញុំអត់ដែលស្គាល់មន្ទីរពេទ្យភ្នំស្រុកផង ខ្ញុំអត់ដែលបានទៅផង បាទ។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ សូមអរគុណលោកប្រធាន។

[១១:២៤:៤៣]

**លោក ត្រាវីស ហ្វារ៖**

លោកប្រធាន មុនផ្តល់ពេលវេលាទៅដល់ក្រុមមេធាវីការពារក្តី ខៀវ សំផន ខ្ញុំសូមបញ្ជាក់ចំណុចសម្រាប់ប្រតិចារឹកទាក់ទងទៅនឹងសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំសំណង គឺឯកសារខាងក្រុមមេធាវីការពារក្តី នួន ជា <ដកស្រង់> គឺ ឯកសារ D22/3209/1 គឺ<មិនមែនជា>ពាក្យសុំ<ទេ វាគ្រាន់តែជារបាយការណ៍ពាក្យសុំតាំងខ្លួនដើមបណ្តឹងរដ្ឋប្បវេណី រៀបចំដោយខាង ផ្នែកគាំពារសាក្សី និងអ្នកជំនាញ។ វាគឺជាសេចក្តីសង្ខេបពាក្យសុំតាំងខ្លួនជាដើមបណ្តឹងនេះ ហើយទំនងដូចជាវាមិន>ស៊ីជាមួយនឹង<ពាក្យសុំតាំងខ្លួនរបស់គាត់ទេ ដែលមានលេខ E3/5033។ នៅក្នុងឯកសារ E3/5033> ផ្នែក(គ) សំណួរទី៧ <គេបានសួរ>ដើមបណ្តឹងរដ្ឋប្បវេណី <អំពី>សងសំណង<។ ត្រង់នេះ ទើបនិយាយថា គាត់>សុំជាគោក្របី ឬក៏ផ្ទះសម្បែង មិនបានបញ្ជាក់ថា គាត់បានបាត់បង់ផ្ទះសម្បែងឬក៏បាត់បង់គោក្របីទេ គ្រាន់តែថាស្នើសុំសំណង ជាគោ ជាក្របី ឬផ្ទះសម្បែង។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំមើលទៅឃើញថាម៉ោងដប់មួយ ម្ភៃប្រាំនាទីទៅហើយ អ៊ីចឹង ខ្ញុំមិនអាចបញ្ចប់ការសួរដើមបណ្តឹងនេះ ក្នុងរយៈពេលតែប្រាំនាទីទេលោកប្រធាន។ <ខ្ញុំមិនចង់ធ្វើឱ្យច្របូកច្របល់អីទេ ដូច្នេះ>ខ្ញុំគ្រាន់តែបញ្ជាក់ឱ្យដឹងមុនថា ខ្ញុំ មិនអាចបញ្ចប់សំណួរទាំងអស់ក្នុងរយៈពេលប្រាំនាទីទេ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ទំនងត្រូវការប៉ុន្មានទៅ? ពីព្រោះរសៀលនេះ ម្នាក់ទៀត ក្រែងលោ វាមានបញ្ហាដូចម្សិលមិញ។ បើអាចថែម ១០នាទីបានទេ? ១៥នាទី? បានន័យថា រហូតដល់ដប់មួយសែសិប។ វាអាចមានបញ្ហាប្រឈមលើលោក ខៀវ សំផន អាចបន្តដល់ម៉ោងដប់មួយសែសិប បានទេ? បើបានបន្តទៅធ្វើ បន្តការតាំងសំណួរដេញដោលចុះ។

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំគិតថាប្រហែលជាអាចបាន ក៏ប៉ុន្តែ ខ្ញុំត្រូវការសុំបំភ្លឺជាច្រើនលោកប្រធាន។ យើងមិនមានសំណួរច្រើនទេ<។ ប្រហែលជាលោកប្រធានបានកត់សម្គាល់ហើយថា យើងមិនមានចំណុចជាច្រើនត្រូវសុំការបំភ្លឺអីទេ ហើយយើងក៏មិនបានសួរសំណួរអីដែរ កន្លងមក។> ប៉ុន្តែ<ឥឡូវ ខ្ញុំ>គ្រាន់តែ<ចង់>សុំបំភ្លឺពីអ្វីដែលលោកដើមបណ្ដឹងរដ្ឋប្បវេណីបានឆ្លើយ<នៅថ្ងៃនេះ>។ ខ្ញុំមិនអាចធានាបានថាចប់ត្រឹមម៉ោងដប់មួយសែសិបនាទីនោះទេ លោកប្រធាន វាអាស្រ័យទៅលើខ្លឹមសារសំខាន់ៗ នៃចម្លើយរបស់គាត់នៅទំនប់ត្រពាំងថ្មនោះ <ដែលមានផ្ទុករឿងរ៉ាវនានាសម្រាប់ចោទប្រកាន់កូនក្ដីរបស់ខ្ញុំ។ អ៊ីចឹងហើយ ខ្ញុំមិនអាចទប់ដោយមិនសួរនាំនោះទេ>។ <ដោយស្មោះត្រង់>ខ្ញុំសូមអភ័យទោសលោកប្រធាន ខ្ញុំដឹងថា ខ្ញុំត្រូវការពេលវេលាបន្ថែម <លើពេលវេលាដែលប្រគល់ឲ្យខ្ញុំ ដើម្បីខ្ញុំអាចសួរបញ្ជាក់រឿងរ៉ាវ>ផ្ដល់ឱកាសឲ្យដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះបំភ្លឺ<។> ខ្ញុំគិតថា ម៉ោងដប់មួយសែសិបនាទីហ្នឹង ប្រហែលជាមិនអាចចប់ទេ <ខ្ញុំចង់សួរឲ្យលើសម៉ោងបន្តិច ទោះបីខ្ញុំត្រូវកាត់ម៉ោងខ្ញុំខ្លះពីដើមបណ្ដឹងរដ្ឋប្បវេណីបន្ទាប់ទៀតក្ដី, បើសិនជាចាំបាច់។ ខ្ញុំសូមឲ្យច្បាស់ត្រង់នេះមុនពេលចាប់ផ្ដើមសួរ។>

[១១:២៧:៥៩]

**ប្រធានអង្គជំនុំ៖**

ខ្ញុំអំមិញនិយាយហើយ បញ្ហាពេលវេលានេះវាមិនជាបញ្ហាចោទ អាចផ្ដល់បានវាប្រសើរជាជាងបន្តនៅពេលរសៀលដូចម្សិលមិញ វាមានបញ្ហាប្រឈមលើការដឹកជញ្ជូនបុគ្គលិកត្រឡប់ទៅទីក្រុងភ្នំពេញ ដែលវាកកស្ទះចរាចរណ៍។ ប៉ុន្តែបញ្ហាប្រឈមនៅពេលនេះ គឺរឿងលោក ខៀវ សំផន ដែលជាកូនក្ដីរបស់លោកស្រី តើគាត់អាចទប់ទល់បានត្រឹមរយៈពេលប៉ុន្មាន ប៉ុន្តែយើងបានផ្ដល់ឱកាស នេះគឺថាធ្វើតាមលទ្ធភាពដែលលោកស្រីអាចធ្វើបានធៀបជាមួយនឹងកូនក្ដីរបស់លោកស្រីអាចតស៊ូបាន។ ក្នុងករណីដែលមិនអាចទៅមុខរួច គឺអាចឈប់ត្រឹមហ្នឹង ហើយល្ងាចបន្តទៀត។ យើងសន្សំអ៊ីចឹងទៅ បាន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ន័យថា ពេលវេលារសៀល គឺប្រហែលជាទំនង វាកុំឲ្យប្រឈមដូចម្សិលមិញ។

**កញ្ញា អង់តា ហ្គីសសេ៖**

<ខ្ញុំយល់ច្បាស់ណាស់>លោកប្រធាន <ប៉ុន្តែ ក្នុងករណីនេះ តាមអ្វីដែលលោកប្រធានបានលើកឡើង> ខ្ញុំចង់ផ្តោតទៅលើអ្វីដែលខ្ញុំចង់សួរ<ឲ្យចប់សិន>។ អ៊ីចឹង ខ្ញុំគិតថា ខ្ញុំអាច<ចាប់ផ្តើម និងបញ្ចប់ការ>សួរនៅរសៀលនេះ<។ បន្ទាប់មក ខ្ញុំនឹងដោះស្រាយផលវិបាកនៅពេលដល់វេនដើមបណ្តឹងរដ្ឋប្បវេណីបន្ទាប់>ទៀត លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញឥឡូវថែម ១៥មីនុត ប្រហែលជា ខៀវ សំផន មិនមានបញ្ហាអ្វីទេ ហើយសួរទៅបើ ១៥មីនុតមិនចប់ទេ យើងនឹងបិទ នឹងផ្អាកសវនាការ ហើយនឹងលើកបន្តទៅរសៀល។ យើងធ្វើនេះក្នុងបំណងបញ្ចៀសឲ្យបាននូវស្ថានភាពនៃការប្រឈមដូចម្សិលមិញ មានសភាពតឹងតែងខាងសតិ-អារម្មណ៍របស់បុគ្គលិក១ អ.វ.ត.ក យើងនេះ នៅពេលដែលគាត់ត្រឡប់ទៅ ហើយគាត់មានបញ្ហាកកស្ទះចរាចរណ៍អ៊ីចឹង វាអាចមានបញ្ហា អ៊ីចឹងហើយបានជាយើងសន្សំពេលនេះ ប្រសិនបើអាចយឺតពេលនៅរសៀល អាចបន្តត្រឹម ១៥នាទីអីទៀត កុំឲ្យវាហួសហេតុម្តងហើយម្តងទៀត វាអាច វាមានបញ្ហាប្រឈម ដូចករណីដែលលោកស្រីធ្លាប់បានលើកឡើងហើយ ប្រឈមចំពោះលោក ខៀវ សំផន ដែលមានបញ្ហាយូរ ឬក៏កម្រនៃឈឺឈាប់សម្រាកនេះ គាត់តែងតែមានបញ្ហាពាក់ព័ន្ធនឹងសុខភាពរបស់គាត់។ ហើយអ្នកដទៃទៀតស្រដៀងគ្នាហ្នឹងដែរ។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំដឹងហើយ <ខ្ញុំនឹងមិនខ្ជះខ្ជាយពេលទៀតទេ។>ខ្ញុំធ្វើតាមលទ្ធភាពដែលអាចធ្វើទៅបាន ក៏ប៉ុន្តែខ្ញុំចង់ត្រូវការពេលវេលារសៀលនេះច្រើនដើម្បីសួរគាត់ <បើទោះបីកាត់ពេលវេលាខ្លះពីការតាំងសំណួរបន្ទាប់ទៀតនោះ>។ មិនអីទេអ៊ីចឹងលោកប្រធាន <ខ្ញុំមិនចង់បង្ហួសពេលឲ្យវែងឆ្ងាយទេ។>ខ្ញុំនឹងចាប់ផ្តើមតែម្តងឥឡូវនេះ។

[១១:៣០:៣៧]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោក សម ស័ក្ត ខ្ញុំចង់សូមលោកបំភ្លឺ<រឿងមួយចំនួន>។ <ជាដំបូង>ខ្ញុំសូមណែនាំខ្លួនសិន ខ្ញុំឈ្មោះអង់ តាហ្គីសសេ ខ្ញុំជាសហមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន។ ខ្ញុំសូមឲ្យលោក

បំភ្លឺនូវចម្លើយរបស់លោកមួយចំនួនដែលលោកបានឆ្លើយ។ ចំណុចទី១ ខ្ញុំចង់ដឹងថា តើលោកអាចបញ្ជាក់បានទេ ថាលោកធ្វើការនៅទំនប់ត្រពាំងថ្មនេះ អស់រយៈពេលប៉ុន្មានខែ ប៉ុន្មានឆ្នាំដែរ?

**លោក សម ស័ក្ត៖**

**ឆ៖** បាទ សូមអរគុណ។ ខ្ញុំចាំបានថា ខ្ញុំចេញពីកងកុមារ មកធ្វើទំនប់ត្រពាំងថ្មនេះ អត់ដឹងទេ ថ្ងៃខែឆ្នាំ អត់ដឹងទេ អត់ដឹងថ្ងៃខែឆ្នាំទេ ភ្លេចហើយ ខ្ញុំភ្លេចហើយៗ ប៉ុន្តែដូចជាមិនចាំថា ថ្ងៃមីទ្និងមួយ ធ្វើមីទ្និងមួយគេបានឲ្យខ្ញុំមកហ្នឹង ហៅខ្ញុំមកធ្វើបុណ្យអង្គមីទ្និងៗហ្នឹង អង្គមីទ្និងទៅលើចក្រពត្តិលន់ នល់--

**ស៖** សូមអភ័យទោសលោកដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំសូមកាត់ផ្តាច់លោកព្រោះថាខ្ញុំមានពេលខ្លីណាស់។ នៅក្នុងចម្លើយរបស់លោកគឺឯកសារ E319/19.3.10 នៅក្នុងសំណួរចម្លើយ៩៩ គេសួរលោកថា៖ “នៅពេលណាលោកទៅធ្វើការនៅទំនប់ត្រពាំងថ្មនោះ? លោកបានឆ្លើយថាលោកទៅធ្វើការនៅទីនោះប្រហែលជាឆ្នាំ១៩៧៧”។ អ៊ីចឹង លោកនៅចងចាំអំពីចំណុចហ្នឹងទេ?

**ឆ៖** បាទ ត្រឹមត្រូវ ខ្ទង់ឆ្នាំ៧៧ បាទៗ ត្រូវហើយៗ។

**ស៖** តើលោកចាំទេថាលោកចាកចេញទៅធ្វើការហ្នឹងក្នុងរដូវណា ឬក៏ពេលណាដែរ?

**ឆ៖** បាទ អរគុណ ខ្ញុំចាំថាខ្ញុំទៅធ្វើការដ្ឋានត្រពាំងថ្ម គឺរដូវៗប្រាំង រដូវៗគេបានបាយហូបឆ្អែរដូវហ្នឹងធ្វើបាយហូប ខ្ញុំចាំរដូវប្រាំង។ បាទៗ អរគុណ។

**ស៖** ខ្ញុំសួរសំណួរនេះពីព្រោះថានៅក្នុងចម្លើយរបស់លោកនៅក្នុងឯកសារដដែលហ្នឹងគឺ ក្នុងចម្លើយទី១១២ លោកបាននិយាយថា៖ “<ខ្ញុំ>បានធ្វើការនៅទំនប់ត្រពាំងថ្មពីឆ្នាំ៧៧ហ្នឹង រហូតដល់របបខ្មែរក្រហមបែក។” <ដូច្នេះ គឺមុន និងក្រោយបន្តិច ខែមករា ឆ្នាំ១៩៧៩។ តើលោកនៅចាំទេ តើលោកអាចបញ្ជាក់ចម្លើយរបស់លោកទេ>?

**ឆ៖** បាទៗ អរគុណ។ សូមអធ្យាស្រ័យ ខ្ញុំអត់បានចាំថ្ងៃខែទេ ជំនាន់នោះ គ្មានថ្ងៃខែឲ្យយើងដឹងទេ មិនដឹងថាថ្ងៃចន្ទ ថ្ងៃអង្គារ ថ្ងៃពុធទេ មិនដឹងថាថ្ងៃខែ០១ ខែ០២ ខែ៣ទេ អត់បានដឹងទេ បាទ សូមទោស ដឹងតែពីធ្វើ--

[១១:៣៤:០៩]

**ស៖** សូមអភ័យទោសលោក ខ្ញុំសូមអភ័យទោសដែលខ្ញុំកាត់ផ្តាច់លោកភ្លាមៗបែបនេះ ពីព្រោះថាខ្ញុំមានពេលខ្លីណាស់។ ខ្ញុំសួរលោកថាលោកនៅចាំឬក៏អត់? បើលោកមិនចាំ លោកថាឆ្លើយថាមិនចាំទៅ ខ្ញុំនឹងចូលទៅចំណុចផ្សេង។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** បាទ។

**ស៖** លោកបាននិយាយកាលពីព្រឹកមិញនេះ<រហូតដល់ពីរដង> ថាលោក<ចង់>ចាកចេញពីកងកុមារដើម្បីទៅធ្វើការនៅក្នុងកងពិសេស ពីព្រោះថាលោកចង់បានហូបបាយ។ អ៊ីចឹងលោក ខ្ញុំចង់ដឹងថាតើលោកបានស្នើសុំទៅចូលនៅធ្វើការកងចល័តពិសេសហ្នឹងនៅពេលណា? ហើយលោកសុំអ្នកណាដែរ?

**ឆ៖** បាទ អរគុណ។ ខ្ញុំសុំគេចូលជាកងចល័តហ្នឹងពិតមែន ព្រោះខ្ញុំចង់បានបាយហូប ព្រោះនៅកងកុមារយ៉ាប់ពេក ខ្ញុំចង់បានបាយហូប។ ពលកម្មក៏យ៉ាប់ បាយហូបក៏យ៉ាប់ ហូបតែបបរ។ អ៊ីចឹងខ្ញុំចូលកងចល័ត ដើម្បីបានបាយហូបបាន។ អរគុណ។

**ស៖** លោកសុំទៅអ្នកណាគេដើម្បីបានទៅធ្វើការនៅកងចល័តហ្នឹង?

**ឆ៖** បាទ ខ្ញុំៗសូមទោសខ្ញុំភ្លេចហើយ កាលនោះខ្ញុំភ្លេចហើយ យូរពេកហើយ ខ្ញុំភ្លេចហើយបាទភ្លេចហើយ អត់ចាំ ដែលខ្ញុំទៅធ្វើហ្នឹង ខ្ញុំអត់ចាំ កាលរយៈហ្នឹង ខ្ញុំចង់ភ្លេចហើយបាទ។

**ស៖** លោកនឹកទៅមើល លោកសុំមេកងកុមាររបស់លោកមែនទេ?

**ឆ៖** បាទ ប្រហែលជាសុំតាមរយៈប្រធានកុមារ ឈ្មោះ មីណែត។ ប្រធានកងកុមារខ្ញុំ ឈ្មោះ មីណែត ខ្ញុំចាំ។ បែបសុំតាមរយៈប្រធានកុមារខ្ញុំ។ បាទ សូមអរគុណ។

**ស៖** នៅពេលដែលលោកចូលទៅក្នុងកង<ពិសេសនោះ> អ្នកណាជាមេផ្ទាល់របស់លោក? លោកថា តាវ៉ាល់ ជាអ្នកគ្រប់គ្រងការដ្ឋានទាំងមូល អ៊ីចឹងខ្ញុំចង់ដឹងថា មេផ្ទាល់របស់លោកហ្នឹងជាអ្នកណាដែរ?

**ឆ៖** បាទ សូមអរគុណ។ ខ្ញុំ កាលនោះខ្ញុំនៅក្មេង ខ្ញុំអត់បានដឹងថាអ្នកណាជាមេក្រុមរបស់ខ្ញុំទេ ខ្ញុំអត់បានចាំទេ អត់បានចាំថា មេក្រុម មេកង អីទេ។ គ្រាន់តែដឹងថា មេក្រុមហ្នឹង មេក្រុមមើលខ្ញុំប៉ុន្មាននាក់ហ្នឹងតែពួក១៧ដូចគ្នា ពួកអ្នក១៧មេសា ដូចគ្នា។ បាទ អារឿងកង ខ្ញុំអត់ដឹងទេ។ ដឹងតែចល័តរបស់តាវ៉ាល់ ខ្ញុំដឹងតែប៉ុណ្ណឹងទេ។ អារឿងថាកងអីណា ខ្ញុំអត់ដឹងទេ ខ្ញុំនៅក្មេង ខ្ញុំអត់ដឹងទេ។ បាទ សូមអរគុណ។

[១១:៣៧:៣៧]

**ស៖** អម្បាញ់មិញនេះ នៅពេលដែលគេសួរលោកអំពីសមាសភាពកងរបស់លោក លោកនិយាយថា ភាគច្រើនគឺជាអ្នក១៧មេសា ក៏ប៉ុន្តែមានអ្នកមូលដ្ឋានដែរ ប៉ុន្តែអ្នកមូលដ្ឋានហ្នឹងជាអ្នកឃ្លាំ

មើលពួកលោក។ អ៊ីចឹង យ៉ាងហោចណាស់ ក៏មានអ្នកណាម្នាក់ដែលជាអ្នកគ្រប់គ្រងលើលោក ដែលជាអ្នកមូលដ្ឋាន។ លោកចាំទេ អ្នកដែលឃ្លាំមើល ឬក៏គ្រប់គ្រងក្រុមហ្នឹង លោកនិយាយហ្នឹង ថាអ្នកមូល-ដ្ឋានហ្នឹង លោកចាំថាជាមនុស្សប្រុស ឬជាមនុស្សស្រីទេ?

**ឆ៖** បាទ អរគុណ ជាមនុស្សប្រុស។

**ស៖** លោកច្បាស់ទេថា គាត់ជាអ្នកមូលដ្ឋាន?

**ឆ៖** បាទ អត់ច្រឡំទេ ១៧មេសា អត់ច្រឡំទេ និយាយមកខុសគ្នាសម្តី។ ១៧មេសា ផ្សេង អ្នកមូលដ្ឋានផ្សេង និយាយខុស អត់ដូចគ្នាទេ។ បាទ សូមអរគុណ។

**ស៖** លោកមិនទាន់ឆ្លើយទៅនឹងសំណួររបស់ខ្ញុំផង <ខ្ញុំសួរថា> តើ<អ្នកនោះ>ជាអ្នកមូលដ្ឋានមែនទេ <ព្រោះគាត់មានតុងសំឡេងផ្សេង>?

**ឆ៖** បាទ លោកមេធាវីស្តាប់អត់ទាន់ ខ្ញុំថាប្រុស ហើយមូលដ្ឋាន អត់មាន១៧មេសាទេ ពួកមូលដ្ឋាន ព្រោះថាអ្នកមូលដ្ឋាននិយាយសម្តីផ្សេង។ ១៧ និយាយសម្តីផ្សេង អត់មានច្រឡំគ្នាទេ។ បាទ សូមអរគុណ។

**ស៖** នៅក្នុងក្រុមរបស់លោក មានទាំងស្រី ទាំងប្រុសនៅចម្រុះគ្នា ឬក៏មានតែមនុស្សប្រុសទេ?

**ឆ៖** បាទ មានតែប្រុសទេ អត់មានស្រីទេ ខាងក្រុមហ្នឹង ក្រុមរបស់ខ្ញុំ តែបើថារួមគ្នា មានដែលមានស្រី មាន ប៉ុន្តែបើថាក្រុមរបស់ខ្ញុំប៉ុន្មាននាក់ហ្នឹង អត់មានស្រីនៅជាមួយទេ សុទ្ធតែប្រុស បាទ។

**ស៖** លោកបានឆ្លើយថា គឺសុទ្ធតែយុវជន <មានអាយុចន្លោះពី១៦> ទៅដល់២០ឆ្នាំ <ហើយលោកក្មេងជាងគេ>។ អ៊ីចឹងលោកក៏ជាយុវជនដែរ។ ខ្ញុំចង់ដឹងថាអ្នកដែលនៅក្នុងក្រុមរបស់លោកហ្នឹងសុទ្ធតែអ្នកមានប្រពន្ធហើយ ឬក៏ជាអ្នកនៅលីវ?

**ឆ៖** បាទ សូមអរគុណ។ នៅក្រុមរបស់ខ្ញុំហ្នឹង ភាគច្រើនគេមានប្រពន្ធ ព្រោះខ្ញុំហៅគេមិត្តបងៗ គេធំជាងខ្ញុំ។ ខ្ញុំហៅគេមិត្តបង គេអាយុច្រើនជាងខ្ញុំ។ អ៊ីចឹងការសន្និដ្ឋានហ្នងថា គេមានប្រពន្ធ។ បាទ ប៉ុន្តែគេធំគេ មានអាយុច្រើនជាងខ្ញុំ។ បាទសូមអរគុណ។

**ស៖** ឥឡូវនេះខ្ញុំនិយាយអំពីផែនការការងារ កាលពីព្រឹកមិញនេះ លោកបានឆ្លើយថា ផែនការប្រចាំថ្ងៃហ្នឹង គឺ៣ម៉ែត្រគូប ឬក៏២ម៉ែត្រគូប។ ខ្ញុំស្តាប់ឮពីព្រឹកមិញអ៊ីចឹង តើត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** នៅក្នុងរបាយការណ៍ E319/27.4.109/1 មានតែជាភាសាអង់គ្លេសទេ គឺ ERN 0103

1297<>នេះជាចម្លើយដែលសរសេរដោយអ្នកធ្វើរបាយការណ៍ ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេស។ អម្បាញ់មិញនេះ មិនមែនការបកប្រែជាភាសាខ្មែរ ខ្ញុំសូមសួរឡើងវិញ។ <ខ្ញុំសូមដកស្រង់៖> "ពួកគេត្រូវបានចាត់តាំងឲ្យជីកដី៥ម៉ែត្រគូបក្នុងមួយថ្ងៃ។" ដូច្នេះ ខ្ញុំចង់សួរលោកថា តើលោកមានធ្លាប់ឆ្លើយប្រាប់អ្នកណាម្នាក់ថា គេឲ្យធ្វើការជីក រែកដីហ្នឹង ឲ្យបាន៥ម៉ែត្រគូបក្នុងមួយថ្ងៃទេ?

**ឆ៖** បាទ ខ្ញុំដូចជាភ្លេចហើយ។ ដូចជាអត់ចងចាំ ភ្លេច។

[១១:៤២:៤២]

**ស៖** ដូច្នេះ លោកមិនចាំឈ្មោះមេផ្ទាល់របស់លោកទេ ប៉ុន្តែលោកចាំឈ្មោះ តាវ៉ាល់ អ៊ីចឹងខ្ញុំចង់ដឹងថាលោកធ្លាប់មានទំនាក់ទំនង ឬក៏សំណេះសំណាលអីជាមួយ តាវ៉ាល់ ទេ?

**ឆ៖** បាទ សូមអរគុណ។ កុំថាសំណេះសំណាល តែមុខខ្ញុំមិនដែលឃើញផង មើលពីចម្ងាយៗទេ។ នរណាប៉ាននៅក្បែរគាត់លោកអើយ! ជំនាន់នោះគ្មាននរណាប៉ាននៅក្បែរទេ គ្រាន់តែឮឈ្មោះតាវ៉ាល់ៗហ្នឹង។ អត់មាននរណាប៉ាននៅក្បែរគាត់ទេ។ អត់ទេៗ អត់! គ្រាន់តែឮឈ្មោះៗ។ បាទ អត់ដែលឃើញទេ អត់ដែលឃើញមុខគាត់ទេ។ បាទ សូមអរគុណ។

**ស៖** តើអ្នកណាជាអ្នកត្រួតពិនិត្យថាលោកធ្វើការសម្រេចបានតាមផែនការ ឬក៏មិនបានជារៀងរាល់ថ្ងៃនុ៎ង? អ្នកណាជាអ្នកមើលរឿងហ្នឹង?

**ឆ៖** បាទ មានមេក្រុមគេ មានមេកងគេអ៊ីចឹងទៅ។ គេមើលតាម របាយការណ៍ទៅ។ គេវាស់ម៉ែត្រឲ្យយើងស្រាប់ហើយ។ ហើយ មិនហើយគេដឹង គេមិនដឹង? ដឹងតើ។ កុហកគេម៉េចបាន កុហកគេហ្នឹងងាប់ទៀតហើយ ក្បត់ហើយ គេហៅថាក្បត់ទៀតហើយ។ គ្មាននរណាប៉ានកុហកទេ ជំនាន់នោះគ្មាននរណាប៉ានកុហកទេ។ និយាយត្រង់ៗ ការងារនិយាយត្រង់ៗណាស់។ បើកុហកប្រវត្តិរូប គេកុហកបើរឿងកុហកការងារ គេមិនប៉ានកុហកទេ។ បាទ សូមអរគុណ។

**ស៖** តើគេត្រួតពិនិត្យការសម្រេចផែនការហ្នឹងយ៉ាងម៉េចដែរ? គេធ្វើយ៉ាងម៉េច? គេមានមធ្យោបាយអី ដើម្បីវាស់វែងថាធ្វើបានតាមផែនការ ឬក៏មិនបាននោះ? <ហើយដោយនរណាគេដែរ?>

**ឆ៖** បាទ សូមអរគុណ។ ជំនាន់នោះអត់មានម៉ែត្រវាស់ទេ។ វាស់ដងចប បាទ វាស់ៗនេះ គេវាស់ដងចប គេវាស់ *(ឮមិនច្បាស់)* គ្រប់១ម៉ែត្រអ៊ីចឹងទៅ គេវាស់មួយដងចបគេកាប់ គេ-ច។ គេហៅ "ច"។ កាប់ពីប១ម៉ែត្រៗ គ្រប់ម៉ែត្រទៅ គេដឹងរបស់គេ។ បាទ មានតែប៉ុណ្ណឹង អត់មានម៉ែត្រតោងខ្សែអីទេ អត់ទេ។ គេវាស់ដងចប។ បាទ សូមអរគុណ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១១:៤៥:២២]

**ស៖** ចុះមេក្រុមរបស់លោកនេះ ដែលថាលោកមិនចាំឈ្មោះហ្នឹង គាត់គ្រប់គ្រងទៅលើ<ការស្នាក់នៅ> ហើយនិងការហូបចុករបស់<ក្រុមហ្នឹង មែន>ទេ?

**ឆ៖** បាទ សូមអរគុណ។ មេក្រុមនេះ គេគ្មានគ្រប់គ្រងការងារហូបចុកទេ អត់ទេ ហូបរបបស្មើភាពគ្នា អត់មានគេមេក្រុម គេលើសយើងមួយស្លាបព្រា អត់ទេ ស្មើគ្នា។ គេគ្រប់គ្រងតែការងារគ្រប់គ្រងតែការងារ គេមេក្រុមគ្រប់គ្រងការងារ ហើយមេក្រុមធ្វើដូចតែយើងអ៊ីចឹង ដូចតែគ្នាអ៊ីចឹង។ មេក្រុមចង់យ៉ាប់ជាងយើងផង គេអ្នកកាប់ ហើយយើងរែកហ្នឹង យើងដឹងតែពីរែកទៅ គេអ្នកកាប់ឱ្យយើង មើលតែយើងហ្នឹង បាទ មានតែប៉ុណ្ណឹង។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រីមេធាវី។ អរគុណដើមបណ្តឹងរដ្ឋប្បវេណី។

អញ្ជើញមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី? បានហើយម៉ោងប៉ុណ្ណឹង អាចចាំល្ងាចបន្តទៀតចុះ!

[១១:៤៦:២៩]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមការបំភ្លឺមួយ ពីព្រោះថាសហភាតារបស់ខ្ញុំ មានកំហុសឆ្គងនៅពេលដែលគាត់ដកស្រង់របាយការណ៍របស់អង្គភាពជនរងគ្រោះ។ គឺរបាយការណ៍ហ្នឹង គឺពាក់ព័ន្ធទៅនឹងដើមបណ្តឹងក្រោយទេ លោកប្រធាន <មេធាវីនេះដកស្រង់>ឯកសារ <E319/27.4.0109> ហ្នឹង គឺមានបញ្ជាក់ថាមាន៥ម៉ែត្រគូប ក៏ប៉ុន្តែនៅក្នុងរបាយការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះគឺអត់មានទេ។ ខ្ញុំគិតថា <ថាតើ>គាត់ច្រឡំ គាត់ដកស្រង់ហ្នឹង <អ៊ីចឹង គាត់ត្រូវឱ្យឯកសារយោងមកយើងឱ្យបានត្រឹមត្រូវ និងច្បាស់លាស់ផង>។

**កញ្ញា អង់តា ហ្គីសសេ៖**

ឯកសារដែលខ្ញុំដកស្រង់ គឺ E319/27.4.109/1។ ខ្ញុំៗភ័ន្តច្រឡំទេ ខ្ញុំដកស្រង់ដើមបណ្តឹងផ្សេងទេ សុំទោស។

**ប្រធានអង្គជំនុំ៖**

បាទ--

[១១:៤៧:៣៣]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធានៗ បញ្ចាក់អម្បាញ់មិញថា ខ្ញុំអស់ម៉ោងហើយ ឬក៏យ៉ាងម៉េចលោកប្រធាន?

**ប្រធានអង្គជំនុំ៖**

ខ្ញុំគិតថា ពេលវេលាសមស្របនឹងសម្រាកហើយ ក្រែងលោលោកស្រីតវ៉ា ដោយសារកូនក្ដីរបស់លោកស្រី គាត់មិនអាចទប់ទល់បានរហូតដល់ពេលម៉ោងដប់ពីរ។ អ៊ីចឹង យើងសម្រេចថា សម្រាកត្រឹមហ្នឹង ហើយលោកទៅបន្តស្ដាប់សាក្សីរូបនេះ ដែលលោកស្រីនឹងអាចសួរនៅរសៀលទៀត។

បាទ ឥឡូវនេះ ដល់ពេលសម្រាកថ្ងៃត្រង់ហើយ។ អង្គជំនុំជម្រះ ប្រកាសសម្រាកត្រឹមនេះ ហើយសវនាការ បន្តធ្វើនៅរសៀលនេះ នៅវេលាម៉ោងមួយកន្លះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយនៅរសៀលនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្ដាប់ការឆ្លើយតបរបស់ដើមបណ្ដឹងរដ្ឋប្បវេណី សម ស័ក្ក ទៅនឹងសំណួររបស់សហមេធាវីការពារក្ដីលោក ខៀវ សំផន បញ្ចប់ ហើយនិងស្ដាប់សេចក្ដីថ្លែងរៀបរាប់ទុក្ខសោកវេទនារបស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-994។ ហើយអង្គជំនុំជម្រះ សូមអរគុណលោក សម ស័ក្ក។ បាទ ឥឡូវនេះ ការស្ដាប់សេចក្ដីថ្លែងរៀបរាប់ទុក្ខសោកវេទនារបស់លោកនៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះត្រូវការស្ដាប់បន្តទៀត នៅរសៀលនេះ នៅម៉ោងមួយកន្លះ។

ឥឡូវនេះ លោកអាចសម្រាកបានហើយ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណីនេះ នៅក្នុងបន្ទប់រង់ចាំរបស់សាក្សី ហើយនិងឱ្យអញ្ជើញគាត់រួមទាំងបុគ្គលិកអង្គការ ធី.ភី.អូ មកកាន់កន្លែងផ្ដល់ចម្លើយនៅក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងមួយកន្លះ។ បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំ ខាងក្រោមសាលសវនាការនេះ និងបង្គាប់ឱ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការវិញ នៅក្នុងបន្ទប់សវនាការនេះ នៅរសៀលនេះ ឱ្យបានមុនម៉ោងមួយកន្លះ។

បាទ សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ។

*(សវនាការសម្រាកពីម៉ោង ១១:៤៩ នាទី ដល់ម៉ោង១៣:៣០ នាទី)*

[១៣:៣១:០៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយតទៅនេះ ផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានការឱកាសបន្តការតាំងសំណួរចំពោះដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរម្តងទៀត លោក សម ស័ក្ត។ កាលពីព្រឹកមិញ លោកបាននិយាយជាមួយនឹងសហព្រះរាជអាជ្ញាអំពីបរិមាណការងារដែលត្រូវបំពេញ ហើយលោកផ្តល់ចម្លើយ<មួយ>ខុសពីចម្លើយដែលលោកបានឆ្លើយនៅក្នុងកិច្ចសម្ភាសន៍របស់លោកជាមួយនឹងអ្នកស៊ើបអង្កេត គឺឯកសារ <E319/19.3.10> សំណួរ<ទី>១៣២៖ "តើមានកំណត់ទំហំការងារឲ្យប្រជាជនធ្វើ<>ដែរ<ទេ>? <ចម្លើយ៖> សម្រាប់<វេន>ពេល<>ថ្ងៃ គេកំណត់<ឲ្យ>រែកក្នុងម្នាក់<ដី១>ម៉ែត្រ<គូបក្នុង>មួយថ្ងៃ ប៉ុន្តែសម្រាប់<វេន>ពេលយប់ មិនមានកំណត់ទំហំការងារទេ"។<បញ្ចប់ការដកស្រង់។> តើមួយណាត្រូវ? មួយណាខុស? តើ១ម៉ែត្រគូបក្នុងមួយថ្ងៃនៅពេលថ្ងៃ ហើយពេលយប់នោះ មិនមានកំណត់អីទេ ឬក៏លោក ដូចពាក្យដែលលោកបាននិយាយថា ពីរបី<>ម៉ែត្រគូប ដែលលោកបាននិយាយមុននេះកាលពីព្រឹកមិញនេះ?

**លោក សម ស័ក្ត៖**

**ឆ៖** បាទ ខ្ញុំបាទនឹកឃើញហើយថា ពេលនោះ ខ្ញុំ ថា១ម៉ែត្រគូបមែន ត្រូវហើយ ១ម៉ែត្រគូប។ ហើយពេលយប់គ្មានកំណត់ទេ ធ្វើកំណត់ម៉ោង បើម៉ោងដប់ គឺឡើង។

**ស៖** តើលោកអាចបញ្ជាក់បានដែរឬទេ <ព្រោះអ្នកបកប្រែមិនច្បាស់ថា តើ១>ម៉ែត្រគូប<ក្នុងមួយថ្ងៃ ឬយ៉ាងណា>?

**ឆ៖** បាទ មិនមែន ១ម៉ែត្រទេ បែបខ្ញុំច្រឡំ ខ្ញុំទទួលស្គាល់ថាខ្ញុំច្រឡំ មិនមែន ១ម៉ែត្រទេបាទ។

**ស៖** អ៊ីចឹង ខ្ញុំចង់សួរលោកថា លោកជ្រើសយកចម្លើយមួយណាឥឡូវ? ១ម៉ែត្រគូប ឬក៏យ៉ាង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ម៉េច?

**ឆ៖** បាទ ខ្ញុំជ្រើសរើសយកចម្លើយ ៣ម៉ែត្រគូប។

[១៣:៣៤:៣៤]

**ស៖** នៅក្នុង<កំណត់ហេតុនៃការស្តាប់ចម្លើយ>របស់លោក លោកឆ្លើយទៅអ្នកស៊ើបអង្កេតហ្នឹង គឺថាលោកបែងចែក<ពលករ>ការងារពេលយប់ ហើយនិងពេលថ្ងៃ។ អ៊ីចឹង លោកអាចបញ្ជាក់បានទេ ពីរបៀបរៀបរយការងារហ្នឹង ការងាររបស់អ្នកយប់យ៉ាងម៉េចដែរ? អ្នកថ្ងៃយ៉ាងម៉េចដែរ?

**ឆ៖** បាទ ថ្ងៃៗយើងធ្វើកំណត់ម៉ែត្រ បាទ កំណត់ម៉ែត្រ កំណត់ម៉ោង។ មើលតែម៉ោងដប់មួយយើងឡើងទៅ។ ម៉ោងមួយចុះ ម៉ោងប្រាំឡើងទៅ ហ្នឹងកំណត់ម៉ែត្រ។ ដល់ពេលយប់ យើងអត់កំណត់ទេ យើងធ្វើតាមដំណើរហ្នឹង ឧបមាថាកំណត់ម៉ោងដប់ គឺឡើង យប់ បាទ។

**ស៖** ប៉ុន្តែនៅក្នុងកំណត់ហេតុរបស់លោកនេះ ចម្លើយ១៣២នេះ លោកនិយាយថា អ្នកធ្វើការពេលថ្ងៃនេះ ខុសពីអ្នកធ្វើការពេលយប់គឺថា គេមានប្តូរវេនគ្នា។ តើលោកអាចពន្យល់បានទេ ម៉េចក៏ឆ្លើយនៅក្នុងចម្លើយនេះផ្សេង ឥឡូវលោកនិយាយផ្សេង?

**ឆ៖** ខ្ញុំអត់បាននិយាយថា "ប្តូរវេន" អត់បាននិយាយភាសាហ្នឹង អត់បាននិយាយ អត់មានប្តូរវេនទេ។ មានមនុស្សឯណាត្រូវប្តូរ? អត់មានទេ បាទ។

**ស៖** ខ្ញុំមិនសូវយល់ច្បាស់កាលពីព្រឹកមិញ។ អ៊ីចឹង ខ្ញុំសូមឲ្យលោកពន្យល់ទាក់ទងនឹងប្រភេទការងារដែលលោកបានធ្វើនៅទំនប់១មករា។ តើនៅពេល<ភ្លាមៗ>ដែលលោកចាប់ផ្តើមចូលទៅការដ្ឋាននោះ រហូត ដល់ពេលលោកធ្វើចប់ហ្នឹងគឺថា ដល់ពេលវៀតណាមចូលតែម្តងនោះ តើក្នុងរយៈពេលហ្នឹងតាំងពីដើមដល់ចប់ហ្នឹង លោកធ្វើការតែដដែលទេ ការងារតែមួយដដែលទេ ឬមួយយ៉ាងម៉េច?

**ឆ៖** បាទ មិនមែនមួយ មិនមែនទំនប់១មករាទេបាទ គឺទំនប់អាងត្រពាំងថ្ម។

**ស៖** បាទ សូមអភ័យទោស ខ្ញុំច្រឡំទេ។ ត្រូវហើយ ទំនប់ត្រពាំងថ្មហ្នឹងហើយដែលខ្ញុំចង់និយាយហ្នឹងនោះ។ បាទ សំណួរខ្ញុំសួរហ្នឹងនៅតែដដែលទេ តើគឺថាពេញមួយរយៈពេល តាំងពីដំបូងទីនៅពេលលោកមានវត្តមាននៅទំនប់ត្រពាំងថ្មហ្នឹងរហូតដល់ពេលចប់ហ្នឹង គឺការងាររបស់លោកហ្នឹងគឺការងារដដែលៗតែមួយទេ ឬក៏យ៉ាងណា? ឬក៏លោកធ្វើការខុសគ្នាក្នុងរយៈពេលហ្នឹង?

**ឆ៖** បាទ ខ្ញុំធ្វើរហូតទៅដល់ ខ្ញុំរត់រកបងស្រីខ្ញុំនៅភូមិសំរោងគឺថា ចាប់ពីខ្ញុំនៅកងចល័តត្រពាំងថ្មហ្នឹងមករហូតតែម្តង អត់មានទៅណាទៀតទេ នៅហ្នឹងរហូត ប៉ុន្តែត្រង់ថាទំនប់នោះហើយ មិនទាន់

ហើយ ខ្ញុំថាមិនបានចាំឲ្យហើយទេកាលហ្នឹង អត់ទាន់ហើយទេ មិនបានចាំឲ្យហើយទេ។ តែខ្ញុំនៅ នៅតែទំនប់ហ្នឹងដដែលហ្នឹង នៅលើទំនប់ផ្លូវមុខស្ពានទី១ បាទ ប្តូរទីតាំងពីស្ពានទី១ ចុះទៅនៅក្រោមមុខស្ពានវិញ មុខប្រឡាយ ប្រឡាយតូច។

[១៣:៣៨:៤២]

**ស៖** ក៏ប៉ុន្តែ សំណួរដែលខ្ញុំសួរអម្បាញ់មិញនេះ ចង់និយាយថា ប្រភេទការងារដែលលោកធ្វើហ្នឹងគឺជាការងារដូចគ្នាតាំងពីដើមដំបូងដល់ចប់ ឬយ៉ាងម៉េច? គឺថាការងារហ្នឹងគ្រាន់តែរែកដីទេ ឬក៏ធ្វើអីខុសពីហ្នឹង? <>

**ឆ៖** បាទ ខ្ញុំចប់ពីទំនប់នោះ ខ្ញុំនៅហ្នឹងធ្វើៗស្រូវប្រាំងទៀត ធ្វើស្រែប្រាំងទៀត បាទ ធ្វើស្រែៗនៅអាងទៀត នៅក្រោមអាងត្រពាំងថ្មហ្នឹង រហូតដល់បែក រហូតដល់វៀតណាមវៃចូលមក បានខ្ញុំរត់ចេញពីអាងត្រពាំងថ្មហ្នឹងបាទ។

**ស៖** ដូច្នេះ តាមចម្លើយរបស់លោកនោះ គឺថានៅពេលណាមួយនោះ លោកលែងរែកដីហើយគឺលោកទៅធ្វើ<ការងារ>កសិកម្ម<វិញ>។ អ៊ីចឹង ខ្ញុំយល់យ៉ាងដូច្នេះត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** នៅចម្លើយ១០២ នៃកំណត់ហេតុស្តាប់ចម្លើយរបស់លោកនោះ លោកឆ្លើយដូចតទៅនេះ៖ "ពីដំបូងដោយសារខ្ញុំនៅក្មេងពេក ខ្ញុំនៅតូចពេកហ្នឹង គេឲ្យខ្ញុំបររទេះគោ ដើម្បីដឹកអុសដើម្បីឲ្យគេដាំបាយសម្រាប់កងចល័ត"។<>សូមបញ្ចប់ការដកស្រង់។ អ៊ីចឹងតើជាការត្រឹមត្រូវដែរឬទេ ដូចដែលលោកឆ្លើយទៅអ្នកស៊ើបអង្កេតនោះថា នៅពេលដែលលោកទៅដល់<ការដ្ឋាន>នោះ ពេលដំបូង គឺថាដល់ត្រពាំងថ្មដំបូងនោះ លោកមិនបានចាប់ផ្តើមធ្វើការរែកដី លើកទំនប់នោះទេ?

**ឆ៖** បាទ អរគុណ។ ខ្ញុំនិយាយពីព្រឹកមិញក៏ខ្ញុំនិយាយអ៊ីចឹងដែរ ខ្ញុំថា ទៅដំបូង គេឃើញខ្ញុំនៅតូច គេប្រគល់រទេះមួយ គោមួយនឹម គេឲ្យខ្ញុំដឹកអុសឲ្យចុងភៅដាំបាយ។ ខ្ញុំបានរៀបរាប់ពីខាងដើមហើយបាទ។

**ស៖** ដូច្នេះជាការត្រឹមត្រូវដែរឬទេ ក្នុងការនិយាយថាកងកុមារនោះមិនត្រូវបានគេអនុញ្ញាតឲ្យធ្វើការនៅការដ្ឋានលើកទំនប់ហ្នឹងទេ។ តើនិយាយអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទត្រឹមត្រូវ ព្រោះខ្ញុំមិនដែលឃើញកងកុមារទៅលើកទំនប់ផង ខ្ញុំមិនដែលឃើញ បាទ។

[១៣:៤១:៤០]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** ដូច្នេះ តើជាការត្រឹមត្រូវដែរឬទេ គឺក្រៅពីមេកងរបស់លោក ឬមេក្រុមរបស់លោកនោះ មិនមានអ្នកណាដែលគេទទួលបន្ទុកក្នុងការឃ្លាំមើលលោកទេ តាមដានលោកទេ។ តើនិយាយអ៊ីចឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** នៅពេលដែលលោកឆ្លើយទៅសហព្រះរាជអាជ្ញាកាលពីព្រឹកមិញ លោកបាននិយាយថា លោកបានចូលរួមមើលគណៈប្រតិភូចិន<>ហើយលោកបានចូលប្រជុំមួយផងដែរ។ ហើយតើ -- មីទ្ទិង <ដែលលោកបាន>ចូលរួម<នោះ> ខ្ញុំចង់សួរលោកថា តើនៅក្នុងឱកាសហ្នឹង គេមាន<ពិភាក្សា>អំពី <គោលបំណងនៃ>ការលើកទំនប់ត្រពាំងថ្មហ្នឹងដែរឬទេ?

**ឆ៖** បាទ គេមាននិយាយៗ ត្រពាំងថ្ម គេមាននិយាយ។ ឲ្យយើងខិតខំតាមផែនការរបស់អង្គការ ដែលគេដាក់ឲ្យ បាទ គេនិយាយ។ ជាមីទ្ទិងៗរំឭកខួបឆ្នាំ ថ្ងៃ១៧ មេសាបាទ។

**ស៖** ហើយនៅក្នុងសុន្ទរកថា ដែលលោកបានស្ដាប់នៅថ្ងៃហ្នឹងនោះ តើគេមានពន្យល់ប្រាប់ លោកថាគេសាងសង់ទំនប់ហ្នឹង ដើម្បីអ្វីដែរឬទេ?

**ឆ៖** បាទ សុំទោសបាទ រឿងការណ៍ធ្វើអង្គមីទ្ទិងនេះ គឺខ្ញុំគ្មានចំណាប់អារម្មណ៍ស្ដាប់ក្នុងខួរក្បាល អត់មានចងចាំទេបាទ អត់មានបានចងចាំក្នុងខួរក្បាលខ្ញុំទេ គ្រាន់តែបានៗចូលរួមតែប៉ុណ្ណឹងទេបាទ។

**ស៖** <>នេះជាសំណួរចុងក្រោយរបស់ខ្ញុំ។ នៅក្នុងទម្រង់បែបបទសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោក គឺឯកសារ E3/5033, ERN ជាភាសាខ្មែរ គឺ00562496។ លោកនិយាយ មានឃើញឈ្មោះសាក្សី ចៅ នី។ អ៊ីចឹងខ្ញុំចង់សួរលោកថាតើ ចៅ នី <នេះជាអ្នកណា? តើលោកអាចប្រាប់អង្គជំនុំជម្រះបានដែរទេថា ចៅ នី ហ្នឹងជាដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់>ដែលយើងបានស្ដាប់គាត់នៅក្នុងសំណុំរឿង ០០២/០១ ហ្នឹងឬក៏មិនមែនទេ? ហើយទំនាក់ទំនងសាច់ញាតិរវាងគាត់និងលោកហ្នឹងជាទំនាក់ទំនងអ្វីដែរ? គាត់ត្រូវជាអ្វីនឹងលោក?

**ឆ៖** បាទ ចៅ នី ត្រូវជាបងថ្លៃរបស់ខ្ញុំ។

[១៣:៤៥:១៧]

**ស៖** នៅពេលដែលលោកនិយាយថាបងថ្លៃរបស់លោកនោះ លោកអាចបញ្ជាក់បានទេថា អ្នកណារៀបការជាមួយអ្នកណា បានចេញទៅជាបងថ្លៃលោកហ្នឹង?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** បាទន័យថា បងថ្លៃខ្ញុំគឺបងស្រីខ្ញុំជាប្រពន្ធរបស់គាត់បានហៅជាបងថ្លៃរបស់ខ្ញុំ បាទ។

**ស៖** សូមអរគុណ ដែលបានស្រាយបំភ្លឺ។

**កញ្ញា អង់តា ហ្គីសសេ៖**

<សូមអគុណសម្រាប់ការបំភ្លឺនេះ។> លោកប្រធានខ្ញុំសួរចប់ហើយ សូមអរគុណលោកប្រធាន ដែលបានផ្តល់ពេលវេលាបន្ថែមឲ្យខ្ញុំ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ អរគុណលោក សម ស័ក្ត សវនាការស្តាប់សេចក្តីថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មដែលលោកអះអាងថាលោកបានទទួលរងនៅក្នុងរបបកម្ពុ-ជាប្រជាធិបតេយ្យនោះ ដែលពាក់ព័ន្ធទៅនឹងអង្គហេតុការដ្ឋានទំនប់ត្រពាំងថ្ម បានដល់ទីបញ្ចប់ហើយ។ ហើយលោកអាចសម្រាកបានហើយ ៗដោយឡែកលោក យួន សារ៉ាត់ ដោយសារនៅត្រូវនៅអង្គុយអមដើមបណ្តឹងរដ្ឋប្បវេណីនាពេលបន្ទាប់នេះទៀត។ ដូច្នេះ លោកអាចអង្គុយនៅកន្លែងនោះបានហើយរង់ចាំអង្គជំនុំជម្រះធ្វើសវនាការស្តាប់សេចក្តីថ្លែងរៀបរាប់ទុក្ខសោកវេទនារបស់ដើមបណ្តឹងរដ្ឋប្បវេណីបន្ទាប់ទៀត។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ជូនលោក សម ស័ក្ត វិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ ហើយនិងបង្គាប់ឲ្យអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-994 ចូលមកកាន់កន្លែងដែលរៀបចំឲ្យគាត់អង្គុយថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា និងព្យសនកម្មនៅចំពោះមុខអង្គជំនុំជម្រះក្នុងបន្ទប់សវនាការនេះ។

*(ដើមបណ្តឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

[១៣:៤៨:១៤]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួរស្តីលោកដើមបណ្តឹងរដ្ឋប្បវេណី តើលោកឈ្មោះអី?

**លោក មាន លឿយ៖**

**ឆ៖** បាទ លោកប្រធាន ខ្ញុំបាទ ឈ្មោះ មាន លឿយ។

**ស៖** អរគុណ លោក មាន លឿយ។ តើលោកកើតនៅថ្ងៃខែឆ្នាំណា? លោកចាំដែរទេ?

**ឆ៖** បាទ ខ្ញុំបាទកើតនៅថ្ងៃទី២២ ខែ១២ ឆ្នាំ១៩៥៤។

**ស៖** អរគុណ។ ហើយលោកមាន លឿយ ទីកន្លែងកំណើតរបស់លោកនៅទីកន្លែងណា?

**ឆ៖** បាទ ខ្ញុំបាទ មានស្រុកកំណើតនៅភូមិថ្មល់ដាច់ ឃុំស្រះជីក ស្រុកភ្នំស្រុក ខេត្តបាត់ដំបង។ សព្វថ្ងៃបច្ចុប្បន្ន ភូមិថ្មល់ដាច់ ឃុំភ្នំដី ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ។

**ស៖** ចុះលោកប្រកបមុខរបររកស៊ីធ្វើអ្វីសព្វថ្ងៃនេះ? ហើយឪពុករបស់លោកឈ្មោះអី? ម្ដាយរបស់លោកឈ្មោះអី?

**ឆ៖** បាទ មុខរបររបស់ខ្ញុំសព្វថ្ងៃធ្វើស្រែ។ ហើយឪពុករបស់ខ្ញុំបាទ ឈ្មោះ មាន លុយ។ ម្ដាយឈ្មោះ ប៉ុក ម៉ៃ។

**ស៖** អរគុណ។ ចុះប្រពន្ធរបស់លោកឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** បាទ ប្រពន្ធរបស់ខ្ញុំឈ្មោះ សុខ ហឿន។ ហើយមានកូនប្រាំមួយនាក់ ស្រីប្រាំ១ ប្រុសមួយបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយអង្គជំនុំជម្រះសូមបញ្ជាក់ជម្រាបជូនសាធារណជន និងភាគីជ្រាបផងដែរថាដើមបណ្ដឹងរដ្ឋប្បវេណីនេះ គឺមានបុគ្គលិកអង្គការ ធី.ភី.អូ យួន សារ៉ាត់ អង្គុយក្បែរគាត់ ដើម្បីពង្រឹងអារម្មណ៍របស់គាត់ ដើម្បីឲ្យគាត់ស្ងប់អារម្មណ៍នៅក្នុងអំឡុងពេលដែលគាត់ថ្លែងរៀបរាប់អំពីស្ថានភាពព្យសនកម្មនិងទុក្ខសោកវេទនា ដែលគាត់បានជួបប្រទះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលគាត់អះអាងថា ដូច្នេះនៅក្នុងពាក្យបណ្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្ប វេណីរបស់គាត់។

លោក មាន លឿយ ក្នុងនាមលោកជាដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងសវនាការ អង្គជំនុំជម្រះផ្ដល់វេទិកាទៅលោក ដើម្បីឲ្យលោកអាចថ្លែងរៀបរាប់ប្រាប់ដល់អង្គសវនាការ អំពីស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មដែលកើតមានចំពោះលោក ដូចជាការខូចខាតខាងផ្លូវចិត្ត ផ្លូវកាយសម្ភារៈ ដែលជាព្យសនកម្មផ្ទាល់ខ្លួន ដែលជាបច្ច័យដោយផ្ទាល់ពីបទឧក្រិដ្ឋកើតមានឡើង មានពិតប្រាកដរហូតដល់សព្វថ្ងៃនេះ ដែលនាំឲ្យលោកសម្រេចខ្លួនតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងរឿងក្ដីនេះ ដែលពាក់ព័ន្ធទៅនឹងឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់លើជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន ដែលលោកអះអាងថាប៉ះពាល់ចំពោះខ្លួនលោក ហើយចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥ រហូតដល់ថ្ងៃ០៦

ខែមករា ឆ្នាំ៧៩ ពាក់ព័ន្ធនឹងអង្គហេតុចោទប្រកាន់ ជាពិសេសគឺការដ្ឋានការងារទំនប់ត្រពាំងថ្ម។ ហើយតាមសំណើសុំរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី តទៅនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហមេធាវី ដើម្បីសាកសួរអំពីស្ថានភាពទុក្ខសោកវេទនា និងព្យសនកម្មទាំងឡាយដែលកើតមានចំពោះដើមបណ្ដឹងរដ្ឋប្បវេណី មាន លឿយ។ សូមអញ្ជើញ!

[១៣:៥១:៣៩]

**លោក ពេជ អង្គ៖**

បាទ សូមអរគុណលោកប្រធាន។ តាមការពិត លោក មាន លឿយ មានការឈឺធ្មេញបន្តិចបន្តួច អាចប៉ះពាល់ទៅដល់ការនឹកឃើញបន្តិចបន្តួចរបស់គាត់ អំពីព័ត៌មានរបស់គាត់។ ដូច្នេះហើយបានយើងខ្ញុំស្នើសុំ ដើម្បីឲ្យជាសក្ខីកម្មរបស់គាត់នាំមុខទៅដោយសំណួរ។ ដូច្នេះសូមលោកប្រធានអនុញ្ញាតឲ្យលោកស្រី ស៊ីន សុវ៉ន លើកជាសំណួរសួរដល់លោក មាន លឿយ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

សូមអញ្ជើញ!

**លោកស្រី ស៊ីន សុវ៉ន៖**

ចាស សូមអរគុណលោកប្រធាន សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម និងសូមគោរពអង្គសវនាការទាំងមូល។ ចាស នាងខ្ញុំឈ្មោះ ស៊ីន សុវ៉ន ជាមេធាវីនៅអង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ហើយជាមេធាវីតំណាងឲ្យដើមបណ្ដឹងការពារ -- តំណាងឲ្យលោកដើមបណ្ដឹង មាន លឿយ។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ស៊ីន សុវ៉ន៖**

**ស៖** ចាស ខ្ញុំសួរសំណួររបស់លោក មាន លឿយ ពាក់ព័ន្ធនឹងព្យសនកម្ម ពាក់ព័ន្ធទៅនឹងការឈឺចាប់ផ្លូវកាយ ផ្លូវចិត្ត និងផ្នែកសម្ភារៈ ដែលគាត់ទទួលរងកាលសម័យកម្ពុជាប្រជាធិបតេយ្យ ហើយបានបន្សល់ទុករហូតដល់សព្វថ្ងៃហ្នឹង។ ចាស អ៊ីចឹងខ្ញុំចង់សួរលោកថា មុនថ្ងៃ១៧ មេសា ឆ្នាំ៧៥ តើលោក និងក្រុមគ្រួសារលោករស់នៅភូមិឃុំណា? ហើយលោកប្រកបមុខរបរធ្វើអ្វីដែរ?

**លោក មាន លឿយ៖**

**ឆ៖** បាទ មុនឆ្នាំ១៩៧៥ ខ្ញុំបាទរស់នៅភូមិថ្នល់ដាច់ ឃុំស្រះជីក ស្រុកភ្នំស្រុក ខេត្តបាត់ដំបង។ ប៉ុន្តែនៅពេលនោះ ឆ្នាំ១៩៧២ ខ្ញុំបានបួសជាព្រះសង្ឃ គង់នៅវត្តពិសេសមុន្នីបូរ ហើយបន្ទាប់មកទៀតខ្ញុំនៅវត្តមុន្នីបូរបានមួយព្រះវស្សា ក៏ត្រឡប់មកសិក្សាឯខេត្តបាត់ដំបង នៅវត្តភ្នំសំពៅ។ បាទ ឆ្នាំទី១។ ឆ្នាំទី២ ខ្ញុំបានទៅសិក្សានៅវត្តជលធារាសម្បត្តិ ជប់ ស្រុកព្រះនេត្រព្រះ។

[១៣:៥៣:៥១]

**ស៖** ចាស ខ្ញុំសូមអរគុណ។ អ៊ីចឹងការរស់នៅរបស់លោក ដែលលោកបួសធ្វើជាលោកនៅវត្តបូរហ្នឹង គឺលោកបួសតាំងពីឆ្នាំ១៩៧២ រហូតដល់ឆ្នាំ១៩៧៥ តើលោកនៅបួសជាលោក ឬក៏លោកសឹកជាមនុស្សធម្មតាហើយ?

**ឆ៖** បាទ នៅឆ្នាំ១៩៧៥ ខ្ញុំបាទក៏បានវិលត្រឡប់ពីវត្តជលធារាសម្បត្តិ ទៅនៅវត្តបូរ វិញ ស្រុកភ្នំស្រុក ហើយពេលនោះ នៅវត្តនោះ ក៏ជាថ្ងៃមួយ ខ្មែរក្រហមរំដោះបាននៅស្រុកភ្នំស្រុក ពេលនោះ ខ្ញុំបាទក៏ចូលទៅដល់វត្តរបស់ខ្ញុំហ្នឹង មានលោកចំនួន២០អង្គ ទាន។ ហើយក្នុងនោះដែរ ក៏ពពួកយោធាខ្មែរក្រហម គេបានប្រកាសសុំឲ្យប្រជាពលរដ្ឋដែលនៅក្នុងភ្នំស្រុកទាំងមូល ប្រាំពីរភូមិហ្នឹង គឺឲ្យមកជួបជុំគ្នានៅវត្តរបស់ខ្ញុំបាទហ្នឹង គឺថាក្នុងទីអារាមហ្នឹងណែន បាទ មួយភ្នំស្រុកទាំងអស់ វាមានប្រាំពីរឃុំ គឺថាណែននៅនឹងវត្ត។ ហើយប្រកាសថា ពួកទាហាន លន់ នល់ អ្នកមានបណ្ដាស័ក្តិ ឲ្យឈរទៅតាមអ្នកមានបណ្ដាស័ក្តិ ពលទោធ្វើតាមពលទោ ប្រជាពលរដ្ឋគឺនៅតាមប្រជាពលរដ្ឋ។ ពេលនោះគឺយប់ប្រហែលជាម៉ោងប្រាំបី គេបានប្រកាសថា បើបានហើយគេនឹងនាំចេញទៅ អ្នកមានបណ្ដាស័ក្តិ នឹងធ្វើឲ្យមានបណ្ដាស័ក្តិវិញ ហើយពលទោឲ្យទៅដោយឡែក។ ចំណែកប្រជាពលរដ្ឋ ពេលនៅគឺគេឲ្យចេញពីភូមិ ទាំងព្រះសង្ឃ ទាំងអ្នកភូមិ គឺឲ្យចេញតែពីរទិសទេ ទាន ផ្លូវទៅកើតមួយ ផ្លូវទៅខាងជើងមួយ។ ហើយចំណែកខ្ញុំបាទផ្ទាល់ដែលជាអ្នកបួសក៏នាំគ្នាដាំបាយទាំងយប់ដើម្បីប្រការក្រែងអត់ចង្ហាន់។ ខ្ញុំក៏ម៉ោងបួនភ្លឺគឺចេញទៅ។ ចេញទៅៗនៅភូមិថ្នល់ដាច់រយៈពេលប្រាំពីរថ្ងៃ។ បាទ កំណត់ប្រាំពីរថ្ងៃហ្នឹងគេឲ្យចូលមកវត្តវិញ។ បាទ ពេលចូលមកដល់វត្តវិញ ហើយព្រះសង្ឃគ្រប់ព្រះអង្គ វាមានទាំងលោកគ្រូធំៗ លោកទៅរស់នៅវត្តបូរខ្ញុំដែរ។ ពេលនោះ ព្រឹកឡើងពួកទាហានខ្មែរក្រហមជានីរសាររបស់ថៅហ្វាយស្រុកហ្នឹង គេមកប្រាប់រៀលថ្ងៃ។ បាទ គេមកប្រាប់ថា "បងអើយសឹកទៅ គេមិនឲ្យនៅទេ!" ពេលនោះមិនទាន់សឹកទេ ព្រោះថាសេចក្ដីប្រាថ្នារបស់ខ្ញុំបាទផ្ទាល់ សូមជម្រាបលោកប្រធានថា ការ

តាំងចិត្តអ្នកបួសចាប់ពី១០ឆ្នាំ ទៅ១៥ឆ្នាំ បានសឹក ដើម្បីឲ្យបានចេះដឹង។ ដល់ពេលហ្នឹងទៅគឺនៅរយៈពេលបានយូរដែរ នៅនឹងវត្តហ្នឹង ចាប់ពី៧០ ខែ៤ ខែ៥ ខែ៦ ខែ៧ បានដាច់ចិត្តថាសឹក។ គេប្រាប់រាល់ព្រឹក រាល់ល្ងាចៗ ហើយ គឺខ្ញុំបានសឹក ទៅសុំលោកគ្រូធំហ្នឹងសឹក។ លោកថាមួយម៉ាត់ លោកថា៖ "ខ្ញុំករុណាមកពីវត្តឆ្ងាយមកពឹងព្រះអង្គ។ ចុះបើព្រះអង្គសឹក ករុណានៅឯណា?" ពេលនោះខ្ញុំបាទបានគិតលោកថា "ព្រះអង្គតាមព្រះអង្គ! ខ្ញុំករុណាតាមខ្ញុំករុណា!" អ៊ីចឹងពេលហ្នឹងខ្ញុំសឹកមួយព្រឹកពីរអង្គ បាទស្អែកឡើងប្រាំមួយ។ ស្អែកឡើងទាល់តែអស់នៅសល់បីអង្គមិនព្រមសឹកសោះ។ បីអង្គហ្នឹងគឺព្រះអង្គមួយអង្គព្រះនាម ទុយឥន្ទ្រសិទ្ធ ហៅ យុយ សារ័ត្ន។ ព្រះអង្គនៅរៀននៅខេត្តបាត់ដំបង គឺឪប្តូមសាលាបាលី។ នៅពេលនោះលោកថាលោកមិនចង់សឹកទេ លោកចង់ស្វែងរកព្រះពុទ្ធសាសនាឲ្យឃើញ ហើយលោកនេនពីរអង្គនៅកំដរលោក។ បាំងបាន១មួយខែ ក៏គេបញ្ជូនលោកឲ្យទៅនៅខាងឃុំណាំតៅ។ ពេលលោកនេនពីរហ្នឹងជូនដល់ឃុំណាំតៅ លោកនេនពីរអង្គក៏ត្រឡប់មកវិញមកសឹក។ នៅតែព្រះអង្គមិនសឹកទេ។ ពេលនោះទៅបាត់ដំណឹងទៀត គេបញ្ជូនទៅដល់ឧត្តរមានជ័យ ទាន ទៅនៅឃុំបេង។ តែប៉ុណ្ណឹងក៏បាត់ៗសូន្យសឹងរហូតដល់រំដោះឆ្នាំ១៩៧៩ យើងរំដោះបាន។ ហើយឆ្នាំ៨០ ក៏មានមេឃុំខាងឃុំបេងហ្នឹងគេឲ្យដំណឹងថា គេធ្វើបុណ្យលោកសង្ឃមួយអង្គដែលគេបញ្ជូនទៅហ្នឹង ពួកខ្មែរក្រហមសម្លាប់ចោល។ ហើយអ្នកដែលឲ្យដំណឹងហ្នឹងក៏ ខ្ញុំគ្រាន់តែដឹងថាសម័យនោះ គាត់ធ្វើមេឃុំ ប៉ុន្តែឈ្មោះគាត់ខ្ញុំអត់ដឹង ភ្លេចអស់។ ប៉ុណ្ណឹងទៅ បងប្អូនក៏រៀបចំទៅធ្វើបុណ្យ ដោយហេតុដែលគាត់មានអំណះអំណាងគាត់ថា គាត់នៅផ្ទះជិតសាលាស្រុកហ្នឹង សាលាស្រុកខ្មែរក្រហមហ្នឹង ឮគេនិយាយ ឮគេថា "អ្ហឺអ្ហា! អ្ហួតតែងងណា សម្មាសម្ពុទ្ធ! សម្មាសម្ពុទ្ធអី ដែលស៊ូនឹងកំណាត់ផ្គានបាន!" អ៊ីចឹងគេយកកំណាត់ផ្គានហ្នឹងវ៉ៃលោក។ បានគាត់ឮហ្នឹងទៅ គាត់ថា "អូ៎! លោកគឺគេយកទៅសម្លាប់ចោលហើយ" បានគាត់ដើរសង្កេតៗទៅ ឃើញកំណាត់ផ្គានគេបញ្ឈរលើផ្នូរថ្មីមែន ពាក់អង្គសាក់ពីលើបាទ មានតែប៉ុណ្ណោះ។

[១៣:៥៩:៤១]

**ស៖** ចាស សូមអរគុណ។ ចុះក្រោយពេលដែលលោកសឹកហើយ តើគេបង្ខំឲ្យលោកធ្វើអ្វីខ្លះហើយធ្វើហ្នឹងធ្វើការនៅភូមិណាឃុំណាដែរ?

**ឆ៖** បាទ ពេលដែលខ្ញុំសឹកពីបួសទៅ ខ្ញុំរស់នៅក្នុងភូមិថ្មល់ដាច់ ហើយធ្វើការធម្មតាជាមួយនឹងប្រជាពលរដ្ឋទាំងអស់ ហៅធ្វើការកាប់គាស់ លើកភ្លឺស្រែ កាប់ដំបូក កាប់ព្រៃ ហើយជាពិសេសទៅទៀត គឺថាខ្ញុំបាទផ្ទាល់ សូមជម្រាបលោកប្រធាន។ ការសឹកពីបួសហ្នឹង គឺអត់មានខោអាវស្លៀកពាក់ទេ

មានតែស្បង់ដែលនៅសល់ហ្នឹងហើយ យកទៅឲ្យបងស្រីកាត់ដេរធ្វើជាខោឲ្យស្លៀក ហើយយកទៅជ្រលក់នឹងផ្លែដង្កោ។ ពេលហ្នឹង គឺខ្ញុំនៅធ្វើការក្នុងភូមិថ្នល់ដាច់ ផ្ទះសម្ពហភាព បាទ ក្នុងរយៈកាលឆ្នាំ៧៥ ដល់ ចុងឆ្នាំ៧៦។

**ស៖** សូមអរគុណ។ ចាស ក្នុងអំឡុងឆ្នាំណាដែលគេបញ្ជូនលោកឲ្យទៅធ្វើការនៅទំនប់អាងត្រពាំងថ្ម?

**ឆ៖** បាទ នៅចុងឆ្នាំ៧៦ ប្រធានសហករណ៍ឈ្មោះ មិត្តយ៉ាន បានប្រមូលកម្លាំង ដើម្បីឲ្យទៅលើកទំនប់ត្រពាំងថ្ម។ ពេលហ្នឹង គឺគេប្រមូលទៅតាមសហករណ៍ គឺប្រមូលរុញច្រានបណ្ដើរៗៗប្រមូលគ្នាបានច្រើន។ ពេលនោះ ខ្ញុំបាទទៅបានចូលក្នុងកងគេ គឺកង១០០នាក់ ដោយមាន មិត្តថន ហ្នឹងជាប្រធានកង តែកម្លាំងយើងខ្ញុំបានលើកនៅខាងលិចស្ពានទី១ ទីតាំង ហ្នឹងមួយខ្សែត្រៀម។ ដល់ចូលខ្សែត្រៀមទី២ គឺខាងជើង បាទ ស្ពានទី១ ទៅទិសខាងជើង ហ្នឹងមួយទីតាំង រហូត ហើយការធ្វើការហ្នឹង គឺកំណត់ពេលវេលា ដូចពិបាកណាស់ តែភ្លឺរើុងឡើង គឺយើងចេញទៅធ្វើការហើយ ម៉ោងដប់មួយបានគេឲ្យសម្រាក។ សម្រាកមិនទាន់បានប៉ុន្មានផង គេនាំទៅទៀត។ ហើយកម្លាំងធ្វើការក្នុងមួយថ្ងៃ គឺគេកំណត់៣ម៉ែត្រគូប។

[១៤:០២:២៦]

**ស៖** ចាស សូមអរគុណ។ ចាសៗ នៅក្នុងការដ្ឋានទំនប់អាងត្រពាំងថ្ម តើលោកមានដឹងទេ អ្នកណាអ្នកគ្រប់គ្រងនៅក្នុងតំបន់ហ្នឹង?

**ឆ៖** បាទ ក្នុងការគ្រប់គ្រងក្នុងតំបន់នោះ ខ្ញុំមិនដែលស្គាល់គេច្បាស់ទេ ប៉ុន្តែឮឈ្មោះថា តាវ៉ាល់ៗ តែប៉ុណ្ណឹង។

**ស៖** ចុះអ្នកណាជាអ្នកបែងចែកការងារឲ្យលោកធ្វើ ដែលលោកដើម្បីជម្រាបអង្គសវនាការថាមួយថ្ងៃឲ្យបាន៣ម៉ែត្រគូបហ្នឹង អ្នកណាអ្នកបែងចែកការងារហ្នឹងជូនលោកធ្វើហ្នឹង?

**ឆ៖** បាទ អ្នកកំណត់ឲ្យធ្វើហ្នឹង គឺប្រធានកងរយហ្នឹង។

**ស៖** អរគុណ។ ចាស ចុះក្នុងអំឡុងពេលដែលលោកធ្វើការងារនៅទំនប់អាងត្រពាំងថ្មហ្នឹង តើលោកធ្វើតែនៅស្ពានទី១ទេ ឬក៏លោកធ្វើចល័តពីកន្លែងមួយទៅកន្លែងមួយ? លោករៀបរាប់ពីការងារដែលលោកធ្វើនៅអាងត្រពាំងថ្មតាមលំដាប់លំដោយ ជូនអង្គសវនាការដើម្បីបានជ្រាប?

**ឆ៖** បាទ ការធ្វើអាងត្រពាំងថ្មនេះ គេលើកទំនប់ចាប់ពីស្ពានទី១ ទៅដល់ភូមិពង្រ រួចហើយក៏

គេដក់កម្លាំង ទាំងកងខ្ញុំ១០០នាក់ហ្នឹងក៏ទៅដែរ ទៅលើកពីកុងសៀម ទៅតំបន់កូនខ្លែង ភ្នំកូនខ្លែង។ ហើយពេលនោះ មិនមែនទៅតែមួយកង១០០នាក់ហ្នឹងទេ គឺច្រើនណាស់ ព្រោះថាលើកផ្លូវពីកុងសៀម ទៅកូនខ្លែង មិនឃ្ងរទេ។ តាមការប៉ាន់ស្មានរបស់ខ្ញុំ ប្រហែលជាកន្លះខែគឺរួច ព្រោះថ្នល់តូច អត់សូវមានប្រឡាយជ្រៅទេ បាទ។

**ស៖** ចាស។ ចុះរបបការងារនោះ គេឲ្យលោកធ្វើធម្មតា ឬក៏គេមានការកំណត់ម៉ែត្រគូបសម្រាប់ឲ្យធ្វើ?

**ឆ៖** បាទ មិនមែនធម្មតាទេ គេកំណត់ម៉ែត្រគូបដូចគ្នា។ មួយថ្ងៃ៣ម៉ែត្រគូបៗ។

[១៤:០៤:៥៨]

**ស៖** ចុះលោកធ្វើរួចតាមការកំណត់របស់គេ ដែលគេកំណត់ឲ្យលោកធ្វើ ៣ម៉ែត្រគូបៗហ្នឹង លោកធ្វើតាមផែនការរបស់គេហើយទេ? បើលោកធ្វើមិនហើយតើមានអ្វីកើតឡើងចំពោះរូបលោកនុ៎ង?

**ឆ៖** បាទ ការធ្វើនោះហើយ ពេលណាដែលមិនហើយ គេហៅយើងទៅទិតៀន។ ទៅទិតៀនតែម្តង ពីរដង តែបីដង គឺពិបាក។

**ស៖** មានន័យយ៉ាងម៉េចដែរ ថា ទិតៀនម្តង ពីរដង ដល់បីដង ពិបាក។ "ពិបាក" ហ្នឹង មានន័យថាម៉េចដែរ សូមឲ្យលោកជម្រាបពិបាកហ្នឹង ឲ្យច្បាស់បន្តិចមើល៍លោក?

**ឆ៖** បាទ អាពាក្យ "ពិបាក" នេះ បានសេចក្តីថា បើសិនណាជាគេទិតៀនម្តង ទៅពីរដង យើងធ្វើមិនរួច យើងមិនអនុញ្ញាតប្រឹងប្រែង មានតែបាត់ខ្លួន។ បាត់ខ្លួន គឺគេយកទៅសម្លាប់ចោល គេយកទៅរៀនសូត្រ។

**ស៖** ចាស កាលដែលលោកខ្លាចថា ម្តង ពីរដង បាត់ខ្លួន។ កន្លងមក លោកធ្លាប់ឃើញមានការបាត់ខ្លួនហ្នឹងកន្លងរួចហើយ ឬក៏លោកមិនដែលឃើញទេ? លោកធ្លាប់ដែលបានឃើញអ្នកនៅក្នុងកងរបស់លោកមានការបាត់ខ្លួនអ៊ីចឹង ឬក៏ម៉េចដែរ ចាស?

**ឆ៖** បាទ ចំពោះការបាត់ខ្លួននៅក្នុងកងរបស់ខ្ញុំបាទ គឺថាមាន មិនបានឃើញទេ ប៉ុន្តែមានបាត់ ព្រោះមានអ្នកឈឺខ្លះ គ្នាទៅធ្វើការមិនរួច គេថាយើងឈឺសតិអារម្មណ៍។ ស្រាប់តែដល់ពេលយប់ឡើង មេគេហៅទៅណែនាំ បាត់សូន្យមិនឃើញមិនមកវិញ។ អ៊ីចឹងពេលនោះ គឺដឹងតែប៉ុណ្ណឹងទេបាទ។

**ស៖** ចាស អរគុណ។ អ៊ីចឹង មូលហេតុដែលលោកឃើញនៅក្នុងកងរបស់លោកបាត់បន្តបន្ទាប់ហ្នឹងហើយ ដែលធ្វើឲ្យលោកខិតខំធ្វើការងារ អ៊ីចឹងមែនទេលោក? លោកចង់មានន័យថា អ៊ីចឹង បាន--

**ឆ៖** បាទ ពិតប្រាកដហើយ។

[១៤:០៧:៤១]

**ស៖** ចាស អរគុណលោក។ ចុះពាក់ព័ន្ធនឹងរបបអាហារ សម្លៀកបំពាក់នៅសម័យហ្នឹង តើពាក់ព័ន្ធនឹងរបបអាហារក្នុងអំឡុងពេលដែលលោកធ្វើការនៅទំនប់អាងត្រពាំងថ្មហ្នឹង ការហូចចុកគ្រប់គ្រាន់ ឬក៏ម៉េចដែរលោក?

**ឆ៖** បាទ កាលនៅអាងត្រពាំងថ្ម គឺហូបមិនគ្រប់គ្រាន់ទេ។ ដើមដំបូង ការចូលដល់ យើងបានមួយកា ម្នាក់ម្តង។ ផ្លាក់ពីរបីថ្ងៃ មានបបរខាប់ ហើយយូរៗទៅ បែរកែប្រែទៅជាមួយចាន់ចង្កឹះក៏មាន។ មិនគ្រប់គ្រាន់ទេ។ ដូច្នេះ កម្លាំងគឺអត់មាន។ តែដោយសារការខំប្រឹងប្រែង ព្រោះខ្លាច ព្រោះភ័យ ព្រោះថាខ្ញុំធ្លាប់បានឮពាក្យគេថា ចំពោះមុខ កាលខ្ញុំនៅជាព្រះសង្ឃនៅឡើយ។ គេថា លោកសង្ឃហ្នឹង គឺជាល្អើងជញ្ជក់ឈាម បាទ គឺជាល្អើងសម្រាប់ជញ្ជក់ឈាម។ ដូច្នេះ យើងសឹកពីបួសទៅ គឺជាអ្នក១៧មេសា។ គេថាយើងអត់បានលត់ដំខ្លួននៅកន្លែងណាទេ។ ទោះបីឆ្អែតក្តី មិនឆ្អែតក្តី គឺត្រូវតែប្រឹង បាទ ត្រូវតែប្រឹង។

**ស៖** ចាស អរគុណ។ ចាស ពាក់ព័ន្ធនឹងទំនប់អាងត្រពាំងថ្មដែលលោកលើកទំនប់អាងត្រពាំងថ្ម។ តើលោកមានសេចក្តីរីករាយ ឬក៏សប្បាយក្នុងការចូលរួមលើកអាងត្រពាំងថ្មដែលធំល្វឹងល្វើយហ្នឹងទេលោក?

**ឆ៖** បាទ ចំពោះយើងខ្ញុំផ្ទាល់ ហើយនិងបងប្អូនយើងទាំងអស់ ដែលយើងលើកអាងត្រពាំងថ្ម មិនមានការពេញចិត្ត និងសប្បាយរីករាយទេ ព្រោះថាធ្វើនេះ ធ្វើទៅតាមមាគ៌ាដែលអង្គការហ្នឹងដាក់ទិសចំ។ បើយើងមិនធ្វើ ខ្លាចស្លាប់។

[១៤:១០:០០]

**ស៖** ចាស អរគុណ ចាសនៅក្នុងអំឡុងពេលដែលលោកធ្វើការនៅទំនប់អាងត្រពាំងថ្ម ពេលដែលលោកឈឺម្តងៗ តើមានគ្រូពេទ្យព្យាបាលលោក ឬក៏ផ្តល់ជាថ្នាំសង្កូវជូនលោកទេ?

**ឆ៖** បាទ ពេលឈឺម្តងៗ មិនដែលមានពេទ្យទេ យើងគ្រាន់តែរាយការណ៍ឲ្យមេ មេកងហ្នឹងទៅ មេកងគេប្រាប់ពេទ្យ ពេទ្យគេមក ហើយពេទ្យហ្នឹងទៀត ឃើញគេស្ពាយសាក់កាដូរបស់គេហ្នឹងថាសមណាំណាស់ ប៉ុន្តែពេលមកគេស្ពាបមើលលិចកើតទៅ មានតែថ្នាអាចម៍ទន្សាយហ្នឹងឯងឲ្យលេប។ ជំងឺ ១០០មុខ គឺត្រូវតែនឹងអាចម៍ទន្សាយហ្នឹង អត់ដែលមានថ្នាំអីខុសពីថ្នាំហ្នឹងទេ។

**ស៖** ចាស សូមអរគុណ។ ចាស ហើយលោកបានជម្រាបអង្គសវនាការថា ទំនប់អាងត្រពាំងថ្មមានមនុស្សច្រើនលើកនៅអាងត្រពាំងថ្មហ្នឹង កម្លាំងយុវជន កម្លាំងយុវនារី។ អ៊ីចឹង ខ្ញុំចង់ជម្រាបសួរលោកថាតាមការសង្កេត និងតាមការមើលឃើញរបស់លោកកន្លងហ្នឹង ក្នុងអំឡុងពេលដែលលោកធ្វើការនៅអាងត្រពាំងថ្មហ្នឹង តើលោកដែលបានឃើញមានយុវជន យុវនារីហ្នឹង ត្រូវបានគេរៀបការនៅនឹងអាងត្រពាំងថ្មហ្នឹងទេលោក?

**ឆ៖** បាទ មិនដែលមានទេនៅអាង។

[១៤:១១:៤៧]

**ស៖** អរគុណ។ ចុះចំពោះលោកវិញ តើលោកមានបានរៀបការទេក្នុងសម័យខ្មែរក្រហមហ្នឹង?

**ឆ៖** បាទ ខ្ញុំបាទផ្ទាល់ខ្ញុំបានរៀបការនៅសម័យខ្មែរក្រហម។ កាលហ្នឹងខ្ញុំនៅអាងត្រពាំងថ្មហ្នឹងដែរ ប៉ុន្តែមេកងគេប្រាប់ថា ថ្ងៃខានស្អែក គេត្រូវបើក បាទ គេត្រូវបើកឲ្យយើងរៀបការ។ គេប្រាប់ឈ្មោះឲ្យយើងទៅសហករណ៍។ ដូច្នេះ ការរៀបការរបស់ខ្ញុំបាទនេះគឺនៅសហករណ៍១៣ ដែលស្ថិតនៅក្នុងភូមិថ្នល់ដាច់។ អ៊ីចឹងគឺថា ក្នុងការរៀបការរបស់ខ្ញុំបានហ្នឹងគឺថាមានច្រើនណាស់ មានដល់ទៅ ៦៣គូ។ បាទក្នុងចំណោម ៦៣គូហ្នឹង មានមូលដ្ឋាន ហើយមានបងប្អូនយើងជម្លៀសពីទីក្រុងភ្នំពេញទៅ។ ប៉ុន្តែការរៀបការហ្នឹងបានតែគេកំណត់តែមូលដ្ឋាន ទៅមូលដ្ឋាន ហើយអ្នកជម្លៀសទៅតាមអ្នកជម្លៀស គឺអត់ឲ្យលាយឡំគ្នាបានទេ សូម្បីតែអ្នកមូលដ្ឋានចង់បានអ្នកជម្លៀសអី គេដណ្តឹងខ្លះក៏អត់ឲ្យការដែរ។ ដូច្នេះ ពេលនោះ ខ្ញុំបាទដូចជាមានអារម្មណ៍មួយថា មិនទាន់ដែលបានឃើញមុខនារីផង ស្រាប់តែគេឲ្យទៅរៀបការ មិនដឹងរៀបការថាយ៉ាងណា។ បាទ ក្នុងពេលនោះ អាយុខ្ញុំវាច្រើនដែរ ២៣ឆ្នាំហើយ។ ហើយក្នុងការរៀបការហ្នឹងឯង គឺគេឲ្យអង្គុយហែគ្នាជាជួរ រួចក្នុងកណ្តាល ក្នុងទីកណ្តាលពាក់កណ្តាលហ្នឹងគេដាក់កូនតុមួយ ហើយមានដបមួយ គេដាក់ផ្កាមួយពីលើ តែប៉ុណ្ណឹង។ ហើយអ្នករៀបចំហ្នឹងគឺជាតំណាងឲ្យសហករណ៍ ឬក៏តំណាងមកពីស្រុកក៏មិនដឹង ព្រោះខ្ញុំមិនសូវស្គាល់ ស្គាល់តែតំណាងឲ្យសហករណ៍ ប៉ុន្តែមានមនុស្សចម្លែកដែរ។

[១៤:១៣:៤៦]

ពេលនោះពិធីរៀបការចាប់ផ្តើម យើងថាយប់ តាមការប៉ាន់ស្មានប្រហាក់ប្រហែលជាម៉ោងប្រាំបីទៅម៉ោងប្រាំបួនយប់បានគេប្រកាស។ ហ្នឹងគេប្រកាសឲ្យអ្នកទាំងអស់គ្នាហ្នឹងដឹងថា ថ្ងៃនេះអង្គការរៀបការឲ្យអ្នកទាំងអស់គ្នាហើយ ទាំងអស់មាន៦៣គូ តែអ្នកត្រូវប្រព្រឹត្តទៅតាមមាគ៌ារបស់អង្គការ

ទោះបីជាអង្គការឱ្យអ្នកប្តេជ្ញាយ៉ាងណា គឺឱ្យបានយ៉ាងនោះ។ ប៉ុណ្ណឹងទៅគេឱ្យយើងចាប់ដៃគ្នា បាទ ចាប់ដៃគ្នាមួយគូៗទៅ បានគេឱ្យអ្នកកណ្តាលហ្នឹង គេឡើងប្តេជ្ញាដើម្បីអនុវត្តទៅតាមមាគ៌ារបស់អង្គការ ធ្វើយ៉ាងណាមួយហិកតាឱ្យបានបីតោនទៅបួនតោន។ ហើយពាក្យប្តេជ្ញាហ្នឹងក៏មិនដឹងថាយ៉ាងណាដែរ គេឱ្យថាអ៊ីចឹង ចេះតែស្រែក បានស្រែកថា “ប្តេជ្ញា!ៗ” នាំគ្នាលើកដៃទៅ។ បាទ ហើយក្នុងការរៀបការហ្នឹងទៀត មានអ្នកខ្លះមិនដែលស្គាល់មុខគ្នា រៀបការឃើញមុខគ្នាពេលចាប់ដៃ ដល់ពេលចេញមកវិញបាត់គ្នាក៏មានដែរ។ សឹងតែមាន អ៊ីចឹងក្នុងការរៀបការរបស់ខ្ញុំបាទនៅពេលនោះ គឺថាខ្ញុំបាទ ក្នុងនាមជាអ្នកស្រុកស្រែហ្នឹងដែរ ក៏គិតឃើញថា ទោះបីមិនដែលស្គាល់គ្នា មិនដែលបាននិយាយគ្នាយ៉ាងម៉េច អង្គការគេរៀបការឱ្យហើយ គឺថាត្រូវតែមានចិត្តផ្តួចផ្តើម និងស្រឡាញ់រាប់អាន។ ពេលរៀបការហ្នឹងបានប្រាំពីរថ្ងៃ គេឱ្យនៅផ្ទះប្រាំពីរថ្ងៃ បានគេឱ្យលើកប្រព័ន្ធភ្លឺស្រែ នៅស្ពានទី៣ទៀត នៅអាងត្រពាំងថ្មហ្នឹងឯង ចុះពីខាងលិចស្ពានទី៣ ទៅទល់នឹងភូមិតាវង បាទ លើកប្រព័ន្ធប្រឡាយ។ លើកប្រព័ន្ធប្រឡាយហ្នឹង គេឱ្យអ្នកដែលរៀបការទាំង ៦៣គូហ្នឹងទៅទាំងអស់។ ពេលទៅដល់កន្លែងការដ្ឋានលើកប្រព័ន្ធប្រឡាយស្រែប្រាំងហ្នឹង គេឱ្យនៅជាមួយគ្នា ប៉ុន្តែដល់ពេលការស្នាក់នៅវិញ ដេកនៅវិញគឺស្រីតាមកងស្រី ប្រុសតាមកងប្រុស អត់មានដេកលាយឡំគ្នាបានទេ ថ្វីត្បិតតែរៀបការឱ្យមែន។ បាទ រយៈពេលខ្ញុំបាទនឹងបានលើកប្រព័ន្ធប្រឡាយរួច ហើយប្តីប្រពន្ធ គឺបានជួបគ្នាតែពេលបាយទេ ពេលបាយមើលមុខគ្នាបាន តែពេលយប់ អត់មើលមុខគ្នាបានទេ ព្រោះគេកំណត់ថាមិនឱ្យដេកជុំគ្នា។ បាទ ស្រីដេកតាមស្រី ប្រុសដេកតាមប្រុស។ ហើយការលើកប្រព័ន្ធប្រឡាយរួចបានអង្គការដកពួកកងកម្លាំងខ្ញុំបាទហ្នឹងទៅទិសខាងកើតទៀត គឺទៅខាងស្ពានស្រែង បាទ លើកប្រឡាយប្រាសាទប្រាំ អូរតាផលរហូតដល់ភ្នំលៀបទល់ផ្លូវជាតិលេខ៦ហ្នឹង ហើយស្រុកព្រះនេត្រព្រះ។ ពេលហ្នឹងគឺគេឱ្យនៅតាមគ្រួសារបាន បាទ ចេញពីអាងត្រពាំងថ្មទៅ គេឱ្យនៅជាមួយគ្រួសារបាន ហើយយើងខ្ញុំបានលើកប្រឡាយនៅមួយជួរពីស្ពានស្រែងទៅទល់ភ្នំលៀបហ្នឹង ចប់មួយខ្សែ នៅពេលនោះគឺមិនទាន់ចប់រួចរាល់ទេ ដោយពេលយប់នោះគឺភ្លៀង បាទ លើកបានមួយខ្សែត្រៀម ស្រាប់តែពេលមួយខ្សែត្រៀមទៀត បង្ខិតទៅមុខភ្លៀងធំ ដល់ភ្លៀងធំទឹកលិច ក៏គេដកកម្លាំងខ្ញុំបាទហ្នឹងមកនៅតាមសហករណ៍វិញ។

[១៤:១៧:៤៥]

**ស៖** ចាសអរគុណច្រើន។ ពាក់ព័ន្ធនឹងការរៀបការ ខ្ញុំចង់ជម្រាបសួរលោកថា លោកហើយនិងគ្រួសារលោកអត់ដែលស្គាល់គ្នាទេ តើដល់ពេលអង្គការចាត់កំណត់ឱ្យលោករៀបការជាមួយគ្រួសារ

លោក តើលោកមានការពេញចិត្តនឹងប្រពន្ធរបស់លោកហ្នឹងទេ ប្រពន្ធរបស់លោកដែលអង្គការគេតម្រូវឱ្យលោករៀបការជាមួយ លោកមានការពេញចិត្តទេ?

**ផ៖** បាទ *(ឮមិនច្បាស់)* ចំពោះខ្ញុំដោយសារតែខ្ញុំបានសិក្សាខាងគុណធម៌ច្រើន អ៊ីចឹងទោះបីល្អអាក្រក់យ៉ាងម៉េច ចាប់ដៃគ្នាហើយគឺត្រូវតែស្រឡាញ់។

**សៈ** ចាស សូមអរគុណ។ ចាស បន្ទាប់ពីថ្ងៃរៀបការហើយ តើលោកនិងប្រពន្ធលោកយល់ព្រមជាមួយគ្នាក្នុងការរួមដំណេកជាប្ដីប្រពន្ធទេលោក?

**ផ៖** បាទ យើងព្រម។

**សៈ** ចាស អរគុណ។ ចាស ចុះបច្ចុប្បន្ន ប្រពន្ធលោក និងលោករស់នៅជាមួយគ្នា ឬក៏យ៉ាងម៉េចដែរលោក?

**ផ៖** អត់ទេ សូមជម្រាប គ្រួសារខ្ញុំចាប់ផ្ដើមពីដកកម្លាំងមកនៅសហករណ៍មក គឺខ្ញុំបាទហ្នឹងគេឱ្យទៅនៅធ្វើស្រែនៅស្ពានធំ ហើយលលំធំ ខាងឃុំស្ពានស្រែង។ អ៊ីចឹងពេលរដូវវស្សាហ្នឹងគឺគេក៏បានយកឪពុកក្មេកខ្ញុំបាទហ្នឹងទៅសម្លាប់ចោល ដោយបទចោទប្រកាន់ថាគាត់សម័យលន់នល់ ជាមេ៥០ខ្ទង។ បន្ទាប់ពីនោះមក គឺបានគេដកទាំងក្រុមគ្រួសារហ្នឹងឱ្យមកនៅច្រូតស្រូវនៅគោកក្រោល បាទ នៅគោកក្រោល។ ដកពីគោកក្រោលហើយ ទៅនៅនឹងព្រៃកជីក នៅជួរគោកត្រាចហ្នឹង។ ដល់ពេលនោះគេឱ្យកម្លាំងប្រុសៗគឺទៅច្រូតឆ្ងាយ កម្លាំងស្ត្រីៗគឺនៅច្រូតជិតៗ ប៉ុន្តែចុងឆ្នាំ៧៨ហ្នឹង ការជ្រួលច្របល់កើតឡើងដោយប្រជាពលរដ្ឋមិនទុកចិត្តថាជាហេតុអ្វីទេ ព្រោះប្រធានសហករណ៍បានជម្លៀសប្រជាពលរដ្ឋចេញពីភូមិអស់ទៅនៅតាមព្រៃ ទៅនៅតាមទីណាដែលមានតំបន់ត្រពាំងទឹក គេឱ្យទៅនៅឯណោះ ក្នុងភូមិគេអត់ឱ្យនៅទេ។ អ៊ីចឹងគ្រួសារខ្ញុំបាទហ្នឹងគឺ ទាំងរួមទាំងម្ដាយមីង ទាំងបងប្អូនជីដូនមួយដែលរស់នៅច្រូតជុំគ្នាហ្នឹង គាត់ធ្វើដំណើរដើម្បីទៅរកបងប្អូនម៉ែឪ តែខ្ញុំបាទអត់បានដឹងទេ ដើរទៅច្រូតឆ្ងាយពេក ពេលដែលជ្រួលច្របល់ហ្នឹង មិនដឹងថាគេដឹងសភាពការណ៍ពីខាងណាទេ។ ពេលល្ងាច បាទ នាំគ្នាចេញទៅបានយោធាខ្មែរក្រហមហ្នឹងចាប់គ្រួសារខ្ញុំ ម្ដាយមីងខ្ញុំ បងប្អូនជីដូនមួយខ្ញុំទាំងអស់១៣នាក់ បាទ គេបញ្ជូនទៅសាលាស្រុកភ្នំស្រុកហ្នឹង។ ពេលល្ងាចខ្ញុំមកពីច្រូតវិញ បានមកដល់កន្លែង បានបងប្អូនប្រាប់ថា អ្នកដែលនៅនោះប្រាប់ថា ឥឡូវពួកបងប្អូនគ្រួសារមិត្តឯងនេះទៅរកបងប្អូនអស់ហើយ ថាទៅរកឯណាអ៊ីចេះ? ថាទៅលលំធំ។ បានខ្ញុំបាទមិនទុកចិត្ត ខ្ញុំថាបើទៅយើងទៅដែរ ពេលខ្ញុំដើរតាមក្រោយ មកបានជួបបងប្អូននៅនឹងភ្នំស្រុកហ្នឹងបររទេះទៅស្រែទៅដឹកកណ្ដាប់ បានប្រាប់ថាក្រុមគ្រួសារ

ឯងគេចាប់ហើយ។ គេចាប់យកទៅឯណា? ថាគេចាប់យកទៅនឹងសាលាស្រុក។ ខ្ញុំគោលបំណងរបស់ខ្ញុំបាទ គឺចង់ទៅតាមព្រោះថា ពាក្យថាចាប់មួយម៉ាត់នេះគឺគ្មានរស់ទេ តែទៅហើយ ស្លាប់។ អ៊ីចឹងខ្ញុំប្តេជ្ញាចិត្តនឹងទៅតាម បើស្លាប់ៗទាំងអស់គ្នា បើរស់ៗទាំងអស់គ្នា។ ប៉ុន្តែដោយអំណាចបងប្អូនខ្ញុំច្រើនគេបានឃាត់ឃាំងខ្ញុំមិនឲ្យទៅទេ។

[១៤:២២:៣៩]

ហើយគេនិយាយពាក្យមួយទៀតថា បងប្អូនខ្ញុំនិយាយពាក្យមួយទៀតថា បើសិនថាអ្នកឯងទៅពិបាកដោះស្រាយ តែបើទៅតែស្រីៗអ៊ីចឹង អាចគេដោះលែងយើងមកវិញ បានទុកចិត្ត។ រហូតដល់យប់ទៅដេកនៅផ្ទះបងប្អូននៅខាងក្រោយវត្តកណ្តាលយើង ភ្នំស្រុកហ្នឹង បងប្អូនគេដើរសង្កេតមើលៗ ថាគេយកទៅឯណា ឬគេលែងឬអត់។ បាទពេលនោះ គឺមិនមានលែងទេ បាទ គេចាប់យកទៅទិសខាងជើងគេហៅ ភូមិត្រឡាច។ ពេលនោះ គឺគេយកទៅសម្លាប់ចោលបាទ គេយកទៅសម្លាប់ចោល សូម្បីតែក្មេងអាយុពីរឆ្នាំក៏អត់គិតថាអត់ទោស ឬក៏ទុកឲ្យរស់ទៅបានទេ។ ដូច្នេះបងប្អូន ក្រុមគ្រួសារខ្ញុំទាំងអស់វា ១២នាក់ អ្នកដែលស្លាប់ ម្នាក់រត់រួច។ បានបងប្អូននៅជិតខាងហ្នឹង គាត់ប្រាប់ខ្ញុំថាគេយកទៅសម្លាប់ចោលហើយ។ ពេលនោះ ដែលនៅក្នុងនោះមានគ្រួសារខ្ញុំហ្នឹងមួយ ហើយគ្រួសារខ្ញុំមិនដឹងថាមានផ្ទៃពោះឬក៏អត់ទេ ព្រោះយើងបានគ្នាប្តីប្រពន្ធប្រហាក់ប្រហែលពីរ បីខែដែរ បានរួមរស់ជុំគ្នា ហើយប្អូនស្រីបង្កើតរបស់គ្រួសារខ្ញុំហ្នឹងម្នាក់ ម្តាយមីងស្រីពីរនាក់ ហើយបងស្រីម្នាក់ និងកូនមួយ ប្អូនប្រុសពីរនាក់ហើយប្អូនជីដូនមួយបួននាក់ទៀត ក្នុងនោះមានកុមារអាយុពីរឆ្នាំហ្នឹងម្នាក់ អាយុប្រាំឆ្នាំហ្នឹងម្នាក់។ បាទគេសុទ្ធតែអារ-ក គេអត់មានគិតថាធ្វើម៉េចទេ អារ-ក។ ពេលព្រឹកឡើង បងប្អូនខ្ញុំបាទនៅភ្នំស្រុកហ្នឹងគេបញ្ជូនខ្ញុំឲ្យរកផ្លូវចេញ ដើម្បីទៅរកព្រៃត្បែង។ ខ្ញុំបាទដើរចេញទៅដល់ព្រៃ ចេញពីព្រៃ ខ្ញុំចូលមកភូមិវិញ ជួបមេសហករណ៍។ ប្រធានសហករណ៍សួរថា "បងទៅណា?" ថា "ខ្ញុំមកមើលអ៊ំឈឺ"។ ពេលនោះ អ៊ំខ្ញុំមួយក៏ឈឺនៅក្នុងភូមិខ្ញុំហ្នឹងស្លាប់ដែរ ស្លាប់ពេលនោះ។ ប៉ុន្តែដោយខ្ញុំរវៀសរវៃបន្តិច ខ្ញុំឃើញនីរសារគេជិះសេះមក គ្នាខ្ញុំបីនាក់ ដើរជុំគ្នាហ្នឹង ឃើញនីរសារជិះសេះមក បានប្រាប់គេថា ខ្ញុំទៅហើយ។ បាទ ពេលខ្ញុំចេញចូលទៅដល់មាត់ភូមិ គេដេញបាញ់បណ្តោយ។ បាទ ពេលនោះ គឺប្រធានសហករណ៍សុទ្ធតែមានអាវុធកាន់គ្រប់គ្នា។ បាទ គេដេញបាញ់កាត់ភូមិ តែអ៊ំក៏មិនបានចូលមើលដែរ រត់រហូត ខ្ញុំរត់ឆ្លងដល់ភូមិស្ពានស្រែង បានទៅឃើញប្អូនប្រុសដែលគេចងយកទៅសម្លាប់ចោលទាំងអស់គ្នាហ្នឹង រស់មកវិញហ្នឹង ថាវាកន្ទ្រាក់ខ្សែពីរដងដាច់ គេដេញដែរ ប៉ុនដេញ គេដេញមិនឆ្ងាយ វារត់ដួល

បុកនឹងភ្លីប្រឡាយ ហើមមុខប៉ុននេះ។ គេសម្លាប់អស់ហើយ បងអើយសម្លាប់អស់ហើយ។

[១៤:២៦:៤១]

ពេលនោះ បាទ អារម្មណ៍របស់ខ្ញុំបាទហ្នឹង គឺថាទ្រុឌទ្រោមអស់ គ្មានអ្វីនៅក្នុងខ្លួនបន្តិចទេ បាទ ដោយការស្តាយអាល័យ ព្រោះថាជីវិតមួយៗកើតមកក្នុងលោកនេះ ប្រាថ្នាដើម្បីរស់។ ចុះបើគេយកទៅសម្លាប់ចោលអ៊ីចឹង គិតយ៉ាងម៉េច។ ពេលនោះ គឺមិនបានទៅឃើញខ្មោច ឃើញអីទេ បាន ពួកយើងខ្ញុំហ្នឹង ចេះតែជម្លៀសខ្លួនចេញពីតំបន់ស្ពានស្រែង រហូតដល់ទៅខេត្តសៀមរាបហ្នឹង បាទ ឆ្លងស្ទឹងស្ពានស្រែង ទៅនៅខាងៗសៀមរាប បាទ។

**សៈ** ចាស សូមអរគុណ។ ចាស សូមលោកនិយាយរៀបរាប់អំពីព្យសនកម្ម និងការឈឺចាប់អារម្មណ៍អាឡោះអាល័យប្រពន្ធដែលជាទីស្រឡាញ់របស់លោក ម្តាយមីង ក្មួយ បង ហើយប្អូនរបស់លោកមើល តើទំហំនៃការឈឺចាប់របស់លោកក្នុងសម័យហ្នឹង បន្សល់ដល់បច្ចុប្បន្នយ៉ាងម៉េចដែរ សូមលោករៀបរាប់ជូនអង្គជំនុំជម្រះ ដើម្បីបានជ្រាបជាព័ត៌មាន។

**ធៈ** បាទ បើគិតទៅអស់ជាង៣០ប្លាយឆ្នាំកន្លងមកនេះ ខ្ញុំបាទមិនដែលភ្លេចមួយនាទីណា នៅក្នុងក្រុមគ្រួសារហ្នឹងទេ។ ថ្វីត្បិតតែខ្ញុំមានប្រពន្ធ ហើយមានកូនដល់ទៅប្រាំមួយនាក់ទៀតហើយ ក៏ខ្ញុំនៅតែអាណិតស្រឡាញ់។ ខ្ញុំឧទ្ទិសកុសលធ្វើបុណ្យជូនគាត់ជារៀងរាល់ឆ្នាំ។ ដូច្នេះ គឺទំហំនៃការស្រឡាញ់របស់ខ្ញុំរកអ្វីប្រៀបផ្ទឹមពុំបានទេ។ ហើយសូមជម្រាបថា មិនគួរ បាទ មិនគួរ។ លោកតែងនិយាយថា អង្គការមហាលោតផ្លោះ មហាអស្ចារ្យ ប៉ុន្តែពេលនោះ សម្លាប់មនុស្សចោលដូចសត្វធាតុ។

ដល់ពេលដែលខ្ញុំត្រឡប់ -- បាទ សូមបន្ថែមត្រង់នេះបន្តិច មកពីខាងខេត្តសៀមរាបវិញ ខ្ញុំបាទទៅមើលខ្មោចហ្នឹង គឺថាទៅក្រៀមក្រញង់អស់ហើយ គ្មានអីទេ។ អត់មានសត្វៗអីស៊ីមួយទេ គឺស្នាមអារកយ៉ាងម៉េច នៅតែអារកអ៊ីចឹង គ្រាន់តែស្វិតស្បែកដណ្តប់ឆ្អឹង ប្រែមួយចំហៀងអ៊ីចឹងមក គឺអាចមានសើមៗនៅខាងខ្នង ព្រោះអត់មានភ្លៀងពេលនោះ ទាំង១២នាក់ហ្នឹង។ ខ្ញុំបាទរើសប្រមូល ហើយកប់ ពេលជួបជុំគ្នាបងប្អូនយាយតា ក៏ធ្វើបុណ្យតាមប្រពៃណី។ ដូច្នេះការឈឺចាប់របស់ខ្ញុំ មិនអាចភ្លេចបានទេមួយជីវិតខ្ញុំក៏ភ្លេចមិនបានដែរ បាទ។

**សៈ** ចាស សូមអរគុណ។ ចាស ជាចុងក្រោយ តើលោកមានសំណូមពរ ឬក៏សំណួរអ្វីសួរទៅជនជាប់ចោទតាមរយៈលោកប្រធានទេ ចាស?

[១៤:៣០:០០]

**ឆ៖** បាទ សំណូមពររបស់ខ្ញុំបាទ ក៏សូមឲ្យលោកប្រធាន តុលាការដាក់ទោស ឧក្រិដ្ឋជន ជនជាប់ចោទ ដាក់គុកងងឹតអស់មួយជីវិត។ ហើយសូមទាមទារសំណងតាមការស្នើសុំរបស់យើងខ្ញុំតាមរយៈមេធាវី ហើយក៏ខ្ញុំសូមសួរសំណួរតាមរយៈលោកប្រធាន។ ក្នុងនាមលោក នួន ជា, លោក ខៀវ សំផន មេដឹកនាំប្រទេសក្នុងកម្ពុជារំដោះ ១៧ មេសា ៧៥ ដល់ ០៦ មករា ៧៩។ បិទផ្លូវទំនាក់ទំនងបរទេស និងកម្ពុជា។ បាទ មួយទៀត លោក នួន ជា និងលោក ខៀវ សំផន របបខ្មែរក្រហមរបស់លោកថា អង្គការភ្នែកម្នាស់ ឬភ្នែកមានច្រើន ហេតុអ្វីមិនដឹងពីការសម្លាប់មនុស្ស បង្អត់អាហារ បង្ខំមនុស្សធ្វើការធ្ងន់ធ្ងរគ្មានពេលសម្រាក? បាទ ទី៣ ហេតុអ្វីបានជាអង្គការរបស់លោកបង្ខំមនុស្សឲ្យរៀបការជាហ្វូងៗ ហើយពួកលោកមិនស្គាល់ -- ដែលពួកខ្ញុំមិនស្គាល់គ្នាសោះ និងបង្ខំឲ្យស្រឡាញ់គ្នាក្រោយមកក៏បំបែកគ្នាចេញពីគ្នា?

**លោកស្រី ស៊ីន សុវ៉ន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំអស់សំណួរសួរហើយ ប៉ុន្តែមានសហការីខ្ញុំ គាត់ចង់សួរសំណួរបន្ត។ ចាស គាត់អត់មានសំណួរអីសួរទេ។ អ៊ីចឹង សូមអរគុណលោកប្រធាន សូមផ្តល់វេទិកាដល់ភាគីផ្សេង។ ចាស អរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញ លោក គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមធ្វើការកត់សម្គាល់ខ្លីទេ ទាក់ទងសំណូមពររបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលគាត់ស្នើសុំថា ឲ្យដាក់គុកងងឹតអស់មួយជីវិត។ ហើយខ្ញុំយល់ថា ការស្នើសុំនេះវាមិនស្របតាមផ្លូវច្បាប់ទេ។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមជម្រាបលោក មាន លឿយ ថានៅក្នុងសវនាការកន្លងមក គឺសវនាការកាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ អង្គជំនុំជម្រះបានសួរបញ្ជាក់ទៅជនជាប់ចោទទាំងពីររូប ហើយអំពីការដែលពួកគាត់រក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបនឹងសំណួរ ហើយសវនាការនោះ ក៏អង្គជំនុំជម្រះបានកត់សម្គាល់ថាជនជាប់ចោទទាំងពីរនាក់នៅតែរក្សាជំហររបស់ខ្លួន អនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបដដែលលើកលែងតែ និងរហូតដល់ពេលដែលអង្គជំនុំជម្រះទទួលបានព័ត៌មានជាក់ច្បាស់ផ្សេងពីជនជាប់ចោទ

ឬក៏ពីសហមេធាវីការពារក្តីជនជាប់ចោទ។

[១៤:៣៣:២០]

ហើយនៅក្នុងសវនាការនោះ អង្គជំនុំជម្រះក៏បានកំណត់ឲ្យជនជាប់ចោទ និងមេធាវីការពារក្តីរបស់ជនជាប់ចោទត្រូវមានការទទួលខុសត្រូវក្នុងការជូនដំណឹងដល់អង្គជំនុំជម្រះឲ្យទាន់ពេលវេលា និងមានប្រសិទ្ធភាព ប្រសិនបើជនជាប់ចោទសម្រេចលះបង់សិទ្ធិនៅស្ងៀមមិនឆ្លើយតប ហើយយល់ព្រមឆ្លើយតបនឹងសំណួររបស់អង្គជំនុំជម្រះ ឬក៏ភាគីពាក់ព័ន្ធនៃដំណាក់កាលណាមួយនៃកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយរហូតដល់មកពេលនេះ អង្គជំនុំជម្រះនៅមិនទាន់បានទទួលដំណឹងពីការផ្លាស់ប្តូរជំហររបស់ជនជាប់ចោទទាំងពីរនាក់ ពីការសម្រេចលះបង់សិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយតប មកជាការឆ្លើយតបនឹងសំណួរនៅឡើយទេ។ ហើយជម្រាបបញ្ជាក់ថែមថា អង្គជំនុំជម្រះមិនមានសិទ្ធិពេញលេញតាមផ្លូវច្បាប់ទេនៅក្នុងបង្ខំឲ្យជនជាប់ចោទតបនឹងសំណួររបស់លោកនោះ សូមលោកជ្រាប។

បាទ ឥឡូវនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅដល់ម៉ោងបី ខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ នៅអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ រួមទាំងបុគ្គលិកអង្គការធី.ភី.អូ មកកាន់កន្លែងថ្លែងរៀបរាប់ទុក្ខសោកវេទនារបស់គាត់នៅចំពោះមុខអង្គជំនុំជម្រះ ក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងបី ខ្វះដប់នាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៤ នាទី ដល់ម៉ោង ១៤:៥១ នាទី)*

[១៤:៥១:៥១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

បាទ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយតទៅនេះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីមានឱកាសតាំងសំណួរចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះប្រសិន

បើមាន។

**លោក ត្រាវីស ហ្វារ៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ត្រាវីស ហ្វារ៖**

**ស៖** ជម្រាបសួរលោកដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំជាមេធាវីការិយាល័យសហព្រះរាជអាជ្ញា ខ្ញុំមានសំណួរតិចតួចទេសួរទៅលោក ខ្ញុំសុំសួរទៅលោកអំពីប្រពន្ធទី១របស់លោក ដែលលោកនោះបានរួមដំណេកជាមួយប្រពន្ធរបស់លោកក្រោយរៀបការហើយ ហើយនៅពេលដែលគាត់ស្លាប់ទៅនោះ ពេលគេយកទៅសម្លាប់នោះ មិនដឹងថាតើប្រពន្ធទី១របស់លោកហ្នឹងមានផ្ទៃពោះ ឬក៏អត់នោះទេ។ ដូច្នេះ <ក្រោយមក តើលោកមានដឹងថា ប្រពន្ធរបស់លោកមានផ្ទៃពោះដែរទេ នៅពេលដែលគេយកគាត់ទៅសម្លាប់?>

**លោក មាន លឿយ៖**

**ឆ៖** បាទ ព្រោះថាការមិនដឹងនោះ គឺមិនដែលបានកំណត់ពេលវេលារស់នៅជាមួយគ្នាបានជារៀងរាល់ថ្ងៃ។ អ៊ីចឹង ក្នុងរយៈកាលពេលណាទៅ មួយខែអីបានបានមកលេងផ្ទះម្ដង បានជាមិនដឹង។

**ស៖** ក្រោយពេលគាត់ស្លាប់ទៅ តើលោកមានបានទទួលដំណឹងពីណា ឬក៏ឮដឹងពីណាថា គាត់មានផ្ទៃពោះទេ?

**ឆ៖** បាទ មិនដែលឮទេ។

**ស៖** ឥឡូវនេះ ខ្ញុំសុំសួរលោកអំពីអារម្មណ៍<>របស់លោកនៅ<ពេលដែលលោកធ្វើការនៅ> ការដ្ឋានទំនប់ត្រពាំងថ្ម។ តើលោកមានអារម្មណ៍យ៉ាងម៉េចដែរ? មានអារម្មណ៍ទុក្ខសោកសង្រេង ឬក៏មានអារម្មណ៍សប្បាយចិត្ត ឬក៏<ភិតភ័យ។ តើលោកមានអារម្មណ៍យ៉ាងម៉េចសម្រាប់ជីវិតរបស់លោកនាពេលនោះ>?

**ឆ៖** បាទ ចំពោះខ្ញុំ មិនដែលមានអារម្មណ៍សប្បាយចិត្តទេ មានតែអារម្មណ៍សោកសង្រេង ព្រោះការស្ដាយអាល័យ ដែលប្រពន្ធដែលធ្លាប់បានរស់នៅជុំគ្នា ទោះបីតិចក្ដី ច្រើនក្ដីក៏ជាប្ដីប្រពន្ធដែរ។

[១៤:៥៥:០៤]

**ស៖** ឥឡូវនេះ និយាយពីពេលវេលាដែលលោកធ្វើការនៅការដ្ឋានទំនប់ត្រពាំងថ្ម នៅពេលនោះ

តើលោកសង្ឃឹម ឬក៏ជឿជាក់ថា លោកអាចរស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យដែរទេ?

**ឆ៖** បាទ ក្នុងការរស់នៅអាងត្រពាំងថ្ម មិនដែលមានសេចក្ដីសង្ឃឹមថានឹងរស់នៅបានសព្វថ្ងៃមកដល់សព្វថ្ងៃនេះទេ។ ពេលថ្ងៃបើកភ្នែកឡើងគឺចេញទៅធ្វើការ ដឹងថាពេលនេះមានរស់ តែពេលយប់ដែលមើលមិនឃើញ ខ្លាចក្រែងយើងមានកំហុសអ្វីពីថ្ងៃទៅ ក៏គេយកទៅសម្លាប់ចោល។ ដូច្នេះការសង្ឃឹមមានតែ ខ្លះគេពោលថា "តែយប់ឡើងរស់ ថ្ងៃឡើងគឺងាប់"។ ខ្លះគេពោលថា "ថ្ងៃឡើងងាប់យប់ឡើងរស់" សង្ឃឹមតែម្នាក់មួយថ្ងៃៗប៉ុណ្ណឹងឯងបាទ។

**ស៖** តើការភ័យខ្លាចនេះ វាអាចឲ្យលោកបំភ្លេចបានដោយពេលៗដែរទេ នៅពេលដែលលោកធ្វើការនៅឯការដ្ឋានហ្នឹង ឬក៏ថាការភ័យខ្លាចនេះ វាមានជារៀងរហូត?

**ឆ៖** បាទ នៅក្នុងនោះគឺមិនដែលមានថ្ងៃណាថាសប្បាយចិត្ត គឺការព្រួយបារម្ភ គឺជារៀងរហូត។

**ស៖** ចុះ<ជីវិត>របស់លោកសព្វថ្ងៃ <>តើក្នុងមួយសប្ដាហ៍ ក្នុងមួយថ្ងៃ មួយអាទិត្យ មួយខែលោកនឹកឃើញរឿងនៅការដ្ឋានហ្នឹងប៉ុន្មានដងដែរ?

**ឆ៖** បាទរហូតមកដល់សព្វថ្ងៃនេះ គឺថា ពេលណាក៏ជាពេលមួយដែលនឹកឃើញដែរ ប៉ុន្តែពេលធ្វើបុណ្យទាន បានស្ដាប់ធម៌ ឬក៏ធ្វើសមាធិអីទៅ ឃើញថា ការកង្វល់ហ្នឹងក៏បាត់បង់ខ្លះ ការកង្វល់ហ្នឹងគឺបាត់បង់ទៅ។ តែបើសិនណាជា មិនបានធ្វើបុណ្យទានគគ្រឹកគគ្រេង មានព្រះសង្ឃ មានអី គឺអារម្មណ៍ពិតជាមានបាទ រៀងរាល់ថ្ងៃ។

**ស៖** ខ្ញុំចង់សួរលោកអំពីការបាត់ខ្លួនដែលលោកបានលើកឡើងនោះ។ លោកនិយាយថា<>ប្រសិនណានរណាម្នាក់មិនអាចសម្រេចផែនការការងារបានពីរបីដងហ្នឹងគឺថា<ត្រូវ>បាត់ខ្លួន <ប៉ុន្តែ>លោកក៏ថា<អ្នកខ្លះ>កម្លាំងពលកម្ម<>គាត់មិនអាចធ្វើការបាន<>ដោយសារគាត់ធ្លាក់ខ្លួនឈឺ<ពេលខ្លះក៏ត្រូវបាត់ខ្លួនដែរ>។ <ខ្ញុំចង់សួរថា> តើលោកដែលឮសូរឃ្លាមួយដែលគេនិយាយថា "ទុកក៏មិនចំណេញ ដកចេញក៏មិនខាត" តើលោកដែលឮទេ?

**ឆ៖** បាទ ឮ។

[១៤:៥៨:៥៩]

**ស៖** លោកឮអ្នកណានិយាយឃ្លាហ្នឹង?

**ឆ៖** បាទ ពួកមេកងអ្នកនិយាយ។

**ស៖** តើមេកងហ្នឹងគាត់និយាយឃ្លាហ្នឹងតែម្ដងទេ ឬក៏គាត់និយាយឃ្លាហ្នឹងជាញឹកញាប់?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្រុបគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** បាទ ពេលណាដែលមានអ្នកជំងឺឈឺច្រើន គឺគេនិយាយញើកញាប់ណាស់។

**ស៖** តើលោកនៅទីកឃើញទេមេកងហ្នឹងនិយាយឃ្លាហ្នឹងនៅកន្លែងណា នៅកន្លែងដែលលោកសម្រាន្ត ឬក៏នៅកន្លែងដែលលោកធ្វើការ ឬក៏នៅកន្លែងណាមួយ<ពេលលោកឮ>?

**ឆ៖** បាទ នៅកន្លែងធ្វើការ។

**ស៖** លោកបានលើកឡើងអំពីកិច្ចប្រជុំទិតៀន ស្វ័យទិតៀន លោកអាចជម្រាបអង្គជំនុំជម្រះឲ្យបានលម្អិតជាងនេះបន្តិចបានទេ អ្នកណាជាអ្នកដឹកនាំការប្រជុំទិតៀន ស្វ័យទិតៀនហ្នឹង ហើយនៅក្នុងពេលប្រជុំនោះ គេទិតៀន ស្វ័យទិតៀនអំពីអ្វី?

**ឆ៖** បាទ ចំពោះទិតៀន ស្វ័យទិតៀនហ្នឹង គឺមេកងគេអ្នកហៅយើងទៅ ឧទាហរណ៍ថា ក្រុម ១០នាក់ ត្រូវខុសក្នុងថ្ងៃនេះ គឺលើកមិនរួច។ បាទ គេហៅទៅប្រជុំគេលើកទិតៀនយើងអំពី យើងមិនប្រឹងប្រែង យើងមិនធ្វើពលកម្ម ចង់ជិះជាន់ពលកម្មគេ យើងអត់មានម្ចាស់ការទៅលើការងារ។ អ៊ីចឹងទៅមិត្តឯងត្រូវតែខំប្រឹង បើមិនប្រឹងធ្វើអែល១ប្រយ័ត្នអង្គការថាហើយ "ថាទុកក៏មិនចំណេញ ដកចេញក៏មិនខាត"។ ដូច្នេះ ពាក្យទាំងអស់នេះ គឺដូចរូបខ្ញុំបាទផ្ទាល់តែឮហើយ ដឹងតែពីខ្លាចហើយបាទ។

**ស៖** លោកដែលឮសួរអ្នកណាម្នាក់និយាយអំពីខ្មាំងរបស់អង្គការ ឬក៏ខ្មាំងរបស់បដិវត្តន៍ដែរទេ នៅពេលដែលលោកធ្វើការនៅការដ្ឋានទំនប់ត្រពាំងថ្ម?

**ឆ៖** បាទ ជម្រាប រឿងគេថា "ខ្មាំង" ឧទាហរណ៍ដូចជា បង្គី ដងរែក ចបកាប់ គឺអ្នកត្រូវរក្សាឲ្យបាន។ បាទ តែបាត់បង្គីមួយគេចោទយើងថាខ្មាំង។ បាក់ដងរែកសម្រាប់រែក គេចោទយើងថាខ្មាំង។ ត្រឹមតែចបកាប់បាក់ដង ក៏គេចោទថាខ្មាំងដែរ។

**ស៖** លោកអាចជម្រាបអង្គជំនុំជម្រះបានទេ អ្នកណាជាអ្នកពិនិត្យមើលថា<តើមានបាត់អីវ៉ាន់ ឬ>ក្រែងលោបាក់ដងចប<>ឬក៏ធ្វើការមិនគ្រប់តាមផែនការ អ្នកណាគេជាអ្នកតាមដានហ្នឹង?

**ឆ៖** បាទ មានតែមេកងហ្នឹងហើយជាអ្នកដើរមើល។ ពេលលើកក្នុងថ្ងៃនេះ មេកងគេគ្មានធ្វើការទេ គេដើរមើលតែយើងអ្នកលើក។ ដូច្នេះ គឺមានតែមេកងជាអ្នកដើរត្រួតពិនិត្យ ដឹងថាចបបាត់ ឬក៏ចបបាក់ បង្គីរហែក បង្គីដាច់ដៃ បាក់ដងរែកមិនធ្វើ អាហ្នឹងគឺគេ គេហើយអ្នកដើរមើលបាទ។

[១៥:០៣:៣៥]

**ស៖** ចុះចំពោះការស៊ើបសួរប្រវត្តិរបស់ប្រជាជនអ្នកណាធ្លាប់បានធ្វើអ្វីនៅមុនរបបកម្ពុជាប្រជាធិបតេយ្យ។ តើលោកមានបានដឹង មានបានកត់សម្គាល់អីណាមួយចំពោះការស៊ើបរកប្រវត្តិរូបប្រជាជន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

នេះទេ?

**ឆ៖** បាទ អត់ទេ។

**ស៖** ចុះតើលោកមានបានដឹងថា មានឈ្លបស្រុកមានវត្តមាននៅការដ្ឋាននោះដែរទេ?

**ឆ៖** បាទ មិនដែលឃើញទេ មិនដែលដឹង។

**ស៖** តើលោកធ្លាប់បានដឹងថា ពលករធ្លាប់ព្យាយាមគេចខ្លួនចេញពីការដ្ឋាននោះដែរទេ ធ្លាប់រត់គេចចេញពីការដ្ឋាននោះដែរទេ?

**ឆ៖** បាទ មិនដឹងទេ។

**ស៖** ចុះការវាយដំ ឬក៏ទារុណកម្មក្នុងទម្រង់ណាមួយមកលើរូបរាងកាយហ្នឹង លោកដែលបានឃើញទេ?

**ឆ៖** បាទ មិនដែលឃើញទេ។

**ស៖** តើលោកធ្វើការជាចម្បង ការងារចម្បងជាងគេ តើលោកជាអ្នកកាប់ដី ឬក៏លោកជាអ្នករែកដី <ឬក៏លោកធ្វើទាំងពីរហ្នឹង>?

**ឆ៖** បាទ ខ្ញុំជាអ្នករែក។

**ស៖** តើលោកអាចប៉ាន់ប្រមាណបានទេ ចម្ងាយពីកន្លែងកាប់ដី ហើយនិងរែកដីយកមកចាក់ៗអាចម៍ដីហ្នឹង ចម្ងាយពីកន្លែងកាប់ដី និងចាក់អាចម៍ដី ចម្ងាយឆ្ងាយពីគ្នាប៉ុន្មានដែរ?

**ឆ៖** បាទ បើចំពោះស្ពានទី១ អាហ្នឹងខ្ញុំឮមេកងនិយាយ ប៉ុន្តែវាចម្ងាយមែន។ គ្រាន់តែពីពាក់កណ្ដាលថ្នល់ទៅៗរកចិញ្ចើមប្រឡាយ វា១០០ម៉ែត្រ។ ដូច្នេះបាតស្ពានហ្នឹង គឺ២០០ម៉ែត្រ កន្លែងនោះគឺវាឆ្ងាយណាស់ បាទរែកឡើងឆ្ងាយណាស់។ កាលពីទាប រែកដូចថាគ្រាន់បើ ដល់កាន់តែខ្ពស់ទៅ កាន់តែយ៉ាកឡើង។ បាទ អានោះចម្ងាយនៅស្ពានទី១។ តែក្រៅពីទីដទៃទៀត មិនឆ្ងាយដល់ប៉ុណ្ណោះទេបាទ។

**ស៖** តើលោកអាចមានមធ្យោបាយណាមួយនោះ គិតពីទំងន់ដីដែលលោករែកមួយជើងៗហ្នឹងណា មានទំងន់ប៉ុន្មានដែរ?

**ឆ៖** បាទ មិនអាចប៉ាន់ស្មានបានទេ។

[១៥:០៧:២៦]

**ស៖** ខ្ញុំសូមសួរលឿនទេអំពី<>ម៉ោងការងាររបស់លោកៗបានលើកឡើងម្ដងមកហើយ ប៉ុន្តែតើលោកអាចជម្រាបមើលនៅពេល -- គិតពីពេលចាប់ផ្ដើមចុះធ្វើការ សម្រាកបាយថ្ងៃត្រង់ ចាប់ផ្ដើម

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ក្រោយពេលបាយថ្ងៃត្រង់ ហើយនិងពេលឈប់ពីការងារនៅពេលល្ងាច និង<វេន>ការងារនៅពេលយប់?

**ឆ៖** បាទ ពេលវេលាធ្វើការ គឺព្រឹកឡើងដឹងតែថ្ងៃរះ គឺទៅដល់កន្លែងជីកអន្លង់ដីហើយ ជីកដីហើយ បាទ រហូតទៅដល់ម៉ោងដប់មួយ បានគេឱ្យសម្រាក។ បាទ ម៉ោងដប់មួយ តែម៉ោងមួយគឺគេដេញឱ្យចុះធ្វើការទៀតហើយ រហូតដល់ម៉ោងប្រាំល្ងាច បានគេឱ្យឡើង បាទ។

**ស៖** ហើយក្រោយពេលឈប់សម្រាកហើយ តើចាប់ផ្ដើមបន្តការងារនៅម៉ោងប៉ុន្មាន?

**ឆ៖** បាទ ជម្រាប។ តំបន់ដែលធ្វើការបន្ថែមនៅយប់ហ្នឹងគឺចាប់ពីម៉ោងប្រាំមួយល្ងាច ព្រោះថាម៉ោងប្រាំមួយពេលនោះ យើងអត់មានម៉ោងទេ ត្រឹមការប៉ាន់ស្មាន បាទ ដល់ម៉ោងដប់យប់។ ព្រោះថាក្នុងរយៈពេលអាងត្រពាំងថ្មហ្នឹងត្រូវស្ដុបទឹក គឺអាងត្រពាំងថ្មត្រូវប្រេះជាពីរ។ ពេលនោះ កម្លាំងគឺសម្រុកមែន សម្រុកទាំងយប់ទាំងថ្ងៃ អត់មានឈប់ខ្លាចវាបាក់។ នៅចុងឆ្នាំ ប្រហាក់ប្រហែលជាចុងឆ្នាំ៧៧ ខែ៩ គឺខាងស្រុកខ្ញុំនោះ តែខែ៩ ទឹកជន់ហើយ បាទ ជន់មកពីក្បាលស្ទឹងមក គឺធ្លាក់ចំអាងតែម្ដង។ ដូច្នេះគឺថាការធ្វើការពេលនោះគឺគេកំណត់ទាំងយប់ទាំងថ្ងៃ តាំងពីហូបបាយរួចល្ងាចដឹងថានាំគ្នាសម្រុកទៅបិទ។ បាទជីកពីក្រោមឡើងទៅលើវិញ ពេលស្ដុបទឹក បាទ។

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី សំណួរខ្ញុំចុងក្រោយ។ លោកបាននិយាយអំពីរបបអាហារ <ការងារលំបាក> ពេលម៉ោងការងារ<ច្រើន និង>ភាពភ័យខ្លាច។ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ <ថា តើអ្វីជាទិដ្ឋភាពដ៏លំបាកជាងគេ នៅពេលលោកបំពេញការងារនៅការដ្ឋានទំនប់ត្រពាំងថ្មហ្នឹង?> ចំណុចមួយណា ដែលពិបាកជាងគេ <ទាក់ទងនឹងផ្លូវកាយ និងផ្លូវ>អារម្មណ៍<របស់លោកនោះ>?

**ឆ៖** បាទ ការតឹងតែងទាំងផ្លូវអារម្មណ៍ ទាំងផ្លូវកាយ គឺតឹងតែងទាំងអស់ ព្រោះថាការលើកទំនប់អាងត្រពាំងថ្មហ្នឹង គឺរែកដីមួយថ្ងៃៗមិនមែនតិចទេ ដូច្នេះម្នាក់ៗខ្នងចង់កោងអស់ហើយ គិតឃើញពេលណា អារម្មណ៍វាមិនជ្រះស្រឡះទេ តឹងតែងរហូត ទាំងផ្លូវកាយ ទាំងផ្លូវចិត្តហើយ។

**លោក ត្រាវីស ហ្វារះ**

សូមអរគុណដែលបានឆ្លើយនឹងសំណួររបស់ខ្ញុំ លោកដើមបណ្ដឹងរដ្ឋប្បវេណី។

សូមអរគុណលោកប្រធាន ចប់ អស់សំណួរហើយ។

[១៥:១១:៣៩]

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តី។ ដំបូងនេះ ផ្តល់ទៅក្រុមមេធាវី សហការពារក្តីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ បាទ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ជម្រាបសួរលោកដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំមានសំណួរតិចតួចដែរទេ ដែលត្រូវសួរទៅលោក។ លោកទើបតែឆ្លើយសំណួរតំណាងសហព្រះរាជអាជ្ញាថា ពេលដែលលោកនៅឯការដ្ឋានលើកទំនប់នោះ លោកមិនដែលឃើញគេវាយដំអ្នកណាទេ ប៉ុន្តែនៅពេលដែលធ្វើការនៅឯការដ្ឋានហ្នឹង លោកដែលធ្លាប់បានឃើញគេសម្លាប់មនុស្សដោយផ្ទាល់ទេ?

**លោក មាន លឿយ៖**

**ឆ៖** បាទ អត់ទេ។

[១៥:១២:៣៦]

**ស៖** តើលោកធ្លាប់ដែលឃើញអ្នកណាម្នាក់ទទួលរងរបួស ដោយសារតែគ្រោះថ្នាក់ការងារទេ?

**ឆ៖** បាទ មិនដែលឃើញទេ។

**ស៖** តើលោកធ្លាប់ឃើញអ្នកណាម្នាក់ត្រូវបានគេចាប់ខ្លួនដែរទេ នៅពេលដែលលោកនៅឯការដ្ឋាននោះ?

**ឆ៖** បាទ មិនដែលឃើញទេ។

**ស៖** តើលោកធ្លាប់ត្រូវបានមេកងរបស់លោកដាក់ពិន័យ ឬក៏វាយដំមកលើរូបលោកទេ?

**ឆ៖** បាទ មិនដែលមានទេ។

**ស៖** ចុះលោកធ្លាប់ដែលធ្លាក់ខ្លួនឈឺទេ នៅពេលដែលលោកធ្វើការនៅការដ្ឋានលើកទំនប់នោះ?

**ឆ៖** បាទ ធ្លាប់។

**ស៖** លោកឈឺអ្វីដែរ? ម៉េចបានជាលោកធ្លាក់ខ្លួនឈឺ ហើយឈឺអ្វី?

**ឆ៖** បាទ គ្រុន – គ្រុនពេល គ្រុនក្ដៅ។

**ស៖** ហើយនៅពេលដែលលោកមានរោគសញ្ញាគ្រុនហ្នឹង ឬក៏ឈឺគ្រុនហ្នឹង តើលោកមានបានសុំច្បាប់ឈប់សម្រាកដែរទេ?

**ឆ៖** បាទ ពេលឈឺ យើងប្រាប់មេកងទៅ សុំគេសម្រាកមួយពេលបាន។

[១៥:១៤:៥៥]

**ស៖** តើមានកម្លាំងពលកម្មណាម្នាក់នៅក្នុងកងរបស់លោកនេះ ធ្លាក់ខ្លួនឈឺ ឈឺបន្តទៅទៀត ហើយត្រូវបញ្ជូនទៅមន្ទីរពេទ្យដើម្បីសម្រាកឲ្យបានជាសះស្បើយដែរទេ?

**ឆ៖** បាទ មិនដែលមាន មិនដែលបានឃើញទេ។

**ស៖** តើលោកធ្លាប់ដែលឮសួរពលករធ្លាប់ខ្លួនឈឺ ហើយមិនជា ហើយសុំការអនុញ្ញាតដើម្បីឲ្យគេដឹករទេះគោយកទៅមន្ទីរពេទ្យស្រុកអីដែរទេ?

**ឆ៖** បាទ មិនដែលឃើញទេ។

**ស៖** តើលោកធ្លាប់ឃើញអ្នកណាម្នាក់ស្លាប់ មិនមែនដោយសារតែគេសម្លាប់ទេ ប៉ុន្តែស្លាប់ដោយសារតែការងារបាក់កម្លាំងដែរទេ?

**ឆ៖** បាទ មិនដែលឃើញទេ។

**ស៖** តំណាងសហព្រះរាជអាជ្ញាទើបតែសួរលោកអំពីពាក្យស្លោក ឬក៏ជាសុភាសិតមួយថា "ទុកក៏មិនចំណេញ ដកចេញក៏ខាត" ហើយលោកឆ្លើយថា លោកឮមេកងរបស់លោកបាននិយាយសុភាសិតគេនេះច្រើនដងដែរ។ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ ថាហេតុអីបានជាមេកងរបស់លោកនិយាយច្រើនដងបែបហ្នឹង ប៉ុន្តែបែរជាអនុញ្ញាតឲ្យលោកសម្រាក ដេកសម្រាកនៅពេលលោកឈឺ <ហើយជាសះស្បើយ>?

**ឆ៖** បាទ ព្រោះថាពលកម្មរបស់ខ្ញុំបាទហ្នឹង គឺមិនដែលខានទេ។ កិច្ចការណាដែលប្រធានប្រគល់ឲ្យ គឺធ្វើជាទៀងរហូត ប៉ុន្តែឈឺមួយពេល គេអាចអនុគ្រោះឲ្យយើង។

[១៥:១៧:៤២]

**ស៖** ខ្ញុំដូចជាយល់មិនទាន់ច្បាស់ទេ។ តើមេកងរបស់លោកនេះ និយាយសុភាសិតនេះទៅកាន់អ្នកណាដែរ នៅពេលដែលគាត់និយាយថា "ទុកក៏មិនចំណេញ ដកចេញក៏ខាត" ហ្នឹង គាត់និយាយទៅកាន់អ្នកណា?

**ឆ៖** បាទ ពេលគេប្រជុំរួមគឺគេនិយាយជាមួយកងចល័តទាំងអស់ហ្នឹង។ ក្នុងកង១០០នាក់ហ្នឹង គេនិយាយឲ្យឮទាំងអស់គ្នាតែម្ដង។

**ស៖** ខ្ញុំយល់ហើយ ប៉ុន្តែតើលោកយល់ថា មេកងរបស់លោកនេះ និយាយទៅកាន់អ្នកណាដែរ សំដៅទៅអ្នកណាដែរ នៅពេលដែលគាត់និយាយឃ្លាហ្នឹង?

**ឆ៖** បាទ មិនដែលបានឮគេនិយាយសំដៅទៅលើបុគ្គលម្នាក់ទេ គឺពេលប្រជុំ បានគេនិយាយសំដៅទាំងអស់គ្នាតែម្ដង។

**ស៖** នៅពេលនុ៎ង នៅពេលដែលលោកឮសូរសុភាសិតហ្នឹង តើលោកយល់ថា សុភាសិតនេះមានន័យដូចម្ដេចដែរ?

**ឆ៖** បាទ សុភាសិតមួយនេះ គឺគេសំដៅទៅលើថា "ទុកមិនចំណេញ ដកចេញក៏មិនខាត"។ បុគ្គលនាដែលប្រព្រឹត្ត មិនប្រព្រឹត្តតាមមាគ៌ារបស់អង្គការ គឺថាគេមិនទុកតែម្ដង គេយកទៅសម្លាប់ចោល។ នេះ ខ្ញុំយល់តែប៉ុណ្ណេះឯង។

**ស៖** លោកក៏ទើបតែបាននិយាយអំពីការងារក្រោយពេលងងឹតទៅ ដូចជាបន្ទាប់ពីម៉ោង ចាប់ពីម៉ោងប្រាំមួយ ឬក៏ម៉ោងប្រាំពីររហូតដល់ម៉ោងដប់។ តើការងារពេលយប់នេះ គេឲ្យធ្វើតែម្ដងម្កាល នៅពេលត្រូវវាយសម្រុក<ការងារ> ឬក៏ថាការងារពេលយប់នេះគឺជាការងារជាប្រចាំដែរ?

**ឆ៖** បាទ ការងារនេះ មិនមែនជាប្រចាំ គឺពេលការងារសម្រុក។

**ស៖** តើស្ត្រីដែលលោករៀបការជាមួយដែលលោកបាននិយាយពីខាងដើមនេះ គាត់ធ្វើការនៅការដ្ឋានលើកទំនប់នោះដែរទេ?

**ឆ៖** បាទ មិនបានធ្វើការនៅការដ្ឋាននោះទេ។

**ស៖** ចុះសាច់ឈាមរបស់គាត់ទាំង ១៣នាក់ដែលលោកថាអ្នកទាំងអស់នោះត្រូវបានយកទៅសម្លាប់ចោលនោះ មុនហ្នឹង មានអ្នកណា<ម្នាក់ក្នុងចំណោមហ្នឹង>ធ្វើការនៅការដ្ឋានលើកទំនប់នេះដែរទេ?

**ឆ៖** បាទ មាន។

**ស៖** តើ <រ៉េត> និង អឿន ជាអ្នកណាដែរ?

**ឆ៖** អឿន ហ្នឹងជាចៅហ្វាយស្រុក។ រ៉េត ជាយោធាស្រុក បាទ។

**ស៖** តើ រ៉េត និង អឿន មានតួនាទីអ្វីនៅការដ្ឋានលើកទំនប់ដែរឬទេ? តើពួកគេមានតួនាទីក្នុង

បញ្ហាអីដែរទេ?

**ឆ៖** បាទ ពេលនោះ ខ្ញុំក៏មិនដែលឃើញដែរ។

[១៥:២២:៥២]

**ស៖** នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោកគឺឯកសារD22/1934 លោកបានលើកឡើងថាទាំង រ៉េត ទាំង អឿន គឺជាអ្នកទទួលខុសត្រូវចំពោះព្យសនកម្ម គឺការខូចខាត ហើយនិង<ឧក្រិដ្ឋកម្ម>ទាំងឡាយ។ តើ<អ្វីដែល>អ្នកទាំងពីរនេះ ត្រូវទទួលខុសត្រូវអ្វីឲ្យពិតប្រាកដលោក?

**ឆ៖** បាទ ពេលគេចាប់ក្រុមគ្រួសារខ្ញុំបាទទៅ គឺអ្នកទាំងពីរហ្នឹងអ្នកទទួលខុសត្រូវ ព្រោះថាជាថៅហ្វាយស្រុក ជាគណៈស្រុក ហើយនិងគណៈឃោធា ហើយនៅពេលនោះតាមប្អូនប្រុសរបស់ខ្ញុំដែលរស់នៅសព្វថ្ងៃហ្នឹង គេប្រាប់ថា តាពីរនាក់ហ្នឹងដែលបញ្ជាឲ្យយកទៅសម្លាប់ចោល។

**ស៖** តើការចាប់ខ្លួនប្រពន្ធរបស់លោកនិងសាច់ញាតិបងប្អូនរបស់គាត់ហ្នឹង<មានអ្វីពាក់ព័ន្ធនឹងការងារលើកទំនប់នោះដែរទេ>?

**ឆ៖** អត់ទេ នៅវាលស្រែច្រូតស្រូវ។

**ស៖** ខ្ញុំខ្លាចតែខ្ញុំយល់ច្រឡំទេ។ តើលោកចង់និយាយថាការចាប់ខ្លួននេះ មិនពាក់ព័ន្ធ<>ទៅនឹងអ្នកដែលធ្វើការនៅទំនប់នោះទេ<។ មែនទេ>?

[១៥:២៥:០៣]

**ឆ៖** បាទ ការចាប់ខ្លួននេះមិនមែនពាក់ព័ន្ធទៅលើការលើកទំនប់ទេ គឺរយៈពេល ដូចខ្ញុំបានរៀបរាប់ពីមុនរួចមកហើយ ថាចាប់ខ្លួនដែល ពេលដែលទៅនៅច្រូតស្រូវ ហើយក៏មានការភ្ញាក់ផ្អើល ក៏នាំគ្នាទៅរកម៉ែ រកឪទៅ ក៏គេចាប់យកទៅដាក់សាលាស្រុកគេយកទៅសម្លាប់ចោលទៅ។

**ស៖** បន្ថែមទៅលើ រ៉េត និងអឿន នេះ លោកក៏បានលើកឡើងផងដែរថា ព្រះបិតាសម្ដេច នរោត្តម សីហនុ ក៏ត្រូវទទួលខុសត្រូវក្នុងអំពើទាំងអស់នោះដែរ ដោយសារព្រះអង្គនេះ គឺជាអ្នកបង្កើតខ្មែរក្រហមដែរ។ តើលោកចង់និយាយថាម៉េចកន្លែងនេះ?

**ឆ៖** បាទ ត្រង់កន្លែងនេះ ព្រោះថាតាមនិយមន័យរបស់ខ្ញុំ នៅពេលនោះគឺសម្ដេចឪលោកបានប្រកាសថាឲ្យកូនចៅរត់ចូលព្រៃម៉ាគី។ ដូច្នេះចាប់ពីពេលនោះមក គឺកើតខ្មែរក្រហមហ្នឹងឯង បានថាពេលព្រះអង្គប្រកាសថាឲ្យរត់ចូលព្រៃម៉ាគី ដល់ពេលគាត់មក បែរជាខ្មែរក្រហម អ្នកកាន់កាប់ទៅវិញទៅលោក ប៉ុល ពត អីកាន់កាប់ទៅវិញ។ ដូច្នេះព្រះអង្គក៏ជាជនរងគ្រោះដែរ ពេលនោះព្រះអង្គមែន តែ

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

ដល់ទីបញ្ចប់ព្រះអង្គជាជនរងគ្រោះដែរ។

**ស៖** សូមអរគុណលោកដើមបណ្ដឹងរដ្ឋប្បវេណី។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

[១៥:២៧:០៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះ ផ្ដល់វេទិកាទៅក្រុមសហមេធាវីការពារក្ដីលោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោកដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំមានសំណួរខ្លីៗទេដើម្បីចោទសួរលោកក្នុងឋានៈជាមេធាវីរបស់លោក ខៀវ សំផន។ យើងមានឯកសារមួយចំនួនដែលជារបាយការណ៍ពាក់ព័ន្ធទៅនឹងពាក្យសុំតាំងខ្លួនរបស់លោកជាដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿងយើងនេះ។ ខ្ញុំចង់ដឹងថាអ្វីដែលលោកបានបញ្ជាក់ជាមួយនឹងអ្នកដែលសម្ភាសលោកពេលដែលបំពេញទម្រង់បែបបទហ្នឹង គឺលោកពិតជាបានឆ្លើយ<អ៊ីចឹង>មែន<ដូចដែលលោកបានឆ្លើយប្រាប់យើងថ្ងៃនេះ គឺ>ថាផែនការ ដែលគេឲ្យសម្រេចបានក្នុងមួយថ្ងៃហ្នឹង<នៅទំនប់ត្រពាំងថ្មនោះ> គឺត្រូវតែលើកដីឲ្យបាន <៣>ម៉ែត្រគូបក្នុងមួយថ្ងៃនោះ?

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណីកុំទាន់អាលឆ្លើយតប! សូមអញ្ជើញសហមេធាវីអន្តរជាតិនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានការបំភ្លឺតូចមួយ ប្រហែលជាភាគីទាំងអស់មិនដឹងពីការរៀបចំរបាយការណ៍<របស់អង្គភាពគាំពារជនរងគ្រោះ>ទេ។ ការពិតទៅ គឺជាបុគ្គលិកនៃអង្គភាពគាំពារជនរងគ្រោះជាអ្នកធ្វើសំយោគនៃខ្លឹមសារព័ត៌មានរបស់គាត់ជាភាសាខ្មែរ។ ហើយនៅពេលដែលធ្វើរបាយ-ការណ៍ហ្នឹងគឺបុគ្គលិកអង្គភាពគាំពារជនរងគ្រោះហ្នឹង មិនមានទាក់ទងទៅនឹងដើមបណ្ដឹងរដ្ឋប្បវេណី

ទេ។ <នេះគ្រាន់តែជាសំយោគចេញពី>ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី<ដែលជាឯកសារដើមជាភាសាខ្មែរ> ហើយបុគ្គលិកអង្គភាពគាំពារជនរងគ្រោះហ្នឹង គាត់ធ្វើការសង្ខេបហ្នឹងជាភាសាអង់គ្លេស។

[១៥:២៩:១៤]

**សួរដោយកញ្ញា អង់តា ហ៊្គីសសេះ**

**ស៖** សូមអរគុណចំពោះការឆ្លើយបំភ្លឺនេះ។ នៅក្នុងឯកសារE3/4889 ដែលជាទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ ក្នុងនោះមានការបំពេញព័ត៌មាន <យើងរកឃើញថា មាន>ចំណុចមួយចំនួនពាក់ព័ន្ធទៅនឹងព័ត៌មានដែលលោកបានបំពេញ។ ដូច្នេះ ខ្ញុំចង់ដឹងថាតើ -- <ក្នុងឯកសារ E3/4889> ជាភាសាបារាំង 00895211 ហើយជាភាសាខ្មែរគឺ <0054045-46*(ស៊ីក)*>, ជាភាសាអង់គ្លេស 01061251។ នៅក្នុងឯកសារ E3/4889 ហ្នឹង គឺមានការរៀបរាប់បញ្ជាក់ថា លោកបានរៀបរាប់ថាមានការកំណត់ឲ្យរែកដីហ្នឹង គឺ៥ម៉ែត្រគូបក្នុងមួយថ្ងៃ ហើយនៅក្នុងសវនាការនេះ លោកបញ្ជាក់ថា តែ៣ម៉ែត្រគូបទេ។ អ៊ីចឹងខ្ញុំចង់ឲ្យលោកឆ្លើយបញ្ជាក់មើលថា លោកពិតជាបានបញ្ជាក់ជូនអ្នកសម្ភាសលោកពេលហ្នឹងថា ៣ម៉ែត្រគូបឬក៏៥ម៉ែត្រគូប?

**ឆ៖** បាទ តែ៣ម៉ែត្រគូបទេ។

**ស៖** សូមអរគុណចំពោះការឆ្លើយបំភ្លឺនេះ។ ខ្ញុំសូមការបញ្ជាក់មួយទៀតពីលោក លោកបានឆ្លើយជូនលោកមេធាវី កូប៉េ ថាការស្លាប់សមាជិកគ្រួសាររបស់លោកមិនមានអ្វីពាក់ព័ន្ធនឹងទំនប់<ត្រពាំង>ថ្មទេ។ អ៊ីចឹង លោកអាចបញ្ជាក់ថា នៅឆ្នាំ១៩៧៩ នៅពេលដែលវៀតណាមវាយចូលហ្នឹងទើបលោកបានដឹងអំពីការស្លាប់របស់សមាជិកក្រុមគ្រួសារលោកមែនទេ?

[១៥:៣១:២៧]

**ឆ៖** បាទ ការស្លាប់នៅក្រុមគ្រួសារខ្ញុំ គឺខ្ញុំដឹងតាំងពីថ្ងៃគេចាប់ទៅ ប៉ុន្តែដែលសរសេរនៅក្នុងឯកសារថាឆ្នាំ១៩៧៩ គឺប្អូនខ្ញុំអ្នកដែលរស់នៅហ្នឹងទេ គេប្រាប់ថា ប្រពន្ធកូនរបស់បងហ្នឹង គឺស្លាប់ដោយសារគេយកទៅអារកចោល ហើយខ្ញុំរត់រួច។ អ៊ីចឹង គឺថាក្នុងឯកសារបានសរសេរឆ្នាំ៧៩នោះ គឺមិនមែនទេ ចុងឆ្នាំ៧៨ បាទ។

**ស៖** សូមអរគុណចំពោះការឆ្លើយបំភ្លឺនេះ។

**កញ្ញា អង់តា ហ៊្គីសសេះ**

លោកប្រធានខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

បាទ សវនាការថ្ងៃនេះ ដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការថ្ងៃនេះត្រឹមនេះ ហើយសវនាការលើបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃព្រហស្បតិ៍ ទី០៣ ខែកញ្ញា ឆ្នាំ ២០១៥ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។ សវនាការនៅថ្ងៃស្អែក អង្គជំនុំជម្រះនឹងធ្វើសវនាការបង្ហាញឯកសារគន្លឹះសំខាន់ៗពាក់ព័ន្ធជាមួយនឹងអង្គហេតុការដ្ឋានទំនប់១មករា ការដ្ឋានការងារព្រលានយន្តហោះកំពង់ឆ្នាំង និងការដ្ឋានការងារទំនប់ត្រពាំងថ្ម ដែលនឹងបន្តធ្វើដោយសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។ សូមភាគីជ្រាប និង អញ្ជើញចូលរួមតាមពេលវេលាដែលបានកំណត់នេះ។

អង្គជំនុំជម្រះអរគុណលោក មាន លឿយ សវនាការស្ដាប់សេចក្ដីថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា និង ស្ថានភាពព្យសនកម្មដែលលោកអះអាងថាលោកបានទទួលរងនូវក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពាក់ព័ន្ធនឹងអង្គហេតុការដ្ឋានការងារទំនប់ត្រពាំងថ្មបានដល់ទីបញ្ចប់ហើយ លោកអាចសម្រាកបានហើយ ហើយអង្គជំនុំជម្រះក៏អរគុណដែរ លោក យ៉ូន សារ៉ាត់ បុគ្គលិកអង្គការ ធី.ភី.អូ ឥឡូវនេះ លោកអាចសម្រាកបានហើយ។

ហើយបង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោក មាន លឿយ វិលត្រឡប់ទៅកាន់លំនៅរបស់គាត់ ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប លោក នួន ជា និង លោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ ចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ទាំងពីររូបត្រឡប់ចូលរួមសវនាការនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៥:៣៣ នាទី)*